**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ប្រព័ន្ធទ្រព្យសម្បត្តិប្តី ប្រពន្ធ

## នៅក្រោមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ស្រាវជ្រាវពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨


ស្រាវជ្រាវដោយ ៖

និស្សិតឈ្មោះ៖ កញ្ញា **ម៉េង លក្ខិណា**

កញ្ញា **សែ សុជាតា**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ម៉ួយ ធីតា**


| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលរៀន ២០១៤ |
| ជំនាន់ទី ១៨ | ឆ្នាំសរសេរសារណា ២០១៨ |

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ម៉េង លក្ខិណា** និង នាងខ្ញុំឈ្មោះ **សែ សុជាតា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧-២០១៨ បានសរសេរនូវកម្រងសារណាមួយនេះឡើង៖

**សូមគោរពលំអោនកាយវាចាចិត្ត សម្ដែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ ៖**

| | |
|---|---|
| លោកឪពុក **ឈុន ម៉េង** | លោកឪពុក **ហម ម៉េងសែ** |
| អ្នកម្ដាយ **លី ពៅ** | អ្នកម្ដាយ **ចុង ឡាន់ណា** |

ដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ ណែនាំ ផ្ដល់ដំបូន្មាន និងផ្គត់ផ្គង់គ្រប់សព្វបែបយ៉ាង ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ទាំងផ្នែកបញ្ញាស្មារតី ក៏ដូចជាផ្នែកសម្ភារៈ តាំងពីតូចក្រូចឆ្មាររហូតដល់ដឹងក្ដីពេញរូបពេញរាង ដោយមិនខ្លាចហត់នឿយ ដែលលោកបាន និងកំពុងបានខិតខំគ្រប់បែបយ៉ាង ដើម្បីឲ្យកូនបានសិក្សារៀនសូត្ររហូតដល់សព្វថ្ងៃ។ ប្រសិនបើគ្មានលោកទាំងពីរផ្ដល់ និងលើកកម្លាំងចិត្តទេ នោះយើងក៏មិនអាចឈានជើងមកដល់ថ្ងៃនេះដែរ។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីសមត្ថភាពក្នុងការផ្ទេរនូវចំណេះដឹងយ៉ាងច្រើនឲ្យយើងខ្ញុំក្នុងរយៈពេល ០៤ (បួន) ឆ្នាំ កន្លងទៅនេះ ជាពិសេសពួកយើងទទួលបាននូវការតម្រង់ទិសមួយធ្វើឲ្យពួកយើងក្លាយជាសិស្សល្អ និងពលរដ្ឋល្អសម្រាប់សង្គមជាតិ។

លោកស្រីសាស្ត្រាចារ្យ **ម៉ួយ ធីតា** ដែលបានខិតខំដឹកនាំ បង្ហាត់បង្ហាញនូវគំនិត ក៏ដូចជាវិធីសាស្ត្រល្អៗទាក់ទងនឹងប្រធានបទ រួមទាំងបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកស្រី តាំងពីដើមរហូតដល់បញ្ចប់ការស្រាវជ្រាវមួយនេះ ពិតជាមិនអាចមានអត្ថិភាពបានឡើយ ប្រសិនបើគ្មានការជ្រោមជ្រែងពីលោកស្រី។

**រៀមច្បង មិត្តរួមជំនាន់ទាំងអស់** ដែលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្ដល់ជាគំនិតល្អៗ ជួយផ្ដល់ជាឯកសារ ជួយបំពេញនូវចំណុចខ្វះខាត ថែមទាំងជួយពិនិត្យ និងកែលំអនូវអក្ខរាវិរុទ្ធ ព្រមទាំងការប្រើប្រាស់ពាក្យពេចន៍ ធ្វើយ៉ាងណាឲ្យការរៀបរៀងឡើងនូវសារណាមួយនេះកាន់តែប្រសើរឡើង។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមធ្វើការគោរពអរគុណ និងដឹងគុណម្ដងទៀតដល់ អ្នកមានគុណដែលបានរៀបរាប់ខាងលើ សូមបានប្រកបតែនឹងពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងជួបតែសេចក្ដីសុខ សេចក្ដីចម្រើន សុភមង្គល សុខភាពល្អ ប្រកបដោយភាពជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# **អារម្ភកថា**

ក្រោយពីបានធ្វើការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមក ដោយបានខិតខំប្រឹងប្រែងក្នុងការរៀនសូត្រដើម្បីទទួលបាននូវចំណេះដឹងពីលោក លោកស្រី សាស្រ្តាចារ្យនៅក្នុងសាកលវិទ្យាល័យ យើងខ្ញុំទាំងពីររូបត្រូវបានលើកទឹកចិត្ត និងទទួលបានការអនុញ្ញាតពីសាកលវិទ្យាល័យ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សា ក្រោមប្រធានបទ "**ប្រព័ន្ធទ្រព្យសម្បត្តិប្តី ប្រពន្ធ នៅក្រោមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧**" នេះឡើង។

ប្រធានបទមួយនេះ គឺកើតចេញពីចម្ងល់ និងការចង់ដឹងឲ្យកាន់តែស៊ីជម្រៅរបស់យើងខ្ញុំទៅលើផ្នែកទ្រព្យសម្បត្តិប្តីប្រពន្ធ។ កិច្ចការស្រាវជ្រាវមួយនេះ ផ្តោតសំខាន់ទៅលើលក្ខណៈ និងវិធីសាស្រ្តក្នុងការគ្រប់គ្រង ចាត់ចែង ក៏ដូចជាការបែងចែកទ្រព្យសម្បត្តិរបស់ប្តី ប្រពន្ធ ព្រមទាំងនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ដូចដែមានក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ដែលជាច្បាប់កំពុងមានអានុភាពអនុវត្តនេះបានបញ្ញត្តិ។ លើសពីនេះទៅទៀត សារណាមួយនេះអាចលេចចេញជារូបរាងឡើងក៏ដោយសារតែមានការជួយជ្រោមជ្រែង ណែនាំ តម្រង់ទិស ពីសំណាក់លោកស្រីសាស្រ្តាចារ្យ **ម៉ួយ ធីតា** ដែលលោកស្រីបានចំណាយពេលដ៏មានតម្លៃក្នុងការចែករំលែកនូវចំណេះដឹងបទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិដល់យើងខ្ញុំ។

ឆ្លៀតក្នុងឱកាសនេះដែរថ្វីបើយើងខ្ញុំបានធ្វើការពិនិត្យ ផ្ទៀងផ្ទាត់រួចមកហើយក្តី ក៏គង់តែមាននូវកំហុសខុសឆ្គងណាមួយដែលពុំអាចជៀសបាន។ ដូច្នេះ យើងខ្ញុំសូមធ្វើការអភ័យទោសនូវរាល់កំហុសដោយអចេតនាដែលអាចកើតមានឡើងនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះហើយក៏យើងខ្ញុំក៏រង់ចាំទទួលនូវការរិះគន់ និងការកែលម្អក្នុងន័យស្ថាបនា ដើម្បីអាចធ្វើឲ្យស្នាដៃបន្តបន្ទាប់ទៀតកាន់តែមាននូវភាពល្អប្រសើរឡើង។

ជាចុងបញ្ចប់ ក្នុងនាមយើងខ្ញុំជាអ្នករៀបរៀងសារណានេះ ក៏សង្ឃឹមថាឯកសារមួយនេះនឹងក្លាយជាប្រយោជន៍ និងជាវិភាគទាន ព្រមទាំងផ្តល់ជាចំណេះដឹងបន្ថែម សម្រាប់ជាគន្លឹះ និងជាឯកសារជំនួយស្មារតីដល់ប្អូនៗជំនាន់ក្រោយៗទៀតអាចធ្វើការសិក្សាស្រាវជ្រាវបន្ថែមបន្តបាន។ ហើយយើងខ្ញុំទាំងពីររូប ក៏សូមជូនពរដល់លោក លោកស្រី ដែលកំពុងអានសៀវភៅមួយនេះ សូមជួបប្រទះតែនូវពុទ្ធពរ ទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

*ទំព័រ*

**សេចក្តីផ្តើម** ........ **១**

**ជំពូកទី១**
**ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា**

**ផ្នែកទី១ ការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា** ........ **៥**
**កថាខណ្ឌទី១ លក្ខខណ្ឌគ្រឹះនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា** ........ **៥**
១.១. ការព្រមព្រៀងរបស់សហព័ទ្ធទាំងសងខាង ........ ៥
១.២. ខ្លឹមសារនៃកិច្ចសន្យា ........ ៦
**កថាខណ្ឌទី២ លក្ខខណ្ឌទម្រង់នៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា** ........ **៩**
២.១. កិច្ចសន្យាជាលាយលក្ខណ៍អក្សរ ........ ៩
២.២. លក្ខខណ្ឌតតាំងនឹងតតិយជនតាមរយៈការចុះបញ្ជីកិច្ចសន្យាប្តីប្រពន្ធ ........ ១០
**ផ្នែកទី២ នីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តី ប្រពន្ធ** ........ **១០**
**កថាខណ្ឌទី១ ពាក្យសុំនៃការចុះបញ្ជី** ........ **១០**
១.១. ទម្រង់នៃពាក្យសុំ ........ ១០
១.២. ទម្រង់លិខិត ........ ១១
១.៣. អត្តសញ្ញាណសហព័ទ្ធ ........ ១១
១.៤. កម្មវត្ថុនៃពាក្យសុំ ........ ១២
**កថាខណ្ឌទី២ របៀបនៃការចុះបញ្ជី** ........ **១២**
**កថាខណ្ឌទី៣ ការចេញលិខិតបញ្ជាក់** ........ **១៤**
៣.១. អ្នកសុំចេញលិខិតបញ្ជាក់ ........ ១៤
៣.២. នីតិវិធីចេញលិខិតបញ្ជាក់ ........ ១៤
**ផ្នែកទី៣ អានុភាពនៃការចុះបញ្ជី** ........ **១៥**
**កថាខណ្ឌទី១ អានុភាពចំពោះសហព័ទ្ធនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ** ........ **១៥**
**កថាខណ្ឌទី២ អានុភាពចំពោះតតិយជន** ........ **១៦**
**ផ្នែកទី៤ ផលប្រយោជន៍នៃការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា** ........ **១៧**
**កថាខណ្ឌទី១. ការពារផលប្រយោជន៍របស់សហព័ទ្ធ** ........ **១៧**
**កថាខណ្ឌទី២ កំណត់លើទំនាក់ទំនងភាគព្វកិច្ច និងសិទ្ធិលើបំណុល** ........ **១៧**
**កថាខណ្ឌទី៣ កំណត់អំពីសិទ្ធិគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ** ........ **១៧**
**កថាខណ្ឌទី៤ សម្រួលនីតិវិធីដោះស្រាយរបស់តុលាការ** ........ **១៨**

## ជំពូកទី២
## ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមច្បាប់កំណត់


**ផ្នែកទី១ សច្ចធារណ៍នីត្យានុកូល** ............ **១៩**
**កថាខណ្ឌទី១ លក្ខខណ្ឌដែលនាំឲ្យមានប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមច្បាប់កំណត់** ............ **១៩**
**កថាខណ្ឌទី២ ការកំណត់គុណវឌ្ឍន៍នៃទ្រព្យ (ប្រភេទនៃទ្រព្យ)** ............ **២១**
២.១. ទ្រព្យសម្បត្តិដោយឡែក ............ ២១
២.២ ទ្រព្យសម្បត្តិរួម ............ ២៦
**ផ្នែកទី២ អានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមច្បាប់កំណត់** ............ **២៨**
**កថាខណ្ឌទី១ ចំណាត់ការទ្រព្យសម្បត្តិ** ............ **២៨**
១.១. ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរួម ............ ២៩
១.២. ការអាស្រ័យនៅទ្រព្យដោយឡែករបស់សហព័ទ្ធ ............ ៣០
១.៣. ការចាត់ចែងទ្រព្យសម្បត្តិរួម ............ ៣១
**កថាខណ្ឌទី២ ការទទួលខុសត្រូវចំពោះភាគពូកិច្ច** ............ **៣២**
២.១. ការទទួលខុសត្រូវលើបំណុលរួម ............ ៣៣
២.២. ការទទួលខុសត្រូវលើបំណុលដោយឡែក ............ ៣៤
**ផ្នែកទី៣ ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ** ............ **៣៥**
**កថាខណ្ឌទី១ ការបែងចែកទ្រព្យសម្បត្តិរួមតាមការព្រមព្រៀងគ្នា** ............ **៣៥**
**កថាខណ្ឌទី២ ការបែងចែកទ្រព្យសម្បត្តិរួមតាមសេចក្ដីសម្រេចរបស់តុលាការ** .... **៣៦**
**សេចក្ដីសន្និដ្ឋាន** ............ **៣៧**
**អនុសាសន៍** ............ **៣៩**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

អាពាហ៍ពិពាហ៍ គឺជាចំណងគតិយុត្តិមួយរវាងបុរស និងនារីដែលបានរួមរស់ជាមួយគ្នា ជាប្តីប្រពន្ធស្របច្បាប់ ដែលត្រូវបំពេញគ្រប់លក្ខខណ្ឌ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ ក្នុងទំហំដែលច្បាប់បានកំណត់។[១] តាមរយៈការរៀបអាពាហ៍ពិពាហ៍នេះហើយ ទើបបុរស និងនារីនោះបានភ្ជាប់នូវទំនាក់ទំនងញាតិនឹងគ្នាដោយស្របច្បាប់[២] ក្រោមរូបភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍។ ដូច្នេះ នៅពេលដែលបុគ្គលពីរនាក់សម្រេចចិត្តរៀបការជាមួយគ្នាហើយ ការកសាងអនាគតជាមួយគ្នា បានបង្កើតឲ្យមាននូវចំណងគតិយុត្តជាច្រើនជាមួយគ្នា មានទាំងកូនរួមគ្នា មានទាំងសេដ្ឋកិច្ចរួមគ្នាដើម។ ដោយមើលឃើញពីបញ្ហាជាច្រើនដែលភាគច្រើនគឺកើតចេញពីទំនាក់ទំនងទ្រព្យសម្បត្តិម្ល៉ោះហើយជាការសម្រួលដល់ការរស់នៅរបស់ប្រជាជនកម្ពុជា ទើបក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានធ្វើការកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចមួយចំនួន ដើម្បីជាកិច្ចប្រតិបត្តិការនៃការគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ។

ក្រមរដ្ឋប្បវេណីបានកំណត់ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ជាពីរប្រព័ន្ធ គឺប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ឬហៅថា កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់។ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា[៣] ចង់សំដៅទៅលើការកំណត់យកទ្រព្យសម្បត្តិរវាងសហព័ទ្ធទាំងសងខាងដែលក្នុងខ្លឹមសារនៃកិច្ចសន្យានោះនឹងចែងច្បាស់អំពីទ្រព្យកម្រិតណាជាទ្រព្យរួម និងទ្រព្យកម្រិតណាជាទ្រព្យដោយឡែក ហើយនឹងធ្វើឡើងទៅតាមការព្រមព្រៀងរបស់ភាគីទាំងសងខាង។ កំឡុងពេលនៃការបង្កើតនូវកិច្ចសន្យានេះផងដែរ ច្បាប់ក៏បានកំណត់យ៉ាងច្បាស់ថា សហព័ទ្ធអាចធ្វើវាឡើងនៅមុន ឬក្រោយអាពាហ៍ពិពាហ៍ក៏បាន[៤] ដរាបណាអនុវត្តទៅតាមលក្ខខណ្ឌ បែបបទនៃការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាឲ្យបានត្រឹមត្រូវតាមច្បាប់។ គោលបំណងដែលជាប្រយោជន៍ចំបងសម្រាប់សហព័ទ្ធក្នុងការបង្កើតឡើងនូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ គឺចង់សំដៅឲ្យច្បាប់ធ្វើការការពារនូវទ្រព្យសម្បត្តិរបស់សហព័ទ្ធទាំងសងខាងក្នុងការអះអាងជាមួយតតិយជន ព្រមទាំងចង់ឲ្យមានការបែងចែកឲ្យដាច់ស្រឡះ និងច្បាស់លាស់ ជៀសវាងនូវវិវាទណាមួយដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់ភាគីជាប្តី និងភាគីជាប្រពន្ធ។[៥] ម៉្យាងទៀត ក៏ដើម្បីបង្ការនូវការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ ដើម្បីឆ្លុះបញ្ចាំង

---

[១] ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៤៨ ដល់ មាត្រា ៩៥២។

[២] ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៣៨។

[៣] ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦៩ និង មាត្រា ៩៧០។

[៤] ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា មាត្រា៩៦៩ កថាខណ្ឌទី១ វាក្យខណ្ឌ១។

[៥] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ៨១.កយ.ប្រក/១៣, ០៩ សីហា ២០១៣, ប្រការ២។

ឲ្យឃើញនូវទ្រព្យរួម និងទ្រព្យដោយឡែករបស់សហព័ទ្ធ ដែលងាយស្រួលដល់ការសម្រេចក្តីរបស់តុលាការដោយផ្អែកតាមកិច្ចសន្យានោះជាអាទិ៍។ ប៉ុន្តែ សម្រាប់សហព័ទ្ធដែលមិនមានការគិតដល់ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិនេះនោះទេ គេអាចអនុវត្តនូវប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់ដូចដែលក្រមរដ្ឋប្បវេណីដែលបញ្ញត្តិយ៉ាងលម្អិតដោយស្វ័យប្រវត្តិ អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធទាំងសងខាងក្នុងការទទួលខុសត្រូវក្នុងនាមជាប្តី ឬប្រពន្ធ។[៦] ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់[៧] គឺការប្រកាន់យកនូវវិធីសាស្ត្រនៃការប្រើប្រាស់ទ្រព្យសម្បត្តិរបស់សហព័ទ្ធទាំងសងខាងតាមការកំណត់របស់ច្បាប់ មានន័យថាសហព័ទ្ធនឹងចាត់ចែង ប្រើប្រាស់ និងគ្រប់គ្រងនូវទ្រព្យសម្បត្តិទាំងនោះ (ទាំងទ្រព្យរួម និងទ្រព្យដោយឡែក) ក្នុងទំហំមួយដែលច្បាប់បានបញ្ញត្តិ។ គោលបំណងនៃការកំណត់ឲ្យមានប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់នេះ គឺដោយសារ តែច្បាប់ចង់រក្សាឲ្យមាននូវការទទួលខុសត្រូវ រវាងប្តីប្រពន្ធ ឲ្យស្របទៅនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ដោយការស្រលាញ់គ្នា ថែរក្សា និងចេះអធ្យាស្រ័យគ្នាទៅវិញទៅមក បើទោះបីជាសហព័ទ្ធពុំបានគិតគូរ ឬស្តែងឲ្យឃើញតាមរយៈកិច្ចសន្យាទ្រព្យសម្បត្តិដូចប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាក៏ដោយ។ ហេតុនេះទើបមានសំនួរមួយចំនួនចោទសួរថា តើប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់ អាចអនុវត្តទៅបានត្រូវឆ្លងកាត់នូវលក្ខខណ្ឌអ្វីខ្លះ? ក្រៅពីនេះទៅទៀត នៅក្នុងការអនុវត្តជាក់ស្តែងបានផ្តល់នូវផលប្រយោជន៍អ្វីខ្លះ? ថាតើត្រូវបានប្រឈមមុខនឹងបញ្ហាអ្វីខ្លះ?

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើនេះ យើងខ្ញុំបានធ្វើការស្រាវជ្រាវ និងជ្រើសរើសឯកសារជាមូលដ្ឋានមួយចំនួនដើម្បីសរសេរសារណានេះឡើង។ ដែលឯកសារទាំងនោះរួមមាន រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (២៤ កញ្ញា ១៩៩៣) ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (២១ ធ្នូ ២០០៧) សេចក្តីប្រកាសស្តីពីនីតិវិធីចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ (០៩ សីហា ២០១៣) សេចក្តីកំណត់នៃក្រមរដ្ឋប្បវេណី ភាគទី៥សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគទី១ និងភាគីទី២ ព្រមទាំងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី (៣១ ឧសភា ២០១១)។

ជាបន្តទៅទៀតនេះ នៅក្នុងសារណាមួយនេះ នឹងបង្ហាញអំពីសញ្ញាណរបស់ខ្លឹមសារនៃប្រធានបទ ដូចតទៅះ

ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា (ជំពូកទី១) ព្រមទាំងលក្ខខណ្ឌបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា (ផ្នែកទី១) នីតិវិធីនៃការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ច

---

[៦] ណូមីរ៉ា គូយ៉ូហ៊ីរ៉ូ, *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី*, (ភ្នំពេញះ ២០១៤), ១៣៩ និង ១៤០។

[៧] ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧១ ដល់ មាត្រា ៩៧៧។

សន្យា (ផ្នែកទី២) អានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យានេះ (ផ្នែកទី៣) និងផលប្រយោជន៍នៃការ បង្កើតប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ផ្នែកទី៤)។ ម៉្យាងវិញទៀត ឯកសារមេរៀនមួយនេះក៏ នឹងបកស្រាយបន្ថែមអំពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់ (ជំពូកទី២) យ៉ាងក្បោះក្បាយ រួមមានភាពត្រឹមត្រូវតាមច្បាប់ ពោលគឺសច្ចធារណ៍នីត្យានុកូល (ផ្នែកទី១) អានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់នេះ (ផ្នែកទី២) និងការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ (ផ្នែកទី៣)។

# ជំពូកទី១

# ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

# តាមកិច្ចសន្យា

# ជំពូកទី១
# ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា

សញ្ញាណនៃការអំពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យានេះ គឺទើបតែឃើញមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នេះតែប៉ុណ្ណោះ[៨] ដែលសញ្ញាណនៃប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធតាមកិច្ចសន្យានេះ ក៏ឃើញមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនឆ្នាំ ១៨៩៦ ផងដែរ ហើយបញ្ញត្តិចាប់ពីមាត្រា ៧៥៥ ដល់មាត្រា ៧៥៩។ ដោយសារតែក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នេះ ត្រូវបានតាក់តែងឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ទើបសញ្ញាណនៃការកំណត់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ត្រូវបានដាក់បញ្ចូលនៅក្នុងក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ របស់កម្ពុជា គឺមាននៅចែងត្រង់មាត្រា ៩៦៩ ដល់មាត្រា ៩៧០។ បើផ្អែកតាមតែបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ត្រឹមតែ ២ មាត្រានេះ គឺពុំគ្រប់គ្រាន់ទេសម្រាប់ការអនុវត្តនោះឡើយ ពីព្រោះថាមាត្រាទាំង ២ នេះ មិនបានបង្ហាញអំពីបែបបទ នីតិវិធី និងទម្រង់នៃការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាឡើយ។ សម្រាប់ការកំណត់អំពីបែបបទ នីតិវិធី និងទម្រង់នៃការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា គឺត្រូវបានបញ្ញត្តិរបស់ប្រកាសរបស់ក្រសួងយុត្តិធម៌ នោះគឺប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នាថ្ងៃទី០៩ សីហា ២០១៣ នេះឡើង។[៩] ក្រោមការចង្អុលបង្ហាញនៃមាត្រា ២៦ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ ក៏បានបញ្ជាក់ និងប្រគល់សមត្ថកិច្ចឲ្យក្រសួងយុត្តិធម៌មានសមត្ថកិច្ចទៅលើការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ។ តួយ៉ាងនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ដើម្បីជ្រើសរើសនូវវិធីនេះបានទាល់តែត្រូវធ្វើការស្វែងយល់ឲ្យបានច្បាស់នូវការបង្កើតនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា (ផ្នែកទី១) នីតិវិធីនៃការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ (ផ្នែកទី២) និងអានុភាពដែលកើតចេញពីការចុះបញ្ជីនៃប្រព័ន្ធនេះ (ផ្នែកទី៣) ព្រមទាំងផលប្រយោជន៍នៃការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ (ផ្នែកទី៤) ជាមុនសិន។

## ផ្នែកទី១ ការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា

នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ ឯកឧត្តម **អង្គ វង្សវឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងសុន្ទរកថានៅក្នុងចំណាប់អារម្មណ៍របស់ខ្លួនថា នៅក្នុងទំនាក់ទំនង

---

[៨] លោកជំទាវ ចាន់ សុទ្ធាវី (រដ្ឋលេខាធិការក្រសួងយុត្តិធម៌), http://www.youtube.com/watch?v=9AXRVUBS2SA (ចូលទស្សនាថ្ងៃទី ៥ មិថុនា ២០១៨)។

[៩] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា ២៧។

រវាងបុគ្គល និងបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ ព្រមទាំងបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដែលមានធនធានទ្រព្យសម្បត្តិ គប្បីមានការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីសិទ្ធិលើទ្រព្យសម្បត្តិ ថាតើទ្រព្យសម្បត្តិណាជាទ្រព្យរួម? ទ្រព្យណាទៀតជាទ្រព្យដោយឡែក ឬទ្រព្យផ្តាច់មុខ? របស់ភាគីណាមួយ។[១០] ជាមួយនឹងប្រសាសន៍របស់ឯកឧត្តមរដ្ឋមន្រ្តីខាងលើ បានសេចក្តីថាការជ្រើសយកនូវវិធីនៃការកំណត់ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធតាមកិច្ចសន្យា គឺជាប្រព័ន្ធមួយក្នុងការជួយសម្រួលដល់ការកំណត់ឲ្យបានច្បាស់លាស់នៃទ្រព្យសម្បត្តិរបស់សហព័ទ្ធ។ យ៉ាងណាមិញផ្តោតទៅលើទិដ្ឋភាពនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក៏បានកំណត់បង្ហាញឲ្យឃើញយ៉ាងច្បាស់ថាបែបបទនៃការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា តម្រូវឲ្យគោរពនូវលក្ខខណ្ឌ ២ ធំៗរួមមានដូចជាលក្ខខណ្ឌគ្រឹះនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា (កថាខណ្ឌទី១) និងលក្ខខណ្ឌទម្រង់នៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា (កថាខណ្ឌទី២) ជាមុនសិន។

### កថាខណ្ឌទី១ លក្ខខណ្ឌគ្រឹះនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា

ចំពោះលក្ខខណ្ឌគ្រឹះនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យានេះ សំដៅទៅលើការព្រមព្រៀងរបស់សហព័ទ្ធទាំងសងខាង (១.១.) និងខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (១.២.)។

#### ១.១. ការព្រមព្រៀងរបស់សហព័ទ្ធទាំងសងខាង

ជាគោលការណ៍ នៅក្នុងបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានប្រកាន់យកនូវគោលការណ៍ស្វ័យភាពរបស់បុគ្គលឯកជន[១១] បានសេចក្តីថាជាការគោរពនូវការបង្ហាញឆន្ទៈរបស់ភាគីជាចម្បងនៅក្នុងកិច្ចសន្យា។ ចំពោះការព្រមព្រៀងលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺត្រូវតែប្រាកដថា ការបង្ហាញឆន្ទៈរបស់សហព័ទ្ធគឺពុំមានវិការៈណាមួយដែលអាចកើតមានឡើង ឬផ្ទុយទៅនឹងសុពលភាពនៃកិច្ចសន្យានោះទេ។[១២] ម្យ៉ាងវិញទៀត ការបង្កើតនូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះទៀតសោត អាចធ្វើឡើងនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ឬក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍នេះផងដែរ។[១៣]

#### ១.២. ខ្លឹមសារនៃកិច្ចសន្យា

ខ្លឹមសារនៃកិច្ចសន្យា គឺជាលក្ខខណ្ឌមួយដ៏សំខាន់មួយមុននឹងឈានដល់ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ បើទោះបីជាក្រមរដ្ឋប្បវេណីបានទុកលទ្ធភាពឲ្យប្តីប្រពន្ធនៅក្នុងការ

[១០] ចំណាប់អារម្មណ៍របស់ ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្រ្តីក្រសួងយុត្តិធម៌, ០៩ សីហា ២០១៣។

[១១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣។

[១២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៤៥ ដល់ មាត្រា ៣៥៥។

[១៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៦៩។

សម្រេចចិត្តនឹងព្រមព្រៀងគ្នាយ៉ាងណាក៏ដោយ ប៉ុន្តែរាល់ការព្រមព្រៀងគ្នា និងការចែងនៅក្នុងកិច្ចសន្យារបស់សហព័ទ្ធនោះ គឺត្រូវតែគិតទៅលើថាតើវាមានផលប៉ះពាល់ដល់សិទ្ធិសហព័ទ្ធដែលច្បាប់បញ្ញត្តិផ្តល់ឲ្យដែរឬទេ? សហព័ទ្ធមានសិទ្ធិសម្រេចទៅលើខ្លឹមសារនៃការបែងចែកទ្រព្យសម្បត្តិរបស់ពួកគេទាំងទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក ក្នុងទំហំមួយដែលពុំប៉ះពាល់ដល់ប្រយោជន៍តតិយជន ឬក្នុងន័យកេងប្រវ័ញ្ចលើសហព័ទ្ធណាម្ខាងទាំងស្រុង។ ដូច្នោះ ដើម្បីការពារនូវការប៉ះពាល់ទាំងអស់នេះ ទើបក្រមរដ្ឋប្បវេណីបានចែងយ៉ាងច្បាស់លាស់នូវចំណុច ២ សំខាន់ៗ ដូចជាកិច្ចសន្យាប្តីប្រពន្ធមិនត្រូវបានចែងផ្ទុយពីបទប្បញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច (១.២.១) និង/ឬក៏ផ្ទុយទៅនឹងបទប្បញ្ញត្តិស្តីពីភាគបម្រុងបានឡើយ (១.២.២)។

### ១.២.១, ខ្លឹមសារមិនឲ្យផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច

សិទ្ធិទាមទារអាហារកាតព្វកិច្ច គឺជាសិទ្ធិទាមទារផ្តាច់មុខមួយរបស់បុគ្គលដែលត្រូវការជាចាំបាច់នូវអាហារកាតព្វកិច្ច ហើយកម្មវត្ថុនៃអាហារកាតព្វកិច្ចនេះ គឺពុំអាចធ្វើអនុប្បទាន ឬប្រទានកម្ម ឬដាក់ប្រាតិភោគសម្រាប់តតិយជន ឬជំនួញផ្សេងៗទៀតបានឡើយ។[១៤] ម្យ៉ាងទៀត អាហារកាតព្វកិច្ច គឺជាកិច្ចដែលធ្វើតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការឲ្យបុគ្គលម្នាក់ ឬច្រើននាក់ ផ្តល់នូវប្រាក់ ឬទ្រព្យសម្បត្តិ ក្នុងគោលបំណងផ្គត់ផ្គង់ដល់ជីវភាព អ្នកដែលស្ថិតនៅក្នុងរង្វង់ទំនាក់ទំនងញាតិនឹងគ្នា។[១៥] ហេតុដូចនេះហើយ ចំពោះខ្លឹមសារនៃកិច្ចសន្យាគឺមិនត្រូវចែងឲ្យពីផ្ទុយពីអាហារកាតព្វកិច្ចនេះបានទេ។

ក្នុងក្រមរដ្ឋប្បវេណីក្នុងបទបញ្ញត្តិដែលបានចែងអំពីអាហារកាតព្វកិច្ច បានបញ្ញត្តិអំពីទំហំនិង លំដាប់នៃញាតិដែលមានករណីយកិច្ចត្រូវផ្គត់ផ្គងអាហារកាតព្វកិច្ច ការកំណត់អំពីអ្នកផ្គត់ផ្គងអាហារកាតព្វកិច្ច និងអ្នកទទួលអាហារកាតព្វកិច្ច ព្រមទាំងការកម្រិត និងរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច រួមទាំងការផ្លាស់ប្តូរការលុបចោលទំនាក់ទំនងអាហារកាតព្វកិច្ច ហើយជាពិសេសគឺជាមានការបញ្ញត្តិមួយ ដែលសំដៅនូវការហាមឃាត់ ចំពោះការចាត់ចែងសិទ្ធិទាមទារអាហារកាតព្វកិច្ចនេះ។ ផ្ទុយពីទៅទៀតនោះ ក្នុងការបកស្រាយរបស់សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី[១៦] បានកំណត់ពីអាហារកាតព្វកិច្ចចំពោះញាតិ លើកលែងចំពោះអាហារកាតព្វកិច្ចរវាងឪពុកម្តាយ ចំពោះកូនដែលជាអនីតិជន និងរវាងសហព័ទ្ធចំពោះគ្នា[១៧] ហេតុនេះបញ្ញត្តិដែល

---

[១៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា១១៩៥។

[១៥] សន្ទានុក្រមនៃក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខ២០២, ទំព័រទី២៨។

[១៦] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៥ គន្ថីទី៧*, (ភ្នំពេញ៖ ២០១០), ១៧៥។

[១៧] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៥*, (ភ្នំពេញ៖ ២០១០), ៣០។

ការពារលើសិទ្ធិទាមទារអាហារកាតព្វកិច្ចនេះមានចែងនៅក្នុងមាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលស្តីពីការសង្គ្រោះកិច្ចសន្យាគ្នាទៅវិញទៅមករវាងប្តីប្រពន្ធ។[១៨]

បើក្រឡេកទៅមើលនូវខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធវិញ ការចែងណាមួយនៅក្នុងកិច្ចសន្យាមិនអាចមានសុពលភាពបានទេ ប្រសិនបើការចែងនៃកិច្ចសន្យានោះ មានភាពរាំងស្ទះ ឬបំបិទនូវសិទ្ធិទទួលបានអាហារកាតព្វកិច្ចពីសហព័ទ្ធម្ខាងទៀត។ ការចែងនៅក្នុងកិច្ចសន្យាសម្បត្តិតាមរយៈការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺមិនអាចឲ្យមានការអនុញ្ញាតឲ្យប្រើប្រាស់សិទ្ធិទាមទារអាហារកាតព្វកិច្ច ធ្វើជាកម្មវត្ថុនៃកិច្ចសន្យា ពីព្រោះអាហារកាតព្វកិច្ច គឺជាជំនួយហិរញ្ញវត្ថុដល់បុគ្គលដែលមិនបានទ្រទ្រង់ជីវភាពដោយសមត្ថភាពខ្លួនឯងបានដោយឡែកសិទ្ធិនៅក្នុងការទាមទារអាហារកាតព្វកិច្ចនៅទីនេះ បានសេចក្តីថាជាសិទ្ធិទាមទារអាហារកាតព្វកិច្ចរវាងសហព័ទ្ធដែលមានសិទ្ធិនេះដោយការកើតចេញពីការរៀបអាពាហ៍ពិពាហ៍។អាស្រ័យហេតុនេះ ទើបមានការកម្រិតនូវខ្លឹមសារដែលការពារនូវការប៉ះពាល់សិទ្ធិទាមទារនូវអាហារកាតព្វកិច្ច រវាងប្តីប្រពន្ធនេះឡើង ហេតុផលគឺដើម្បីធានានូវភាពយុត្តិធម៌ និងសុវត្ថិភាពនៃជីវភាពរស់នៅរបស់ប្តី និងប្រពន្ធ។

ជាឧទាហរណ៍៖ លោក **ដារណ្ណ** មានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់ឪពុកជរារបស់គាត់នូវទឹកប្រាក់ចំនួន ១០០ ដុល្លារអាមេរិក នៅជារៀងរាល់ក្នុងមួយខែម្តង។ យ៉ាងណាមិញក្រោយពីរូបលោកបានរៀបអាពាហ៍ពិពាហ៍រួចមក លោក **ដារណ្ណ** បានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាមួយនឹងលោកស្រី **ដានី** ដែលមានខ្លឹមសារថា៖ "រាល់ការចំណាយដែលមានទឹកប្រាក់ចាប់ពី ៥០ ដុល្លារអាមេរិក ឡើងទៅ គឺត្រូវតែមានការព្រមព្រៀងគ្នាពីសហព័ទ្ធទាំងសងខាង"។

ចំពោះខ្លឹមសារដែលចែងបែបនេះ គឺបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិក្នុងការទាមទារកាតព្វកិច្ចរបស់ឪពុកដារណ្ណ។ ម្យ៉ាងទៀតនៅត្រង់ចំណុចនេះ គឺកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះមិនមានអានុភាពហាមឃាត់លោកដារណ្ណមិនឲ្យបង់ប្រាក់ចំនួន ១០០ ដុល្លារអាមេរិក ចំពោះឪពុកគាត់បានឡើយ ពីព្រោះថាការចែងនៅក្នុងកិច្ចសន្យាបែបនេះរបស់លោក **ដារណ្ណ** និងលោកស្រី **ដានី** គឺបានផ្ទុយនឹងបទប្បញ្ញត្តិនៃអាហារកាតព្វកិច្ចហើយ។[១៩]

[១៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៦។

[១៩] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត,*សៀវភៅជំនួយស្មារតី, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, (ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១៧), ៣៤៩។

### ១.២.២. ខ្លឹមសារមិនឲ្យផ្ទុយនឹងបញ្ញត្តិស្តីពីភាគបម្រុង

អនុលោមតាមមាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណីដដែលបានបញ្ញត្តិកម្រិតពីការបែងចែកក្នុងកិច្ចសន្យាប្តីប្រពន្ធមិនឲ្យផ្ទុយពីការភាគបម្រុងផងដែរ ដោយហេតុថាភាគបម្រុង គឺជារបបមួយដែលធានាដល់សិទ្ធិជាមូលដ្ឋានមួយភាគនៃចំណែកមតិក ដែលច្បាប់បានកំណត់ស្តីពីសន្តតិជនដែលកំណត់ដោយច្បាប់។ ម្យ៉ាងទៀតសហព័ទ្ធនៃមតកជន គឺជាអ្នកមានសិទ្ធិលើភាគបម្រុង ហើយប្រសិនបើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមួយបានចែងឲ្យមានការលះបង់សិទ្ធិលើភាគបម្រុងទាក់ទងនឹងសន្តតិកម្មនេះ គឺជាការបំពានលើបញ្ញត្តិស្តីពីសិទ្ធិលើភាគបម្រុងរបស់សហព័ទ្ធហើយ។

បន្ថែមពីលើនេះទៅទៀត ការចែងនៃកិច្ចសន្យាប្តីប្រពន្ធ គឺត្រូវកំណត់ដោយឲ្យមានចំណែកស្មើៗគ្នារវាងប្តីប្រពន្ធ និងសន្តតិជនផ្សេងៗទៀត។

ឧទាហរណ៍ថា៖ លោក **សំខាន់** បានធ្វើកិច្ចសន្យាប្តីប្រពន្ធជាមួយភរិយារបស់គាត់ឈ្មោះ **ចិន្តា** ដែលមានខ្លឹមសារតទៅ៖ នៅពេលដែលសហព័ទ្ធណាម្នាក់ស្លាប់បាត់បង់ជីវិតមុនសហព័ទ្ធដែលរស់ មានសិទ្ធិទទួលបានទ្រព្យសម្បត្តិទាំងអស់របស់សហព័ទ្ធដែលបានស្លាប់បាត់បង់ជីវិត។[២០]

ឧបមាថា៖ លោក **សំខាន់** មានកូនចំនួន ២ នាក់ មុនពេលដែលគាត់មករៀបអាពាហ៍ពិពាហ៍ជាមួយនឹង លោកស្រី **ចិន្តា** ហើយឥឡូវនេះលោក **សំខាន់** ក៏បានស្លាប់បាត់បង់ជីវិត។ រួមសេចក្តីមក បើសិនជាត្រូវអនុវត្តតាមកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺទ្រព្យសម្បត្តិទាំងអស់របស់លោក **សំខាន់** នឹងត្រូវផ្ទេរទៅឲ្យលោកស្រី **ចិន្តា** នៅពេលនោះ គឺកូនទាំងពីររបស់លោក **សំខាន់** មិនអាចទទួលបានអ្វីទាំងអស់។ ត្រង់ចំណុចនេះ គឺផ្ទុយទាំងស្រុងទៅនឹងបទប្បបញ្ញត្តិនៃក្រមរដ្ឋប្បវេណីទាក់ទងនឹងភាគបម្រុង។ អាស្រ័យហេតុនេះ ខ្លឹមសារនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាខាងលើនោះ គឺមិនអាចនឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិទាមទារភាគបម្រុងនៃកូនទាំងពីររបស់លោក **សំខាន់** បានឡើយ។ និយាយម្យ៉ាងវិញទៀតថា ទោះបីជាមានកិច្ចសន្យាបែបនេះក៏ដោយ ក៏កូនទាំងពីរនាក់របស់លោក **សំខាន់** នៅតែអាចទាមទារឲ្យគោរពសិទ្ធិលើភាគបម្រុងរបស់ពួកគេបានជាដដែល ពោលគឺទ្រព្យសម្បត្តិមួយភាគដែលជាមរតករបស់លោក **សំខាន់** នឹងត្រូវប្រគល់ឲ្យទៅកូនទាំងពីរ នាក់របស់លោក **សំខាន់** តាមការទាមទារ។

សរុបសេចក្តីមក នៅរាល់ការចែងបំពានទាំងឡាយរបស់ភាគី ជាប្តីក្តី ជាប្រពន្ធក្តីនៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មិនថាជាការប៉ះពាល់ដល់បទប្បញ្ញត្តិស្តីពីអាហារកាតព្វកិច្ច មិនថាជាការប៉ះពាល់ដល់បទប្បញ្ញត្តិស្តីពីភាគបម្រុងទេ គឺត្រូវមោឃភាពតែចំពោះផ្នែកដែលប៉ះពាល់នោះ

[២០] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, *សៀវភៅជំនួយស្មារតី, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ,* (ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១៧, ៣៨៩។

តែប៉ុណ្ណោះ មានន័យថាមិនមែននឹងត្រូវមោឃភាពនៅគ្រប់ផ្នែកនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធទាំងមូលនោះឡើយ។

### កថាខណ្ឌទី២ លក្ខខណ្ឌទម្រង់នៃប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមកិច្ចសន្យា

លក្ខខណ្ឌទម្រង់ ឬហៅថាលក្ខខណ្ឌតតាំង គឺជាលក្ខខណ្ឌមួយដែលតម្រូវឲ្យមានជាចាំបាច់បន្ទាប់ពីលក្ខខណ្ឌគ្រឹះត្រូវបានបំពេញ ក្នុងន័យឲ្យមានអានុភាពទៅលើតតិយជនក្រៅពីគូភាគី។[២១] ហេតុ ដូច្នេះ កង្វះខាតនូវលក្ខខណ្ឌតតាំង នឹងនាំឲ្យតតិយជនអាចជំទាស់ចំពោះអានុភាពនៃកិច្ចសន្យា ចំពោះភាគីដែលជាប្ដី ជាប្រពន្ធខ្លួនឯងបាន។ ដើម្បីជៀសវាងពីហានិភ័យទាំងអស់នេះហើយទើប លក្ខខណ្ឌទម្រង់នៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមកិច្ចសន្យា[២២] គឺតម្រូវឲ្យមានធ្វើឡើងជាកិច្ចសន្យាជាលាយលក្ខណ៍អក្សរ (២.១) និងលក្ខខណ្ឌតតាំង (២.២) ដើម្បីឲ្យកិច្ចសន្យានោះមានលក្ខណៈជាលិខិតយថាភូត ពោលគឺមានអានុភាពអាចតតាំងជាមួយតតិយជនតាមរយៈការចុះបញ្ជីកិច្ចសន្យានេះ។

#### ២.១. កិច្ចសន្យាជាលាយលក្ខណ៍អក្សរ

ដោយសារតែកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនេះនាំឲ្យមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទំនាក់ទំនងនៃសិទ្ធិ និងករណីយកិច្ចរបស់ប្ដី និងប្រពន្ធ ជាហេតុនាំឲ្យក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បញ្ញត្តិអំពីទម្រង់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធយ៉ាងប្រត្យក្សមួយដោយតម្រូវឲ្យកិច្ចសន្យានេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

នៅក្នុងកិច្ចសន្យានេះផងដែរ ត្រូវសរសេរឡើងដោយមានបញ្ជាក់ពី៖

- អត្តសញ្ញាណ និងអាសយដ្ឋាននៃសហព័ទ្ធ
- ព្រមទាំងខថែងនៃខ្លឹមសារដែលបានព្រមព្រៀងគ្នាតាមរយៈហត្ថលេខា ឬស្នាមមេដៃរបស់សហព័ទ្ធ ទាំងសង។
- ក្រោយពីបានធ្វើហើយ លិខិតនេះត្រូវយកទៅដាក់ជាឯកសារនៅពេលដាក់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដី ប្រពន្ធនៅឯក្រសួងយុត្តិធម៌។

#### ២.២. លក្ខខណ្ឌតតាំងនឹងតតិយជនតាមរយៈការចុះបញ្ជីកិច្ចសន្យាប្ដីប្រពន្ធ

ដូចដែលបានរៀបរាប់ខាងលើរួចមកហើយ លក្ខខណ្ឌតតាំងដែលមាននៅក្នុងនីតិវិធីនៃការចុះបញ្ជីនៃកិច្ចសន្យាប្ដីប្រពន្ធប្រៀបដូចជាការត្រួតពិនិត្យមួយចំពោះការព្រមព្រៀង ក៏ដូចជាខ្លឹមសារដែលអាចប៉ះពាល់ដល់តតិយជន ព្រមទាំងការពារពីការតតាំងរបស់តតិយជន ដែលអាចនឹងរងការ

[២១] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, *សៀវភៅជំនួយស្មារតី, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ,* (ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១៧), ៣៨៩។

[២២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧០។

ខាតបង់នានា។[២៣] ចំណែកឯការចុះបញ្ជីដែលក្រមរដ្ឋប្បវេណីបានកំណត់នោះ គឺបានបើកឲ្យប្តីប្រពន្ធអាចមកចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ បានរួមទាំងមុន និងក្រោយអាពាហ៍ពិពាហ៍ ព្រមទាំងបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ផងដែរ។[២៤]

## ផ្នែកទី២ នីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តី ប្រពន្ធ

នីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ គឺជាការកំណត់អំពីបែបបទ និងទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបែបបទទាំងនោះ ត្រូវបានកំណត់ប្រកាសស្តីពីនីតិវិធីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធឆ្នាំ ២០១៣ បានជ្រើសយកនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ជាស្ថាប័នមានសមត្ថកិច្ចក្នុងកិច្ចការចុះបញ្ជី នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះដោយបានកំណត់ឡើងដូចជា៖[២៥] ការស្នើសុំចុះបញ្ជី (កថាខណ្ឌទី១) របៀបនៃការចុះបញ្ជី (កថាខណ្ឌទី២) ព្រមទាំងការរក្សាទុកនូវការចុះបញ្ជី (កថាខណ្ឌទី៣) និងបែបបទនានាទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដើម្បីអនុញ្ញាតឲ្យសហព័ទ្ធ អាចប្រើប្រាស់នូវ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាបាន (កថាខណ្ឌទី៤) ដែលនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តី ប្រពន្ធនេះមានវិសាលភាពលើចំណុចជាច្រើនដូចជា ការបង្កើត ការផ្លាស់ប្តូរ ការលុបចោល និងការចេញលិខិតបញ្ជាក់ ការចុះបញ្ជីកិច្ចសន្យាប្តីប្រពន្ធ។[២៦]

### កថាខណ្ឌទី១ ពាក្យសុំនៃការចុះបញ្ជី

#### ១.១. ទម្រង់នៃពាក្យសុំ

ដូចដែលបានរៀបរាប់ដូចខាងលើរួចមក ទម្រង់នៃកិច្ចសន្យាត្រូវសរសេរជាលាយលក្ខណ៍អក្សរ ដែលក្នុងនោះត្រូវមានបញ្ចូលនូវអត្តសញ្ញាណរបស់សហព័ទ្ធ ព្រមទាំងកម្មវត្ថុច្បាស់លាស់។ ម្យ៉ាងវិញទៀតក្នុងពាក្យសុំនោះដែរ ក៏ត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់នានាដែលមានភាពបត់បែនទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនោះ ប៉ុន្តែច្បាប់ដើមនៃឯកសារភ្ជាប់ ត្រូវបានអនុញ្ញាតឲ្យទាមទារប្រគល់វិញបាន។[២៧] ជាងនេះទៅទៀតអ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវពាក្យសុំនោះនូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះគ្មានភាពខុសពីច្បាប់ដើម ព្រម

[២៣] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, *សៀវភៅជំនួយស្មារតី, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, (ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១៧), ៣៤៩។

[២៤] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៥*, (ភ្នំពេញ៖ ២០១០), ៣០។

[២៥] JICA, *ការបកស្រាយអំពីប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធ*, ១៤ និង ១៥ មីនា ឆ្នាំ ២០១៨, ទំព័រ ៣៥ និង ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ប្រការ៤។

[២៦] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ប្រការ៣។

[២៧] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ប្រការ១៧ កថាខណ្ឌទី១។

ទាំងសរសេរសេចក្ដីបញ្ជាក់នៃការណ៍ដែលខ្លួនបានទទួលការប្រគល់ឯកសារនៅក្នុងឯកសារចម្លង និងចុះហត្ថលេខា។[២៨]

### ១.២. ទម្រង់លិខិត

នៅក្នុងកិច្ចការរដ្ឋបាលជាទូទៅ គឺទម្រង់នៃលិខិតមានលក្ខណៈជាលិខិតរដ្ឋបាលដែលចាំបាច់ត្រូវមានចំណុចសំខាន់ដូចជា៖

- បាវចនាជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ចំណងជើងនៃពាក្យសុំ
- ការធ្វើគារវកិច្ចចំពោះអ្នកទទួលលិខិត ពោលគឺការគោរពចូលមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ (សូមគោរពជូនឯក ឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌)
- កម្មវត្ថុឲ្យបានច្បាស់លាស់
- ជាចុងក្រោយ គឺកាលបរិច្ឆេទធ្វើលិខិត និងហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដាក់ពាក្យសុំ។[២៩]

បន្ថែមពីលើនេះទៅទៀត ពាក្យសុំមានបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃពាក្យសុំទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ រួមមានដូចជា៖

- ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដី ប្រពន្ធ
- ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ពាក្យសុំចុះបញ្ជីអំពីការលុប ចោលកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ជាអាទិ៍។[៣០]

### ១.៣. អត្តសញ្ញាណសហព័ទ្ធ

សម្រាប់ពាក្យសុំចុះបញ្ជីនេះ គឺតម្រូវឲ្យមានបុគ្គលស្នើសុំពាក្យបំពេញនូវពត៌មានជាចម្បងៗដូចជាអត្តសញ្ញាណផ្ទាល់ខ្លួន (ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត) ឋានៈជាអ្វីនៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (ជាប្ដី ឬជាប្រពន្ធ ឬជាបុគ្គលដែលត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នា) និងអាសយដ្ឋានបច្ចុប្បន្ន។[៣១]

### ១.៤. កម្មវត្ថុនៃពាក្យសុំ

អនុលោមតាមប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ មានការចែង អំពីកម្មវត្ថុនៃការចុះបញ្ជីចំនួន ៧ យ៉ាងផ្សេងៗគ្នាដូចជា៖

- សំណើសុំចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដី ប្រពន្ធ

---

[២៨] ប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ប្រការ១៨។

[២៩] ប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ប្រការ១៦ កថាខណ្ឌទី១។

[៣០] ប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ប្រការ១៧ កថាខណ្ឌទី២។

[៣១] ប្រកាសស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ឧបសម្ព័ន្ធទី១ ដល់ឧបសម្ព័ន្ធទី៧។

- សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ
- សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬអាសយដ្ឋាន
- សំណើសុំចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ
- សំណើសុំចុះបញ្ជីអំពីការលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ
- សំណើសុំចុះបញ្ជីអំពីកាលបរិច្ឆេទរៀបអាពាហ៍ពិពាហ៍
- សំណើសុំចេញលិខិតបញ្ជាក់

ទាំងអស់នេះ បានសេចក្តីថាការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺថាអាចធ្វើការផ្លាស់ប្តូរ កែប្រែ និងលុបចោលបាន។

បន្ទាប់ពីបញ្ជាក់អំពីកម្មវត្ថុនៃពាក្យសុំ មានការតម្រូវឲ្យបង្ហាញពី គោលបំណង មូលហេតុ និងខ្លឹមសារនៃកម្មវត្ថុនោះ។ ជាពិសេសជាងនេះទៅទៀត អ្នកដាក់ពាក្យសុំចុះបញ្ជី អាចជាសហព័ទ្ធក៏បាន និងអាចអ្នកតំណាងក៏បាន។

**កថាខណ្ឌទី២ របៀបនៃការចុះបញ្ជី**

យោងតាមតាមសេចក្តីណែនាំស្តីពីការចុះបញ្ជីនៅក្នុងប្រកាសស្តីពីការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយការចុះបញ្ជីត្រូវបានធ្វើឡើងតាមការទទួលពាក្យសុំចុះបញ្ជីយកមកពិនិត្យ សរសេរចូលក្នុងសន្លឹកចុះបញ្ជី រួចបញ្ជូនទៅរដ្ឋមន្រ្តីនៃក្រសួងយុត្តិធមិសម្រេច ហើយជាចុងក្រោយ គឺត្រូវរក្សាទុកនៅក្នុងក្រូណូ។

ដើម្បីជាគន្លឹះក្នុងការបកស្រាយអំពីរបៀបនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺត្រូវបែងចែកជាពីរដំណាក់កាល ដែលដំណាក់កាលទី១ គឺនីតិវិធីមុនចុះបញ្ជី និងដំណាក់កាលទី២ គឺនីតិវិធីក្រោយពិនិត្យ និងសម្រេច។

នីតិវិធីមុនចុះបញ្ជី គឺជាបន្ទុក និងសកម្មភាពការងាររបស់មន្រ្តីចុះបញ្ជី ចំពោះការទទួលពាក្យសុំ ពិនិត្យពាក្យសុំ និងរៀបចំសន្លឹកចុះបញ្ជី។ នៅពេលដែលមន្រ្តីចុះបញ្ជីបានទទួលពាក្យសុំនោះមន្រ្តីចុះបញ្ជីត្រូវស្រង់នូវពត៌មានពីពាក្យសុំមកសរសេរចូលក្នុងសន្លឹកក្រដាសទទួលពាក្យសុំ[៣២] ទៅតាមតារាង បែងចែកខ្ទង់ដែលមានរៀបចំរួចជាស្រេច។[៣៣] សម្រាប់ពត៌មានដែលត្រូវដកស្រង់ចូលសន្លឹកក្រដាស ទទួលពាក្យសុំមានដូចជា លេខរៀងទទួលពាក្យ កាលបរិច្ឆេទនៃការទទួលពាក្យ ប្រភេទនៃការចុះបញ្ជី កិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ ឈ្មោះ និងអាសយដ្ឋានអ្នកដាក់ពាក្យសុំ ជាប្តីឬជាប្រពន្ធ បុគ្គលដែល នឹងត្រូវរៀនអាពាហ៍ពិពាហ៍ជាមួយគ្នា ឈ្មោះ និងអាសយដ្ឋាន

[៣២] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ប្រការ ៣៧។
[៣៣] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ឧបសម្ព័ន្ធ ៨ និង គំរូចុះបញ្ជី១។

របស់អ្នកតំណាង (ប្រសិនបើមាន) និងផ្សេងៗ។[៣៤] អ្នកដាក់ពាក្យសុំ អាចដកពាក្យសុំចុះបញ្ជីរបស់ខ្លួនវិញបាន នៅពេលនីតិវិធីនៃការចុះបញ្ជី ត្រូវបានបញ្ចប់ដោយការដកពាក្យសុំនោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ជាងនេះទៅទៀត មន្ត្រីចុះបញ្ជីមានតួនាទីក្នុងការពិនិត្យពាក្យសុំចុះបញ្ជី ឯកសារបញ្ជាក់ដែលតម្រូវឲ្យអ្នកដាក់ពាក្យ ប្រគល់ជូន និងផ្ទៀងផ្ទាត់រវាងពាក្យសុំចុះបញ្ជីនឹងឯកសារដែលភ្ជាប់ជាមួយ។ ក្នុងករណីដែលមន្ត្រីចុះបញ្ជីមានវិមតិសង្ស័យ នោះមន្ត្រីចុះបញ្ជីអាចធ្វើការសាកសួរបន្ថែមទៅកាន់អ្នកពាក្យសុំ ឬអ្នកតំណាង ដែលមកដាក់ពាក្យជំនួសនោះបាន។[៣៥] ក្នុងករណីដែលមន្ត្រីចុះបញ្ជី បានពិនិត្យរកឃើញថាពាក្យសុំចុះ បញ្ជីនោះឡើងពុំត្រឹមត្រូវ ដោយមានចំណុចខ្វះខាត ឬមិនគោរពទៅតាមបទប្បញ្ញត្តិណែនាំនានា នោះមន្ត្រីចុះបញ្ជីអាចចេញលិខិតបង្គាប់ឲ្យកែតម្រូវ និងជូនដំណឹងទៅអ្នកដាក់ពាក្យសុំដោយមានកំណត់ពេលវេលាដើម្បីកែតម្រូវក្នុងរយៈពេលមួយដ៏សមរម្យ។ មូលហេតុដែលអាចចាត់ទុកថា ពាក្យសុំនៃការចុះបញ្ជីនោះធ្វើឡើងមិនត្រឹមត្រូវ គឺមានដូចជាពត៌មាន និងបែបបទក្នុងពាក្យសុំចុះបញ្ជីនោះមិនស្របតាមតាមប្រកាសនេះពុំបានផ្តល់ឯកសារដែលជាចាំបាច់ខ្លឹមសារនៅក្នុងពាក្យសុំ និងឯកសារមិនសមស្របគ្នា ពាក្យសុំចុះបញ្ជីនោះធ្លាប់បានដាក់ និងចុះបញ្ជីម្តងរួចមកហើយ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំនៅក្នុងពាក្យសុំមិនស្របគ្នាជាមួយនឹងការចុះបញ្ជី ពុំបានបង់សោហ៊ុយ ឬពាក្យសុំ នោះមិនអនុលោមតាមលក្ខខណ្ឌនៃប្រកាសនេះ ឬច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធ។

បន្ទាប់ពីបានពិនិត្យពីមន្ត្រីចុះបញ្ជីរួចហើយ នោះមន្ត្រីចុះបញ្ជីដែលបានពិនិត្យ និងយល់ឃើញថាពាក្យសុំចុះបញ្ជីមានភាពត្រឹមត្រូវ និងគោរពទៅតាមបទបញ្ញត្តិនានាដែលពាក់ព័ន្ធហើយមន្ត្រីចុះបញ្ជី ត្រូវសរសេរនូវពតិមាន កម្មវត្ថុ ខ្លឹមសារនៃពាក្យសុំចូលក្នុងសន្លឹកចុះបញ្ជីដែលមានឮមុខងារតាមសន្លឹក ចុះបញ្ជីនីមួយៗ។ ក្រោយពីបំពេញចូលសន្លឹកចុះបញ្ជីរួចរាល់ហើយ មន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខា បំព្រួញ ដើម្បីបញ្ជាក់ថា "**បានពិនិត្យរួចហើយ**" នៅខ្ទង់ដែលគេបានកំណត់ រួចត្រូវបញ្ជូនទៅរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។ ម្យ៉ាងទៀតក្នុងករណីដែលការចុះបញ្ជីកាលបរិច្ឆេទអាពាហ៍ពិពាហ៍ មន្ត្រីចុះបញ្ជីត្រូវសរសេរអំពីកាលបរិច្ឆេទនៃថ្ងៃចុះអាពាហ៍ពិពាហ៍នៅខ្ទង់ "**កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍**" នៅក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយមន្ត្រីចុះបញ្ជីត្រូវហត្ថលេខា កាលបរិច្ឆេទ និងឈ្មោះរបស់មន្ត្រីចុះបញ្ជី[៣៦] ដោយពុំចាំបាច់មានការពិនិត្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ម្តងទៀតនោះទេ។

---

[៣៤] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ប្រការ ៦ កថាខណ្ឌទី២។

[៣៥] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ប្រការ ៣១។

[៣៦] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ប្រការ ៤២។

## កថាខណ្ឌទី៣ ការចេញលិខិតបញ្ជាក់

ដោយសារតែបញ្ជីកិច្ចសន្យាប្តីប្រពន្ធមានលក្ខណៈ សាធារណៈ ឬត្រូវបានបើកបង្ហាញជាសាធារណៈ ដូចនេះការចេញជាលិខិតបញ្ជាក់នឹងត្រូវបានធ្វើឡើងគ្រប់ពេលវេលា អាស្រ័យតាមការស្នើសុំ មិនថាការស្នើសុំនោះធ្វើឡើងដោយសហព័ទ្ធដែលជា ភាគីនៃកិច្ចសន្យាផ្ទាល់ ឬតតិយជននោះទេ។

### ៣.១. អ្នកសុំចេញលិខិតបញ្ជាក់

អ្នកស្នើសុំឲ្យចេញលិខិតបញ្ជាក់ត្រូវតែបំពេញនូវលក្ខខណ្ឌតម្រូវឲ្យបានខ្ជាប់ខ្ជួន តួយ៉ាងដូចជា ការតម្រូវឲ្យពាក្យសុំចេញលិខិតបញ្ជាក់នោះត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវបំពេញនូវពត៌មានផ្សេងៗទៅតាមការតម្រូវការជាក់ស្តែងរបស់អ្នកដាក់ពាក្យស្នើសុំរួមមាន ឈ្មោះរបស់បុគ្គល ឬអ្នកតំណាងនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំចេញលិខិតបញ្ជាក់ គោលបំណងនៃការចេញលិខិតបញ្ជាក់ និងចំនុចផ្សេងៗទៀត។ អ្នកស្នើសុំឲ្យចេញលិខិតបញ្ជាក់ត្រូវទៅដាក់ពាក្យសុំនោះនៅឯនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ និងបង់សោហ៊ុយសេវា ដូចបានបញ្ញត្តិ ឬប្រកាសរួមរបស់ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ។[៣៧]

### ៣.២. នីតិវិធីចេញលិខិតបញ្ជាក់

បន្ទាប់ពីទទួលបានពាក្យសុំឲ្យចេញលិខិតបញ្ជាក់នោះរួចមក មន្ត្រីចុះបញ្ជីត្រូវថតចម្លងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលមានស្រាប់នៅក្នុងក្រុំណូឲ្យទៅអ្នកដាក់ពាក្យសុំ ដោយគ្រាន់តែបញ្ជាក់នៅលើសន្លឹកដែលបានបញ្ជាក់នោះថាជាច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម តាមរយៈការចុះកាលបរិច្ឆេទ ព្រមទាំងហត្ថលេខាបំព្រួញរបស់មន្ត្រីចុះបញ្ជីផងដែរ។ ច្បាប់ថតចម្លងដែលបានបំពេញ នូវគោលការណ៍ខាងលើរួចមកហើយ នឹងត្រូវបញ្ជូនបន្តទៅឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីពិនិត្យ ហើយកាលបើរដ្ឋមន្ត្រីមានការឯកភាព និងយល់ស្របចំពោះពាក្យសុំនោះ គាត់នឹងចុះហត្ថលេខា ព្រមទាំងប្រថាប់ត្រារបស់ក្រសួងទៅលើពាក្យសុំឲ្យចេញលិខិតបញ្ជាក់នោះ។

ម្យ៉ាងវិញទៀត នៅក្នុងការចេញជាលិខិតបញ្ជាក់នេះផងដែរគឺ តម្រូវឲ្យក្រសួងយុត្តិធម៌ជា អ្នកទទួលបន្ទុកចេញនូវលិខិតបញ្ជាក់នោះ ក្រោយរយៈពេល៣ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃដែលធ្វើការដាក់ពាក្យសុំ។[៣៨]

---

[៣៧] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ប្រការ៨៨។
[៣៨] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ប្រការ៨៩។

## ផ្នែកទី៣ អានុភាពនៃការចុះបញ្ជី

កិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ ជាកិច្ចសន្យាមួយដែលបានជួយជ្រោមជ្រែងសម្រួល និងបង្កើតនូវភាពជឿជាក់ដល់ប្តី និងប្រពន្ធ ដែលកិច្ចសន្យានោះទាក់ទិននឹងបញ្ហាជាច្រើន រួមមានចំណាត់ចាត់ ចែងនូវសិទ្ធិលើទ្រព្យសម្បត្តិ កាតព្វកិច្ច និងករណីយកិច្ចដែលតម្រូវឲ្យសហព័ទ្ធគោរព និងអនុវត្តតាម គោលការណ៍ដែលច្បាប់បានកំណត់។ គួរបញ្ជាក់ផងដែរថា ការចុះបញ្ជីទ្រព្យសម្បត្តិប្តី ប្រពន្ធនេះ ត្រូវបានបង្កើតឡើងដោយគោរពទៅតាមការកំណត់ និងចង្អុលបង្ហាញរបស់ច្បាប់ គឺក្នុងគោលបំណងដើម្បីធានាឲ្យមានភាពត្រឹមត្រូវដែលវាបានបង្កើតឲ្យមានអានុភាពគតិយុត្ត។

គួបផ្សំជាមួយគ្នានេះដែរ ការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យានេះនាំឲ្យមានអានុភាពចំពោះសហព័ទ្ធនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (កថាខណ្ឌទី១) ក៏ដូចជាមានអានុភាពចំពោះតតិយជន (កថាខណ្ឌទី២)។

### កថាខណ្ឌទី១ អានុភាពចំពោះសហព័ទ្ធនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធ អាចធ្វើឡើងបាននៅមុន និងក្រោយពេលរៀបអាពាហ៍ពិពាហ៍ក៏បាន គ្រាន់តែការចុះនោះតម្រូវឲ្យគោរពតាមនីតិវិធីច្បាប់ឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីធានាបាននូវការអានុភាពនៃកិច្ចសន្យានោះតាមគោលការណ៍គតិយុត្ត។ ការចុះបញ្ជីទ្រព្យសម្បត្តិ ប្តី ប្រពន្ធនេះនឹងបានបង្កើតអានុភាពចំពោះភាគីនៃកិច្ចសន្យា ពោលគឺសហព័ទ្ធដែលបានចុះបញ្ជីនោះ បានកំណត់ដ៏ជាក់លាក់មួយនូវទំហំទ្រព្យសម្បត្តិដែលសហព័ទ្ធទាំងសងខាងមាន។ បន្ថែមពីលើនេះ ទ្រព្យរួម និងទ្រព្យដោយឡែករបស់ប្តី ប្រពន្ធ នឹងត្រូវបានកំណត់យ៉ាងច្បាសនៅក្នុងខ្លឹមសារនៃកិច្ចសន្យា ត្រង់នេះបានបង្ហាញឲ្យឃើញពីភាពច្បាស់លាស់ ចំពោះសិទ្ធិ និងកាតព្វកិច្ចដែលភាគី ជាប្តី និងប្រពន្ធត្រូវបំពេញ។ ចំពោះទ្រព្យសម្បត្តិដោយឡែកដែលរបស់ប្តី ឬប្រពន្ធតែម្ខាងមិនអាចរឹបអូស បាន ឬលក់ដោយគ្មានការបង្ហាញឆន្ទៈរបស់ម្ចាស់កម្មសិទ្ធិទេ គឺមិនអាចធ្វើបានទេ លើកលែងតែក្នុងករណីដែលមានការអនុញ្ញាតដោយមានបទបញ្ញត្តិច្បាប់បានបញ្ញត្តិជាមុនទៅករណីមួយចំនួន។ ករណីមួយចំនួន។

ឧទាហរណ៍ដូចជា៖ នៅពេលដែលប្តីបានជំពាក់បំណុលគេ ហើយពុំមានលទ្ធភាពនៅក្នុងការសងទើបត្រូវបានម្ចាស់បំណុលរឹបអូសយកទ្រព្យរបស់ខ្លួនជំនួស ប៉ុន្តែការរឹបអូសដែលធ្វើទៅនេះ ចាំបាច់ត្រូវគោរពនូវគោលការណ៍ដែលបានកំណត់នៅក្នុងខ្លឹមសារនៃបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តី ប្រពន្ធចំពោះទំហំទ្រព្យ មានន័យថាបំណុលដែលជាបន្ទុករបស់ប្តីដែលតម្រូវឲ្យមានរឹបអូសយកទ្រព្យ ជំនួសនោះ គេអាចរឹបអូសបានត្រឹមតែទ្រព្យដោយឡែកដែលជាកម្មសិទ្ធិរបស់ប្តីតែ

ប៉ុណ្ណោះ ហើយម្ចាស់បំណុលមិនអាចបំពាន ឬធ្វើការរឹបអូសនូវទ្រព្យដោយឡែកដែលជាកម្មសិទ្ធិរបស់ប្រពន្ធទៀតបានឡើយ។

**កថាខណ្ឌទី២ អានុភាពចំពោះតតិយជន**

ក្រៅពីការបង្កើតឲ្យមានអានុភាពដល់សហព័ទ្ធដែលជាភាគីនៃកិច្ចសន្យា ការចុះបញ្ជីកិច្ចសន្យា ប្តី ប្រពន្ធក៏មានបង្កើតអានុភាពចំពោះតតិយជនដែរ។ ចំពោះតតិយជនដែលមានផលប្រយោជន៍ ឬ មានគោលបំណងចង់បញ្ជាក់ទំហំទ្រព្យសម្បត្តិរបស់ប្តី ឬប្រពន្ធ បានសេចក្តីថានេះជាមូលដ្ឋាននៅក្នុង ការកំណត់នូវទ្រព្យសម្បត្តិរបស់ភាគីណាម្ខាងនៃកិច្ចសន្យា ឲ្យច្បាស់លាស់សម្រាប់ការសម្រេចធ្វើកិច្ច គតិយុត្តណាមួយជាមួយប្តី ឬប្រពន្ធ ហើយដើម្បីជៀសវាងនូវការខូចបង់ទ្រព្យរបស់ខ្លួននោះ តតិយជននោះអាចស្នើសុំចេញនូវលិខិតបញ្ជាក់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះបាន។

គួរបញ្ជាក់ផងដែរថា តតិយជនអាចទាមទារឲ្យចេញនូវលិខិតបញ្ជាក់នោះ អាចជារូបវន្តបុគ្គល ឬ ជានីតិបុគ្គលដែលមានផលប្រយោជន៍ ចំពោះទ្រព្យ ហើយអាចសុំចេញលិខិតបញ្ជាក់នេះ ត្រូវតែគោរពតាមគោលការណ៍ និងលក្ខខណ្ឌដែលច្បាប់បានកំណត់ ជាក់ស្តែងដូចជាការបញ្ជាក់អំពីគោលបំណង ឬកម្មវត្ថុនៃការសុំនោះជាអាទិ៍។

**ផ្នែកទី៤ ផលប្រយោជន៍នៃការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា**

ការបង្កើតឲ្យមាននូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានបង្កប់នូវផលប្រយោជន៍មួយចំនួនរួមមាន[៣៩] ការពារនូវផលប្រយោជន៍របស់សហព័ទ្ធ (កថាខណ្ឌទី១) កំណត់លើទំនាក់ទំនងកាតព្វកិច្ច និងសិទ្ធិ លើបំណុល (កថាខណ្ឌទី២) កំណត់អំពីសិទ្ធិគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ (កថា ខណ្ឌទី៣) និងសម្រួលនីតិវិធីដោះស្រាយរបស់តុលាការ (កថាខណ្ឌទី៤)។

**កថាខណ្ឌទី១. ការពារផលប្រយោជន៍របស់សហព័ទ្ធ**

ការកំណត់នូវទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធតាមកិច្ចសន្យា ជាកត្តាមួយដែលជួញឲ្យសហព័ទ្ធមានភាពងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិឲ្យបានត្រឹមត្រូវ និងមានសមភាពក្រោយពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់។

ជាក់ស្តែងនៅក្នុងករណីដែលសហព័ទ្ធកំណត់ថា ទ្រព្យណាមួយជាទ្រព្យរួម នោះនៅពេលដែលភាគីណាមួយទទួលមរណភាពទ្រព្យនោះនឹងក្លាយជាទ្រព្យរបស់ភាគីជាសហព័ទ្ធម្ខាងទៀត ក៏ប៉ុន្តែមិនអាចបំពានលើភាគបំរុងបានទេ។ សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច។

[៣៩] ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា, https://thimhorn.wordpress.com/2017/11/09/ប្រព័ន្ធទ្រព្យសម្បត្តិ/, (ចូលទស្សនានៅថ្ងៃ ២៥ មិថុនា ២០១៨)។

## កថាខណ្ឌទី២ កំណត់លើទំនាក់ទំនងភាតព្វកិច្ច និងសិទ្ធិលើចំណុល

ជាគោលការណ៍ចំពោះប្តីប្រពន្ធ មានកាតព្វកិច្ចទំនុកបំរុងក្នុងជីវភាពប្រចាំថ្ងៃ ចំណូលដែលរកបាន ឬប្រាក់បៀវត្សដែលរកបាន ត្រូវចាត់ទុកជាទ្រព្យរួម ដែលទំនាក់ទំនងទ្រព្យនេះត្រូវបានកំណត់នៅមុនពេល ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍របស់សហព័ទ្ធតាមកិច្ចសន្យា។ ដោយឡែកក្នុងកំឡុងពេលនៃអាពាហ៍ពិពាហ៍ដែលប្តីប្រពន្ធបានព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុលវាជាការទទួលខុសត្រូវរួមដោយសាមគ្គី។ នៅត្រង់ចំណុចនៃមាត្រានេះ ទាមទារឲ្យមានលក្ខខណ្ឌចាំបាច់នៃលិខិតជាលាយលក្ខណ៍អក្សរ និងការព្រមព្រៀងរវាងប្តីប្រពន្ធទាំងសងខាងដើម្បីជៀសវាងការដាក់បន្ទុកធ្ងន់ធ្ងរទៅលើភាគីម្ខាងៗ។ ទោះជាយ៉ាងណាក៏ដោយ ជាគោលការណ៍បន្ទុកនៃកាតព្វកិច្ចត្រូវជាទ្រព្យសម្បត្តិរួម ដូច្នេះហើយសិទ្ធិចំពោះទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធម្ខាងទៀត មិនត្រូវបានការពារទេ នៅក្នុងទំនាក់ទំនងជាមួយតតិយជនដែលសុចរិត ហើយគ្មានកំហុសលើកលែងតែករណីដែលបានធ្វើការចាត់រក្សាការពារចំពោះទ្រព្យសកម្ម។

## កថាខណ្ឌទី៣ កំណត់អំពីសិទ្ធិគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ

ជាទូទៅកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់យ៉ាងជាក់លាក់អំពីទ្រព្យសម្បត្តិដែលសហព័ទ្ធមាន។ ការបែងចែកឲ្យដាច់ពីគ្នារវាងទ្រព្យរបស់សហព័ទ្ធពោលគឺទ្រព្យណាដែលជាទ្រព្យរបស់ប្តី ទ្រព្យណារបស់ប្រពន្ធ ហើយទ្រព្យណាជាទ្រព្យរួមដែលសហព័ទ្ធរកបាននៅក្នុងចំណងអាពាហ៍ពិពាហ៍ នឹងជាកត្តាមួយយ៉ាងសំខាន់នៅក្នុងការកំណត់កម្មសិទ្ធិនៃទ្រព្យ ហើយតាមរយៈការកំណត់កម្មសិទ្ធិនេះអាចធ្វើឲ្យប្តីប្រពន្ធអាចបែងចែកគ្នាដាច់ចំពោះសិទ្ធិក្នុងការគ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យ ដែលអាចបង្ការ ឬធ្វើឲ្យសហព័ទ្ធជៀសផុតបញ្ហាជម្លោះដែលកើតមានឡើងតាមរយៈការប្រើប្រាស់ និងគ្រប់គ្រងលើទ្រព្យទាំងឡាយណាដែលជាទ្រព្យដោយឡែក និងមានសិទ្ធិគ្រប់គ្រងទៅលើទ្រព្យរួមផងដែរ ក៏ប៉ុន្តែក្នុងការចាត់ចែងទ្រព្យរួម គេតម្រូវឲ្យមានការសហការគ្នារវាងសហព័ទ្ធទាំងពីរ លើកលែងតែក្នុងករណីចាំបាច់មួយដែលមានបញ្ញត្តិនៅក្នុងច្បាប់។

## កថាខណ្ឌទី៤ សម្រួលនីតិវិធីដោះស្រាយរបស់តុលាការ

ជាការពិតណាស់ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាដែលបង្កើតឡើងឲ្យមានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ មានគោលបំណងអនុញ្ញាតឲ្យសហព័ទ្ធអាចចុះនូវកិច្ចសន្យាដើម្បីកំណត់ឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យប្តីប្រពន្ធ។ ដូច្នេះដោយសារតែកិច្ចសន្យានេះមានទម្រង់ជាលិខិតលាយលក្ខណ៍អក្សរ ថែមទាំងអាចស្នើសុំចុះបញ្ជីដើម្បីក្លាយជាលិខិតយថាភូតទៀតនោះ ដែលនាំឲ្យប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះ មានអំណោយផល ក៏ដូចជាអនុគ្រោះយ៉ាងមាន

ប្រសិទ្ធភាពចំណោះដំណើរការនីតិវិធី ព្រមទាំងជាវត្ថុតាងដល់តុលាការចំពោះការវិនិច្ឆ័យ ដែលក្នុងនោះការសម្រួលជាពិសេសដល់តុលាការនៅក្នុងវិវាទលែងលះ វិវាទផ្នែកមរតក និងវិវាទក្នុងករណីទាមទារឲ្យអនុវត្តកាតព្វកិច្ច។

# ជំពូកទី២

## ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ
## តាមច្បាប់កំណត់

# ជំពូកទី២
# ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់

ក្រៅពីមានការកំណត់អំពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ច្បាប់ក៏មានចែងអំពីការគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិប្តីប្រពន្ធក្នុងទំហំដែលច្បាប់បានកំណត់ផងដែរ។ ជាក់ស្តែង ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់ នឹងចូលខ្លួនមកអនុវត្តជាស្វ័យប្រវត្តិ ប្រសិនបើសហព័ទ្ធពុំបានបង្កើតនូវកិច្ចសន្យាទ្រព្យសម្បត្តិរបស់ខ្លួននោះទេ។ ជាងនេះទៀតសោត ដើម្បីអោយប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់របស់សហព័ទ្ធ នឹងមានអានុភាពទៅបាន កាលណាពួកគេមានអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលមានការកំណត់ទៅតាមច្បាប់ ដែលផ្នែកទី១ នៃជំពូកនេះនឹងបកស្រាយលំអិតអំពីធាតុនីត្យានុកូលចាំបាច់សម្រាប់អាពាហ៍ពិពាហ៍។

ខាងក្រោម នេះនឹងធ្វើការបកស្រាយអំពីសច្ចធារណ៍នីត្យានុកូល (ផ្នែកទី១) អានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់ (ផ្នែកទី២) និងការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ (ផ្នែកទី៣)។

## ផ្នែកទី១ សច្ចធារណ៍នីត្យានុកូល

នៅក្នុងផ្នែកទី១ សច្ចធារណ៍នីត្យាកូល មានគោលបំណងចង់រំលេចឲ្យឃើញអំពីការកើតឡើងនូវប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់តែប៉ុណ្ណោះ។ ដូចគ្នាទៅនឹងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់នេះ មូលដ្ឋានគ្រឹះនៃការបង្កើតឡើង គឺចាំបាច់តម្រូវឲ្យមានអាពាហ៍ពិពាហ៍មួយដែលមានអត្ថិភាព ប្រកបដោយអានុភាព និងសុពលភាពគតិយុត្ត។ ប៉ុន្តែសម្រាប់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ធាតុផ្សំរបស់វាចាំបាច់មួយទៀតគឺ តម្រូវឲ្យមានការបង្កើតឡើងនូវកិច្ចសន្យាទ្រព្យសម្បត្តិ ដែលមានការព្រមព្រៀង និងធ្វើឡើងរវាងប្តីប្រពន្ធទៅលើទ្រព្យសម្បត្តិរបស់ខ្លួន ចំណែកឯប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់វិញ ពុំតម្រូវឲ្យមានការព្រមព្រៀងអ្វីឡើយ ពីព្រោះបើសហព័ទ្ធពុំបានបង្កើតនូវប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាទេនោះ នោះប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់នឹងយកមកអនុវត្តដោយស្វ័យប្រវត្តិ។ ហេតុដូច្នេះទើបចំណុចខាងក្រោមនេះ នឹងបកស្រាយលំអិតបន្ថែមអំពីលក្ខខណ្ឌដែលនាំឲ្យមានប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់ (កថាខណ្ឌទី១) និង ការកំណត់អំពីប្រភេទទ្រព្យសម្បត្តិ (កថាខណ្ឌទី២)។

**កថាខណ្ឌទី១ លក្ខខណ្ឌដែលនាំឲ្យមានប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់**

នៅក្នុងក្រមរដ្ឋប្បវេណី គន្ថីទី៧ ស្តីអំពីញាតិ មានការកំណត់នូវលក្ខខណ្ឌមួយចំនួនដែលធ្វើឲ្យអាពាហ៍ពិពាហ៍មានអានុភាព និងសុពលភាព។[៤០] កាលណាយើងនិយាយអំពីលក្ខខណ្ឌអានុភាពនៅក្នុងកិច្ចសន្យា ច្បាប់ចង់សំដៅទៅលើសំណើ និងស្ទីការត្រូវគ្នា សម្រាប់អាពាហ៍ពិពាហ៍មួយមានអានុភាពក៏មិនខុសពីកិច្ចសន្យាដែរ គឺចាំបាច់តម្រូវឲ្យមានការព្រមព្រៀងរវាងបុរស និងនារីដែលមានបំណងចង់រួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ។ ប៉ុន្តែ សម្រាប់លក្ខខណ្ឌសុពលភាពវិញ គឺតម្រូវឲ្យភាគីបុរស និងនារីនោះចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនទៀត ទើបធ្វើឲ្យអាពាហ៍ពិពាហ៍នោះមានសុពលភាពទៅបាន។ អនុលោមតាមមាត្រា៩៤៨ សម្រាប់លក្ខខណ្ឌអាយុនៃការរៀបអាពាហ៍ពិពាហ៍ បុរស និងនារីអាចរៀបអាពាហ៍ពិពាហ៍ទៅបាន លុះត្រាតែខ្លួនដល់នីតិភាព មានន័យថាមានអាយុមិនក្រោម១៨ឆ្នាំ ឬ មានម្ខាងដល់នីតិភាព ហើយម្ខាងទៀតអាចជាអនីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំ ដោយភាគីដែលជាអនីតិជននោះត្រូវមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។ ម្យ៉ាងវិញទៀត ពួកគេអាចទាមទារទៅតុលាការ ឲ្យសម្រេចសេចក្តីជំនួសការយល់ព្រមនេះបានក្នុងករណីដែលអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានជំទាស់ នូវការរៀបអាពាហ៍ពិពាហ៍របស់អនីតិជននោះ។[៤១] ប៉ុន្តែបញ្ញត្តិនេះពុំត្រូវបានយកមកអនុវត្តឡើយចំពោះការរៀបអាពាហ៍ពិពាហ៍របស់អនីតិជនដែលទទួលបាននូវអត្តាធីនភាព ទោះបីជាគេពុំទាន់ដល់អាយុរៀបអាពាហ៍ពិពាហ៍ ក៏ដោយ។[៤២]

លក្ខខណ្ឌមួយចំនួនទៀតដែលទាក់ទងទៅនឹង សុពលភាពអាពាហ៍ពិពាហ៍ គឺការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត ញាតិពន្ធតាមបញ្ញត្តិមាត្រា៩៥១ និងមាត្រា៩៥២នៃក្រមរដ្ឋប្បវេណី។ ក្រៅពីនេះ បុរស និងនារី អាចទទួលបាននូវអាពាហ៍ពិពាហ៍មួយដែលមានទាំងអានុភាព និងសុពលភាពបាន លុះត្រាតែអនុវត្តតាមលក្ខខណ្ឌដែលបានរាយរ៉ាប់ពីខាងដើម ព្រមទាំងនីតិវិធីនៃការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងបញ្ញត្តិមាត្រា៩៥៥ និងមាត្រា៩៥៦នៃក្រមរដ្ឋប្បវេណី (ដូចគ្នាសម្រាប់អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរដែលរស់នៅបរទេស ដូចមានចែងក្នុងមាត្រា៩៥៧ នៃក្រមដដែលនេះ)។

[៤០] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៤៨ ដល់មាត្រា៩៦៤។
[៤១] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៣។
[៤២] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២១។

សម្រាប់ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅវិញ ច្បាប់តម្រូវឲ្យគេមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអប្បបរិមាដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍ បើទោះបីជាគេជានីតិជនក៏ដោយ ក្នុងករណីនេះ ច្បាប់មិនតម្រូវឲ្យមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ[៩៣] (ប៉ុន្តែក្នុងករណីដែលគេជាអនីតិជន ត្រូវអនុវត្តដូចគ្នាទៅនឹងបញ្ញត្តិការរៀបអាពាហ៍ពិពាហ៍ដែលមាន ភាគីជាអនីតិជនដូចដែលបានរៀបរាប់ពីខាងដើម)។ ដោយឡែកអាពាហ៍ពិពាហ៍នោះពុំមានសុពលភាពឡើយប្រសិនបើវាមានមូលហេតុដែលនាំឲ្យមោឃភាព ឬមានការលើកឡើងអំពីការលុបចោលរបស់សហព័ទ្ធណាម្ខាងដែលមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការមោឃភាព ឬលុបចោលអាពាហ៍ពិពាហ៍នោះ ដែលស្របទៅនឹងបញ្ញត្តិមាត្រា៩៥៨ ដល់មាត្រា៩៦៤។

ដូច្នេះ នៅពេលដែលអាពាហ៍ពិពាហ៍មួយអានុភាព និងសុពលភាពហើយនោះ សហព័ទ្ធទាំងសងខាង ពុំចាំបាច់ធ្វើការបង្ហាញឆន្ទៈព្រមព្រៀងកំណត់យកប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់មកអនុវត្តនោះទេ ដរាបណាពួកគេពុំបានបង្កើតនូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា) នោះច្បាប់នឹងចាត់ទុកថាពួកគេអនុវត្តនូវប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់ ដោយស្វ័យប្រវត្តិ។

### **កថាខណ្ឌទី២ ការកំណត់គុណវឌ្ឍន៍នៃទ្រព្យ** (**ប្រភេទនៃទ្រព្យ**)

នៅក្នុងអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិគឺជា កត្តាសំខាន់មួយក្នុងចំណោមកត្តាសំខាន់ដទៃទៀតដែលធ្វើឲ្យចំណងអាពាហ៍ពិពាហ៍នោះមានភាពរឹងមាំ។ មិនថាសហព័ទ្ធជ្រើសរើសយកប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់ ឬតាមកិច្ចសន្យាក៏ដោយ ក៏ច្បាប់តម្រូវឲ្យពួកគេមានការបែងចែកឲ្យជាក់លាក់នូវទ្រព្យណាដែលជាទ្រព្យដោយឡែក និងទ្រព្យណាដែលជាទ្រព្យរួម។ សម្រាប់ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ច្បាប់តម្រូវឲ្យពួកគេព្រមព្រៀងគ្នាបង្កើតនូវកិច្ចសន្យាមួយដែលមានការចែងច្បាស់នូវទ្រព្យសម្បត្តិរបស់ពួកគេ ជាលាយលក្ខណ៍អក្សរ និងមានការចុះបញ្ជីយ៉ាងត្រឹមត្រូវនៅក្រសួងយុត្តិធម៌ (ផ្នែកទី១)។ ប៉ុន្តែសម្រាប់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់វិញ ទ្រព្យសម្បត្តិរបស់សហព័ទ្ធគឺមានការសន្មតតាមច្បាប់តែម្តង ដោយអនុលោមតាមមាត្រា៩៧២ ទ្រព្យសម្បត្តិដោយឡែក (២.១) និងមាត្រា៩៧៣ ទ្រព្យសម្បត្តិរួម (២.២) នៃក្រមរដ្ឋប្បវេណី។

#### **២.១. ទ្រព្យសម្បត្តិដោយឡែក**

ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ ត្រូវបានកំណត់នៅក្នុងមាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី ដែលរាល់ប្រភេទទ្រព្យដែលមានចែងនៅក្នុងមាត្រានេះ នឹងចាត់ចូលជាប្រភេទទ្រព្យ

[៩៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៥៤។

សម្បត្តិដោយឡែកតែម្តង។ គោលគំនិតរបស់ច្បាប់ ក្នុងការតាក់តែងបញ្ញត្តិមាត្រានេះឡើងគឺដោយសារ តែប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់ ជាក់ស្តែងណាស់គឺពុំមាននូវការព្រមព្រៀង តាក់តែង និងចងក្រងនូវលក្ខខណ្ឌណាមួយពីសហព័ទ្ធ អំពីទ្រព្យសម្បត្តិរបស់ពួកគេឡើយ ដូច្នេះហើយ ដើម្បីជៀសវាងនូវវិវាទណាមួយ អំឡុងពេលអាពាហ៍ពិពាហ៍ និងនៅក្រោយពេលលែងលះ ទើបច្បាប់សម្រេចកំណត់នូវប្រភេទទ្រព្យទាំងនោះឲ្យពួកគេតែម្តង។

តាមមាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី ចំណុច ក ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ។ ជាការពិតណាស់ ទ្រព្យសម្បត្តិដែលភាគីណាម្ខាងមាន ឬខិតខំប្រឹងប្រែងរកបានមុនពេលរៀបការ គឺជាទ្រព្យសម្បត្តិដោយឡែករបស់គេ ព្រោះជាក់ស្តែង ទ្រព្យសម្បត្តិទាំងនេះ គឺពុំមានការចូលរួមពីសហព័ទ្ធម្ខាងទៀតក្នុងនាមជាប្តី ឬប្រពន្ធរបស់គេទេ ដូច្នេះបើចាត់ចូលប្រភេទទ្រព្យសម្បត្តិនេះ ទៅក្នុងទ្រព្យសម្បត្តិរួមដែរនោះ វាហាក់បីដូចជាមានភាពអយុត្តិធម៌ចំពោះភាគីដែលបានរកនូវទ្រព្យសម្បត្តិទាំងនេះពេក។ ទ្រព្យសម្បត្តិទាំងនោះអាចមានដូចជា ចលនវត្ថុ (ឡាន លុយ) ឬ អចលនវត្ថុ (ផ្ទះ ដី)....។ល។ ដែលសហព័ទ្ធណាម្ខាងមានមុនពេលរៀបអាពាហ៍ពិពាហ៍ជាមួយសហព័ទ្ធម្ខាងទៀត។

ឧទាហរណ៍: លោកភក្តី មានផ្ទះមួយខ្នង ឡានមួយគ្រឿង (ដែលនៅជាប់បង់រំលោះក្រុមហ៊ុន) និងលុយសុទ្ធចំនួន១០ម៉ឺនដុល្លា ក្រោយមកលោកបានជួបនឹងនារីម្នាក់ឈ្មោះកញ្ញា ពួកគេបានរៀបការជាមួយគ្នានៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។ ដូច្នេះ រាល់ទ្រព្យសម្បត្តិដែលលោកភក្តីមាន នៅមុនថ្ងៃទី០១ ខែ មករា ឆ្នាំ២០១៨ ដែលជាថ្ងៃរៀបអាពាហ៍ពិពាហ៍របស់លោកជាមួយនឹងលោកស្រីកញ្ញា គឺជាទ្រព្យសម្បត្តិដោយឡែករបស់លោកភក្តី។ យ៉ាងណាមិញ នៅពេលដែលគេនិយាយពីទ្រព្យសម្បត្តិ គេភាគច្រើនសម្លឹងមើលតែទ្រព្យដែលភាគីមានសិទ្ធិចាត់ចែង ឬប្រើប្រាស់ ឬអាស្រ័យផល ប៉ុន្តែជាក់ស្តែង ពាក្យថាទ្រព្យសម្បត្តិគឺ មានអត្ថន័យក្តោបទាំងទ្រព្យដែលជាសិទ្ធិ និងទ្រព្យដែលជាកាតព្វកិច្ចរបស់ភាគីដែលនឹងត្រូវបំពេញ។ សម្រាប់ភាសាច្បាប់ ទ្រព្យទាំងឡាយណាដែលជាសិទ្ធ គេហៅថាទ្រព្យសកម្ម និងទ្រព្យទាំងឡាយណាដែលជាកាតព្វកិច្ច គេហៅថាទ្រព្យអកម្ម។ ខាងក្រោមនេះ នឹងពន្យល់បកស្រាយលម្អិតអំពីប្រភេទទ្រព្យសកម្ម និងទ្រព្យអកម្ម។

**ទ្រព្យសកម្ម:** គឺជាទ្រព្យដែលកម្មសិទ្ធិករ អាចទទួលផលប្រយោជន៍បានពីវាដោយសារការយកទ្រព្យនោះទៅប្រើប្រាស់ ចាត់ចែង ឬអាស្រ័យផលជាអាទិ៍។ នៅពេលគេនិយាយពីទ្រព្យសកម្ម ជាធម្មតាយើងអាចសន្មតបានទុកជាមុនថាទ្រព្យទាំងនោះ ប្រាកដជាមានដូចជាផ្ទះ ឡាន ដីធ្លី ឬអចលនវត្ថុផ្សេងៗដែលកម្មសិទ្ធិករមានសិទ្ធិពេញលេញក្នុងការចាត់ចែងទ្រព្យទាំងនោះ

បាន។ ឧទាហរណ៍ ផ្ទះដែលលោកភក្តីទិញដាច់ពីម្ចាស់ផ្ទះចាស់ នោះគឺជាទ្រព្យដោយឡែកសកម្ម របស់លោក ព្រមទាំងលុយសុទ្ធ១០ម៉ឺនដុល្លារបស់លោកផងដែរ។

**ទ្រព្យអកម្មៈ** គឺជាទ្រព្យដែលកម្មសិទ្ធិករ ត្រូវបំពេញកាតព្វកិច្ចចំពោះវាវិញ ពោលគឺ ជាបំណុល ដែលកូនបំណុល ត្រូវបំពេញកម្មវត្ថុទៅឲ្យម្ចាស់បំណុល ក្នុងន័យនេះកម្មសិទ្ធិករពុំបាន ទទួលផលប្រយោជន៍ពីវាទេ ប៉ុន្តែត្រូវមានកាតព្វកិច្ចចំពោះវាទៅវិញ។ ឧទាហរណ៍ ឡានរបស់ លោកភក្តី ដែលកំពុងជាប់ការបង់រំលោះនៅក្រុមហ៊ុន គឺជាទ្រព្យអកម្ម ដោយសារតែលោកត្រូវសង បំណុលទាំងនោះឲ្យគ្រប់ចំនួន ដូច្នេះការបង់រំលោះឡាននោះ គឺជាទ្រព្យសម្បត្តិដោយឡែកអកម្ម របស់លោកភក្តី។

បញ្ញត្តិនេះ នឹងត្រូវយកមកអនុវត្តដូចគ្នាចំពោះចំណុចដទៃទៀត នៅក្នុងចំណុចទ្រព្យសម្បត្តិ ដោយឡែកនេះ។

តាមបញ្ញត្តិមាត្រា៩៧២ ចំណុចខ នៃក្រមដដែលនេះ ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយ**ប្រទានកម្ម សន្តតិកម្ម អច្ច័យទាន** នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ក៏ត្រូវបានចាត់ចូលជា ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធដែរ។ នៅក្នុងក្រមរដ្ឋប្បវេណីនេះផងដែរ ត្រង់មាត្រា៥៦៨ បានឲ្យនិយមន័យពាក្យថា **ប្រទានកម្ម** សំដៅទៅលើកិច្ចសន្យាមួយ ដែលត្រូវមានអានុភាព ដោយ ភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឲ្យភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាង ទៀតយល់ព្រមទទួល។ ដោយសារលក្ខណៈពិសេសនៃប្រទានកម្ម គឺទាយក (ភាគីម្ខាងនៃកិច្ច សន្យាប្រទានកម្ម ដែលបង្ហាញឆន្ទៈផ្តល់ទៅឲ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ)[៩៤] មានឆន្ទៈ ចង់ផ្តល់នូវកម្មវត្ថុណាមួយ មកឲ្យបដិគ្គាហក (អ្នកដែលទទួលយកអំណោយ ឬភាគីម្ខាង នៃកិច្ចសន្យាប្រទានកម្ម ដែលយល់ព្រមទទួលយកនូវទ្រព្យសម្បត្តិពីទាយក ដោយមិនផ្តល់តម្លៃតប ស្នង)[៩៥] ដោយសណ្តានចិត្ត ពុំត្រូវការការតបស្នងណាមួយពីភាគីម្ខាងទៀត ទើបច្បាប់យល់ឃើញ ថា រាល់ទ្រព្យដែលសហព័ទ្ធទទួលបានពីការធ្វើប្រទានកម្ម ពីតតិយជនណាមួយនោះ គប្បីចាត់វា ចូលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងនោះ ព្រោះដើម្បីគោរពដល់អ្នកបង្ហាញឆន្ទៈក្នុង ការឲ្យ ឬប្រគល់វត្ថុនោះទៅឲ្យសហព័ទ្ធណាម្ខាងជាចាំបាច់។

ក្នុងនោះផងដែរ **សន្តតិកម្ម** ក៏ជាចំណែកមួយដែលសហព័ទ្ធទទួលបានជាទ្រព្យសម្បត្តិ ដោយឡែកផងដែរ។ តាមន័យរបស់សន្ធានុក្រម ផ្នែករដ្ឋប្បវេណី បានឲ្យនិយមន័យលើពាក្យ **សន្តតិកម្ម** គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់

[៩៤] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខ៥៣ ទំព័រ៨។
[៩៥] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខ៨២ ទំព័រ១២។

តាមឆន្ទៈ ឬតាមច្បាប់។ ដោយសារសន្តតិកម្ម គឺជាការកំណត់របស់ច្បាប់ ពោលគឺបើទោះបីជាមតកជន (ជនដែលបានស្លាប់ទៅហើយ)[៩៦] ពុំបានសរសេរលិខិតបណ្តាំ អំពីអ្នកដែលទទួលទ្រព្យសម្បត្តិរបស់គាត់មុនពេលចែកឋានទៅទេ នោះច្បាប់នឹងធ្វើការបែងចែកអោយ ដោយផ្អែកតាមក្រមរដ្ឋប្បវេណី គន្ថីទី៨ ស្តីអំពីសន្តិកម្មផងដែរ។ សម្រាប់សន្តតិកម្មដែលធ្វើឡើងដោយផ្អែកតាមឆន្ទៈរបស់មតកជន ត្រូវបានគេហៅថា សន្តតិកម្មមានបណ្តាំ ឬមតកសាសន៍ និងសម្រាប់សន្តតិកម្មដែលមិនមានការបង្ហាញឆន្ទៈពីមតកជននោះទេ ពោលគឺតាមបញ្ញត្តិនៃច្បាប់កំណត់ ត្រូវបានគេហៅថា សន្តតិកម្មតាមច្បាប់។[៩៧] យ៉ាងណាមិញ បើទោះបីជាការទទួលបានទ្រព្យសម្បត្តិណាមួយពីមតកជន តាមរយៈសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមបណ្តាំក៏ដោយ ក៏ទ្រព្យដែលសន្តតិជន (ជនដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម)[៩៨] ទទួលបាននោះ ក្នុងប្រភេទជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនដែរ។ នេះដោយសារតែ គោលគំនិតច្បាប់ អោយតម្លៃទៅលើការបង្ហាញឆន្ទៈរបស់មតកជនជាធំ ពោលគឺដើម្បីសម្រេចបំណងប្រាថ្នារបស់ខ្លួន បន្ទាប់ខ្លួនបានទទួលមរណភាពទៅ ទើបច្បាប់យល់ថា ទ្រព្យដែលសហព័ទ្ធណាម្ខាងទទួលបានពីសន្តតិកម្ម គឺជាទ្រព្យសម្បត្តិពិសេស គប្បីចាត់ចូលជាទ្រព្យសម្បត្តិដោយឡែក។

មិនខុសពីប្រទានកម្ម និងសន្តតិកម្ម **អច្ច័យទាន** ក៏ត្រូវបានគេសន្មតថាជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធនៅពេលដែលគេទទួលបានពីតតិយជន។ **អច្ច័យទាន** គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។[៩៩] អនុលោមតាមមាត្រា១១៩៩ បានបែងចែក និងឲ្យនិយមន័យអច្ច័យទានជាពីរ គឺអច្ច័យទានសកលគឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគ។ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់ដោយមតកសាសន៍។ ទោះជាយ៉ាងនេះក្តី ទ្រព្យសម្បត្តិដែលសហព័ទ្ធ នឹងទទួលបានតាមរយៈអច្ច័យទាន ទោះជាជាអច្ច័យទានសកលក្តី ឬអច្ច័យទានមានកំណត់ក្តី ក៏ច្បាប់ចាត់ទុកនូវទ្រព្យសម្បត្តិទាំងនោះ ក្នុងន័យជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនដែរ។ សរុបមក បើយើងពិនិត្យមើលទៅលើលក្ខណៈសម្បត្តិរបស់ទ្រព្យសម្បត្តិដោយឡែកក្នុងចំណុចខ មាត្រា៩៧២នេះ យើងឃើញថា ទាំងប្រទានកម្ម សន្តតិកម្ម និងអច្ច័យទាន គឺភាគច្រើនសុទ្ធតែកើតឡើងពីការបង្ហាញឆន្ទៈរបស់បុគ្គលដែលជា ទាយក មតកជន និងម្ចាស់បណ្តាំ ក្នុង

[៩៦] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខ១១៧ ទំព័រ១៧។
[៩៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ឆ្នាំ២០០៧ មាត្រា ១១៥៥។
[៩៨] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខ១៨៤ ទំព័រ ២១។
[៩៩] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខ១៧៧ ទំព័រ ២៦។

ការប្រគល់នូវទ្រព្យសម្បត្តិណាមួយ ទៅឲ្យបុគ្គលណាម្នាក់។ ដូច្នេះហើយ តាម**គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន**[៥០] ក្រមរដ្ឋប្បវេណី បានឲ្យតម្លៃ និងគោរពជាខ្លាំងទៅលើសេរីភាពនៃឆន្ទៈរបស់បុគ្គល ក្នុងការសម្រេចចិត្ត លើប្រតិបត្តិការណាមួយ។ ជាហេតុ ធ្វើឲ្យមានតែបុគ្គលដែលជាម្ចាស់ប្រទានកម្ម ឬម្ចាស់មរតក បង្ហាញឆន្ទៈប្រគល់នូវទ្រព្យសម្បត្តិណាមួយទៅឲ្យបុគ្គលនោះតែប៉ុណ្ណោះ ទើបបុគ្គលនោះមានសិទ្ធិទទួលបាននូវផលប្រយោជន៍ ឬកាតព្វកិច្ចណាមួយជាដាច់ខាត។ ដោយសារហេតុនេះហើយ ទោះបីជាទ្រព្យសម្បត្តិទាំងនោះបានកើតឡើងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ក៏វានៅតែជាប្រភេទទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ ដដែល។

តាមបញ្ញត្តិមាត្រា៩៧២ ចំណុចគ នៃក្រមរដ្ឋប្បវេណី បានកំណត់ទៀតផងដែរ ថារាល់ទ្រព្យសម្បត្តិដែលជាតម្លៃតប ពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក ដែលមានចែងនៅក្នុងចំណុចក និងខ នៃមាត្រាដដែលនេះ ក៏នៅតែជាទ្រព្យសម្បត្តិដោយឡែកដដែល។ ពាក្យថា**ជាតម្លៃតប ពីការចាត់ចែង** នៅក្នុងភាសាច្បាប់ គឺចង់សំដៅ ទៅលើការលក់ ប្រទានកម្ម ឬការដូរ ដែលជាទ្រព្យដោយឡែក (ក្នុងចំណុចក និងខ) ដើម្បីជាប្រយោជន៍ ឬក្នុងគោលបំណងណាមួយរបស់សហព័ទ្ធ។ ក្នុងនេះផងដែរ ក៏មានមតិមួយចំនួន លើកឡើងអំពីចម្ងល់ថា ក្នុងករណីដែលសហព័ទ្ធ បានប្រើប្រាស់ទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនដើម្បីយកទៅជួល តើវាជាសកម្មភាពនៃការចាត់ចែងទ្រព្យនេះដែរឬទេ? នៅក្នុងន័យច្បាប់ ប្រាក់ឈ្នួលពុំមែនជាតម្លៃតបដែលបានមកពីការចាត់ចែង នោះទេពោលគឺច្បាប់ពុំបានកំណត់ថា ប្រាក់ដែលបានមកពីការដាក់ជួលទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ គឺមិនមែនជាទ្រព្យសម្បត្តិដោយឡែកនោះទេ គឺវានៅតែជាទ្រព្យសម្បត្តិរួមដដែល។ ដូច្នេះ ក្នុងមាត្រានេះ តម្លៃតបដែលបានមកពីការចាត់ចែង ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ គឺមានដូចជា ការលក់ ការដូរ ឬការធ្វើប្រទានកម្មទៅឲ្យតតិយជនជាដើម។

យ៉ាងណាមិញ បើទោះបីជានៅក្នុងមាត្រា៩៧២ ទ្រព្យសម្បត្តិដោយឡែក ពុំបានចែងអំពីសិទ្ធិដែលមានលក្ខណៈផ្ទាល់ខ្លួនសម្រាប់សហព័ទ្ធក៏ដោយ ក៏យើងគប្បីគួរកត់សម្គាល់ផងដែរថា ទ្រព្យដែលបានមកពីសិទ្ធិផ្តាច់មុខរបស់សហព័ទ្ធ ដែលមានដូចជាសិទ្ធិទទួលបាននូវអាហារកាតព្វកិច្ចជាដើម ក៏ច្បាប់បានចាត់ទុកថាវាជាទ្រព្យដោយឡែករបស់សហព័ទ្ធផងដែរ ដោយពុំអាចយកមកបែងចែងជាមួយនឹងទ្រព្យរួមបានឡើយ។ ក្នុងន័យនេះ មានន័យថា បើសិនជាសហព័ទ្ធណាម្ខាងបានទទួលអាហារកាតព្វកិច្ចនៅមុនពេលរៀបអាពាហ៍ ឬកំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ក៏ប្រាក់នោះជាទ្រព្យដោយឡែករបស់សហព័ទ្ធនោះ តែក្នុងករណីកំឡុងអាពាហ៍ពិពាហ៍ប្រាក់ដែលគេទទួលបាននោះ ត្រូវប្រើប្រាស់ជាទ្រព្យរួម ដោយឡែកសម្រាប់ពេលលែងលះ អាហារ

[៥០] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣។

កាតព្វកិច្ចពុំត្រូវបានបែងចែកទៅឲ្យសហព័ទ្ធម្ខាងទៀតបានឡើយ។ ឧទាហរណ៍ សហព័ទ្ធម្ខាងបានទទួលនូវអាហារកាតព្វកិច្ចពី ម្ដាយរបស់គាត់ជារៀងរាល់ខែ ចំនួន៥០០ដុល្លាអាមេរិក ដូច្នេះទ្រព្យនេះជាទ្រព្យដោយឡែករបស់គាត់ បើទោះបីជាពេលគាត់រៀបអាពាហ៍ពិពាហ៍ទ្រព្យនេះគាត់អាចយកមកប្រើប្រាស់ជាទ្រព្យរួមក៏ដោយ ក៏នៅពេលដែលលែងលះ សហព័ទ្ធម្ខាងទៀតពុំអាចទទួលបាននូវអាហារកាតព្វកិច្ចដោយចែកជាពីរបានទេ ពោលគឺ គេពុំអាចយកមកចែកគ្នាមួយខែទទួលបានម្នាក់៥០០ដុល្លាអាមេរិក ពីម្ដាយរបស់សហព័ទ្ធម្ខាងណានោះបានឡើយ។[៥១]

សរុបមក សម្រាប់ទ្រព្យសម្បត្តិដោយឡែក ក៏មានការកំណត់ប្រភេទថាលក្ខណៈទ្រព្យសម្បត្តិណាជាទ្រព្យសកម្ម និងលក្ខណៈទ្រព្យសម្បត្តិណាជាទ្រព្យអកម្មផងដែរ ដោយអនុលោមទៅតាមលក្ខខណ្ឌដែលបានបកស្រាយពីនិយមន័យ នៃទ្រព្យសកម្ម (ជាសិទ្ធិ) និងទ្រព្យអកម្ម (ជាកាតព្វកិច្ច ឬបំណុល) នៅខាងដើមផងដែរ។ ច្បាប់ពុំបានបកស្រាយឲ្យលម្អិត ថាតើទ្រព្យអ្វីជាទ្រព្យសកម្ម ឬទ្រព្យអ្វីជាទ្រព្យអកម្មឡើយ ប៉ុន្តែច្បាប់បានកំណត់អំពីវិសាលភាព ប្រយោជន៍ និងកាតព្វកិច្ចរបស់កម្មសិទ្ធិករ ដោយឲ្យយើងជាអ្នកវិភាគ យកទៅអនុវត្ត ទៅតាមករណីខុសៗគ្នានីមួយៗ តែត្រូវផ្អែកទៅតាមគោលគំនិតច្បាប់ដដែល។

### ២.២ ទ្រព្យសម្បត្តិរួម

តាមបញ្ញត្តិមាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី បានកំណត់ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្ដីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុងចំណុចខ និងចំណុចគ នៃមាត្រា៩៧២នៃក្រមដដែល។ ជាមួយគ្នាផងដែរ ទ្រព្យសម្បត្តិដែលជាតម្លៃតប(ដែលមិនមែនបានមកពីការចាត់ចែង) នៃទ្រព្យសម្បត្តិដោយឡែក ក៏ចាត់ចូលជាទ្រព្យសម្បត្តិរួមផងដែរ។ ពោលប្រសិនបើទ្រព្យដែលបានមកពីការជួល ឬអាចទាញប្រយោជន៍ចេញពីទ្រព្យសម្បត្តិដោយឡែក ដោយពុំបានធ្វើឲ្យបាត់បង់នូវទ្រព្យដោយឡែកនោះទេ (មិនមែនជាការចាត់ចែង) នោះទ្រព្យនោះ នឹងត្រូវចាត់ចូលជាទ្រព្យសម្បត្តិរួម។ ជាឧទាហរណ៍ នៅពេលដែលលោកភក្តី បានរៀបការជាមួយអ្នកនាងកញ្ញារួច លោកក៏ដាក់ជួលផ្ទះរបស់លោក ដើម្បីទ្រទ្រង់ជីវភាពរស់នៅក្នុងក្រុមគ្រួសារ ក្នុងន័យនេះ លុយដែលបានមកពីការដាក់ជួលផ្ទះដែលជាទ្រព្យសម្បត្តិដោយឡែករបស់លោក ត្រូវក្លាយជាទ្រព្យសម្បត្តិរួម។ ម្ដងទៀតផងដែរ រាល់ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួម ក្នុងនោះ ក៏រាប់បញ្ចូលទាំងប្រាក់ខែ ប្រាក់ចំណូលរបស់សហា

[៥១] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, *សៀវភៅជំនួយស្មារតី, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, (ភ្នំពេញ៖ ពេងពុម្ពជោគជ័យ, ២០១៧), ៣៥៨។

ព័ទ្ធ នៅពេលដែលពួកគេបានរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ។ ប៉ុន្តែ មានមតិមួយចំនួនមានចម្ងល់ទៅលើករណី ដែលសហាព័ទ្ធណាម្ខាង ជាកម្មសិទ្ធិករ លើក្រុមហ៊ុន ឬភោជនីយដ្ឋានជាឧទាហរណ៍ ក្នុងន័យនេះ គេគិតអំពីថ្ងៃខែឆ្នាំដែលសហាព័ទ្ធបានរៀបអាពាហ៍ពិពាហ៍ ដោយចាត់ចូលប្រាក់ចំណេញនៃភោជនីយដ្ឋាន ឬក្រុមហ៊ុននោះទទួលបានចាប់តាំងពីថ្ងៃដែលសហាព័ទ្ធរៀបការ គឺជាទ្រព្យសម្បត្តិរួម ប៉ុន្តែក្រុមហ៊ុន ឬភោជនីយដ្ឋាននោះ នៅតែជាទ្រព្យសម្បត្តិដោយឡែករបស់សហាព័ទ្ធដែលជាម្ចាស់កម្មសិទ្ធិនោះដដែល។

គោលបំណងរបស់ច្បាប់ បានកំណត់យ៉ាងច្បាស់អំពីទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួមរបស់សហាព័ទ្ធ ប៉ុន្តែ ច្បាប់ក៏បានប្រកាន់នូវគោលការណ៍ សាមគ្គីភាព របស់សហាព័ទ្ធនៅពេលដែលពួកខ្លួនបានរៀបអាពាហ៍ពិពាហ៍រួច ទើបទ្រព្យដែលទាញចេញពីប្រយោជន៍ទ្រព្យសម្បត្តិដោយឡែក នឹងក្លាយទៅជាទ្រព្យសម្បត្តិរួម លើកលែងតែទ្រព្យនោះបានមកពីការចាត់ចែង (លក់) ទ្រព្យសម្បត្តិដោយឡែក ទើបវានៅតែជាទ្រព្យសម្បត្តិដោយឡែករបស់សហាព័ទ្ធណាម្ខាងនោះដដែល។ នៅក្នុងផ្នែកទ្រព្យសម្បត្តិរួមរបស់សហាព័ទ្ធនេះផងដែរ យើងអ្នកសិក្សាគប្បីគួរបែងចែកឲ្យដាច់នូវទ្រព្យសម្បត្តិសកម្ម និងទ្រព្យសម្បត្តិអកម្ម។ មិនខុសពីនៅក្នុងផ្នែកទ្រព្យសម្បត្តិដោយឡែកទេ ទ្រព្យសម្បត្តិរួម ក៏នៅមានទ្រព្យខ្លះជាទ្រព្យដែលសហាព័ទ្ធមានសិទ្ធិក្នុងការចាត់ចែង ប្រើប្រាស់ និងអាស្រ័យផល (ទ្រព្យសកម្ម) ហើយទ្រព្យខ្លះ ជាទ្រព្យដែលសហាព័ទ្ធទាំងសងខាងមានកាតព្វកិច្ចតបស្នងទៅកាន់ម្ចាស់បំណុលវិញផងដែរ (ទ្រព្យអកម្ម)។ បានបញ្ជាក់ពីខាងដើមរួចមកហើយ ទ្រព្យសកម្ម គឺជាទ្រព្យដែលសហាព័ទ្ធទាំងសងខាង មានសិទ្ធិក្នុងការទាញផលប្រយោជន៍ពីវា ចំណែកឯទ្រព្យអកម្ម គឺជាកាតព្វកិច្ចដែលសហាព័ទ្ធដើម្បីអនុវត្តទៅតតិយជនណាម្នាក់វិញ។ ប៉ុន្តែ ចំណុចខុសប្លែករវាងចំណុចទាំងពីរនេះគឺនៅត្រង់ ទ្រព្យសកម្មដោយឡែក គឺសហាព័ទ្ធណាម្ខាងមានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ និងចាត់ចែងតាមការប៉ងរបស់ខ្លួនបានដោយសេរី ពោលគឺសម្រាប់ខ្លួនឯង ឬក្រុមគ្រួសារ ក៏ដូចគ្នាទៅនឹងទ្រព្យអកម្មដោយឡែក សហាព័ទ្ធម្ខាងនោះមានកាតព្វកិច្ចក្នុងការអនុវត្តទៅកាន់ម្ចាស់បំណុលរបស់ខ្លួន រីឯទ្រព្យសម្បត្តិរួមនេះ សហាព័ទ្ធទាំងសងខាង មានសិទ្ធិ និងកាតព្វកិច្ចជាមួយគ្នា ទៅវិញទៅមក ទាំងទ្រព្យសម្បត្តិរួមអកម្ម និងទ្រព្យសម្បត្តិរួមសកម្ម។

ជាមួយគ្នានេះដែរ មានការបកស្រាយ និងលើកអំណះអំណាងថា ទ្រព្យសម្បត្តិរួម មានចរិតលក្ខណៈ ស្រដៀងគ្នាទៅនឹងកម្មសិទ្ធិអវិភាគ ដែលមានចែងក្នុងបញ្ញត្តិមាត្រា២០២ នៃក្រមរដ្ឋប្បវេណី ត្រង់សហកម្មសិទ្ធិករ មានកម្មសិទ្ធិស្របទៅតាមសមាមាត្រ នៃចំណែករបស់ខ្លួន។ ក្នុងន័យនេះ មានន័យថាសហាព័ទ្ធ ដែលជាសហម្ចាស់កម្មសិទ្ធិ មានសិទ្ធិ និងករណីយកិច្ច ក្នុងការប្រើប្រាស់ ថែទាំ គ្រប់គ្រង លើទ្រព្យសម្បត្តិរួមរបស់ពួកគេ។ ប៉ុន្តែចំណុចដែលមានលក្ខណៈពិសេស

និងខុសប្លែកពីកម្មសិទ្ធិអវិភាគ គឺនៅត្រង់ថា ទ្រព្យសម្បត្តិរួម តម្រូវឲ្យមានការយល់ព្រម (ឬផ្តល់សច្ចានុមតិ) ពីសហាព័ទ្ធម្ខាងទៀត មុនសហាព័ទ្ធម្ខាងណានោះ អាចធ្វើការចាត់ចែងបាន ឬមានការអនុញ្ញាតពីសេចក្តីសម្រេចរបស់តុលាការផងដែរ។[៥២] ចំណុចបន្តបន្ទាប់ទៅនេះ នឹងធ្វើការបកស្រាយលម្អិតបន្ថែម ទៅលើអានុភាពនៃទ្រព្យសម្បត្តិរបស់សហាព័ទ្ធ ទាំងសិទ្ធិ និងករណីយកិច្ចរបស់ពួកគេ។

## ផ្នែកទី២ អានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់

អនុលោមតាមមាត្រា៩៧១ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត។ សោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ មានដូចជា ថ្លៃម្ហូបអាហារ ថ្លៃភ្លើង ថ្លៃទឹក ថ្លៃហ្គាស ថ្លៃព្យាបាល ថ្លៃថែទាំកូន ថ្លៃសិក្សារបស់កូន និងផ្សេងៗទៀត។[៥៣] ដូច្នេះនៅពេលដែលប្តីប្រពន្ធ តម្រូវឲ្យមានការជួយសង្គ្រោះគ្នាទៅវិញទៅមក សម្រាប់ជីវភាពប្រចាំថ្ងៃទាំងនេះហើយនោះ ការដឹងច្បាស់អំពីទ្រព្យសម្បត្តិរួម និងដោយឡែករបស់ពួកគេ មានភាពចាំបាច់សម្រាប់ការប្រើប្រាស់ និងចាត់ចែងផ្សេងៗ ចៀសវាងការបង្ករឲ្យមានវិវាទនឹងគ្នានៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ដោយសារហេតុនេះហើយ ទើបច្បាប់មានគោលបំណងក្នុងការកំណត់នូវករណីយកិច្ចនានា សម្រាប់សហាព័ទ្ធបំពេញនៅពេលដែលពួកគេរួមរស់នៅជាមួយគ្នា។ ម៉្យាងក៏ដោយសារករណីយកិច្ចដែលកំណត់ដោយច្បាប់បែបនេះ មានភាពគត់មុតជាងកាតព្វកិច្ចដែលកំណត់ដោយគូរភាគី (សហាព័ទ្ធទាំងសងខាង) ព្រោះជាកាតព្វកិច្ចដែលច្បាប់តម្រូវការបំពាន នូវកាតព្វកិច្ចណាមួយ ភាគីដែលទទួលរងនូវការបំពាន មានសិទ្ធិទាមទារសំណងមកវិញបាន។

សរុបមក កាលណាលក្ខខណ្ឌមានកំណត់នៅក្នុងច្បាប់ ពួកគេនឹងទទួលស្គាល់ថា វាជាកាតព្វកិច្ចចាំបាច់ដែលត្រូវតែធ្វើ និងងាយស្រួលឲ្យតុលាការងាយវិនិច្ឆ័យ សម្រេចសេចក្តីលើករណីដែលពួកគេសុំតុលាការចេញសេចក្តីសម្រេចណាមួយ នៅពេលដែលពួកគេពុំអាចពិភាក្សាអំពីការគ្រប់គ្រង ប្រើប្រាស់, ចាត់ចែងទ្រព្យសម្បត្តិរួម ទាំងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងក្រោយពេលលែងលះ។

កថាខណ្ឌបន្ទាប់ទៅនេះ នឹងបកស្រាយអំពី ចំណាត់ការលើទ្រព្យសម្បត្តិ (កថាខណ្ឌទី១) និងការទទួលខុសត្រូវលើកាតព្វកិច្ច (កថាខណ្ឌទី២) របស់សហាព័ទ្ធ ។

---

[៥២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៦។
[៥៣] កម្រងមេរៀន រៀបរៀងឡើងដោយវិភាគទានច្បាប់ ឆ្នាំ២០១៧, ៤៦។

**កថាខណ្ឌទី១ ចំណាត់ការទ្រព្យសម្បត្តិ**

នៅក្នុងក្រមរដ្ឋប្បវេណី ផ្នែកទី៣ ប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធ មាត្រា៩៧៤ មាត្រា៩៧៦ និងមាត្រា៩៧៧ បានកំណត់អំពីកាតព្វកិច្ចដែលសហព័ទ្ធមានចំពោះគ្នាទៅវិញទៅមក សហការគ្នាដោយសាមគ្គីភាព សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់គ្រួសារទាំងមូល។ យ៉ាងណាមិញ បើទោះបីទាំងនេះជាកាតព្វកិច្ចត្រូវតែធ្វើឲ្យគ្នាទៅវិញទៅមកក៏ដោយ ប៉ុន្តែបើប្តីប្រពន្ធទាំងសងខាង បានព្រមព្រៀងគ្នា សម្របសម្រួល ឬយល់ព្រមនូវការសម្រេចចិត្តរបស់សហព័ទ្ធណាម្ខាងដោយសន្តិវិធីនោះ ច្បាប់ក៏មិនមានការចាប់បង្ខំឲ្យពួកគេត្រូវតែធ្វើជាកំហិតនោះដែរ ព្រោះក្រមរដ្ឋប្បវេណី គោរពតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនជាធំ ដូច្នេះ បើទោះបីជាគ្មាន ឬមានកំណត់នៅក្នុងច្បាប់ក៏ដោយ ក៏ការស្មគ្រចិត្តរបស់ភាគី នៅតែយកមកអនុវត្តដដែលនៅក្នុងន័យនេះ។ ចំណុចបន្ទាប់ នឹងបកស្រាយអំពីទំហំនៃការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួម (១.១) ការអាស្រ័យនៅលើទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ (១.២) និងការចាត់ចែងទ្រព្យរួម (១.៣)។

**១.១. ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរួម**

អនុលោមតាមមាត្រា៩៧៤ កថាខណ្ឌ១ ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន។ នៅក្នុងកថាខណ្ឌនេះ ច្បាប់មានបំណង បើកសិទ្ធិឲ្យសហព័ទ្ធទាំងសងខាង មានសិទ្ធិស្មើគ្នា ទៅលើទ្រព្យរួម ពោលគឺទំហំនៃការប្រើប្រាស់ គ្រប់គ្រង គប្បីមានការយល់ព្រមពីសហព័ទ្ធ ឬមានមតិរួមក្នុងការយកទ្រព្យសម្បត្តិរួម ទៅប្រើប្រាស់ក្នុងគោលដៅផ្សេងៗ និងចៀសវាងនូវការចម្រូងចម្រះគ្នា។ មួយវិញទៀតសោត បើទោះបីជាការរៀបអាពាហ៍ពិពាហ៍ មានគោលបំណង ឲ្យសហព័ទ្ធមានសាមគ្គីភាពជាមួយគ្នាទៅវិញទៅមកលើការរស់នៅជាជីវភាពប្តីប្រពន្ធក្តី ក៏ច្បាប់ពុំធ្វេសប្រហែសទៅលើការបើកសិទ្ធិឲ្យសហព័ទ្ធអាចប្រើប្រាស់ ទទួលផលប្រយោជន៍ និងការគ្រប់គ្រងផ្សេងៗលើទ្រព្យសម្បត្តិដោយឡែករបស់ពួកគេដែរ ព្រោះនៅក្នុងអាពាហ៍ពិពាហ៍ ទោះបីជាសហព័ទ្ធប្រើប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាក្តី ឬប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់ក្តី ក៏ពួកគេនូវតែទទួលបាននូវការបែងចែកយ៉ាងច្បាស់អំពីទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែករបស់គេ ដូច្នេះ បើទោះបីជាពេលខ្លះទ្រព្យទាំងពីរនេះមានភាពលំបាកក្នុងការញែកពីគ្នា នៅពេលអនុវត្តក្តី ក៏ច្បាប់នូវតែការពារប្រយោជន៍របស់បុគ្គលនោះយ៉ាងម៉ឺងម៉ាត់ ដរាបណាពួកគេមានភស្តុតាងបញ្ជាក់អំពីទ្រព្យដោយឡែកនោះ។

នៅក្នុងមាត្រាដដែល ច្បាប់បានកំណត់ឲ្យសហព័ទ្ធ មានការសហការគ្នា ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរួម និងសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យរួមនោះ ក្នុងទំហំមួយដែលចាំបាច់សម្រាប់ជីវភាព

គ្រួសារ ដូចជាការប្រើប្រាស់យានយន្តទៅធ្វើការ ជូនកូនទៅសាលា ជាអាទិ៍។[៥៤] ដោយសារទ្រព្យរួម គឺជាទ្រព្យរបស់បុគ្គលទាំងពីរនាក់ ដូច្នេះ នៅពេលមានម្នាក់ពុំបានបំពេញនូវកាតព្វកិច្ច ឬធ្វេសប្រហែលក្នុងការរក្សាទ្រព្យសម្បត្តិនោះ សហព័ទ្ធម្ខាងទៀត មានសិទ្ធិក្នុងការទាមទារចំពោះភាគីម្ខាងទៀត ឲ្យបំពេញនូវកាតព្វកិច្ចណាមួយដែលមានភាពចាំបាច់ សម្រាប់ការគ្រប់គ្រង និងរក្សាទុកនូវទ្រព្យរួមទាំងនោះបាន ឧទាហរណ៍ការជួសជុលទ្រព្យសម្បត្តិរួម ឬរក្សាទ្រព្យសម្បត្តិរួមដោយមិនលក់ ឬមិនជួល ឲ្យទៅតតិយជនណាម្នាក់នោះ ។ល។ ប៉ុន្តែប្រសិនបើសហព័ទ្ធមានគំនិតប្រឆាំងគ្នាពោលគឺពួកគេមិនអាចដោះស្រាយអំពីការប្រើប្រាស់ និងគ្រប់គ្រងនូវទ្រព្យសម្បត្តិរួមរបស់ពួកគេបែបនេះបានទេ នោះសហព័ទ្ធអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន។ ថ្វីត្បិតតែបញ្ហានេះ ជាបញ្ហារវាងសហព័ទ្ធ ឬអាចនិយាយបានថាជាបញ្ហានៅក្នុងគ្រួសាររបស់ពួកគេ ច្បាប់ប្រាកដណាស់ពុំអាចលូកដៃទៅក្នុងវិវាទគ្រួសាររបស់គេបានឡើយ ប៉ុន្តែច្បាប់ក៏មិនប្រកែកក្នុងការផ្តល់ជាជំនួយ លើការសម្រេចយកមតិរួមមួយ នៅពេលដែលពួកគេត្រូវការដែរ។ ដូច្នេះក្នុងន័យនេះ ច្បាប់មានគោលបំណង ពុំចង់ឲ្យមានការរាំងស្ទះនៅក្នុងការសម្រេចសេចក្តី ក៏រឹតតែមានបំណងឱ្យការរស់នៅរបស់សហព័ទ្ធទាំងនោះ មានសេចក្តីសុខ និងចៀសវាងភាពរកាំរកូសនឹងគ្នាផងដែរ។

### ១.២. ការអាស្រ័យនៅទ្រព្យដោយឡែករបស់សហព័ទ្ធ

ក្រៅពីការប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធទាំងសងខាង សហព័ទ្ធមានសិទ្ធិក្នុងការអាស្រ័យនៅលើទ្រព្យដោយឡែករបស់សហព័ទ្ធម្ខាងទៀត ដែលជាអចលនវត្ថុផងដែរ ដោយច្បាប់មានគោលគំនិតឲ្យសហព័ទ្ធមានការសហការគ្នា មានសាមគ្គីភាពក្នុងការរួមរស់នៅជាមួយគ្នា។ នៅក្នុងករណីនេះផងដែរ ក្រមរដ្ឋប្បវេណី បានចែងអំពីសិទ្ធិរបស់សហព័ទ្ធណាម្ខាងដែលបានអាស្រ័យនៅលើអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ឲ្យមានសិទ្ធិរស់នៅបន្តរហូតដល់ពេលគេអាចរកទីសំណាក់ផ្សេងមកជំនួសបាន បន្ទាប់ពីសហព័ទ្ធដែលជាម្ចាស់ទ្រព្យនោះ បានចាត់ចែងអចលនវត្ថុនោះ។[៥៥]

តាមសេចក្តីកំណត់ក្រម ភាគទី៥ គន្លឹ៧ បានបកស្រាយថា សិទ្ធិអាស្រ័យនៅ នៅត្រង់នេះគឺជាសិទ្ធិអាទិភាព ដែលអាចអះអាងអំពីការបន្តការស្នាក់អាស្រ័យអចលនវត្ថុនេះតទៅទៀត ចំពោះតតិយជនបាន។[៥៦] បើតាមការពិចារណា មាត្រានេះ មានគោលបំណងការពារដល់សហព័ទ្ធម្ខាង

---

[៥៤] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, *សៀវភៅជំនួយស្មារតី, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, (ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១៧), ៣៦០។

[៥៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៧។

[៥៦] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី និងសេចក្តីពន្យល់, ភាគទី៥ គន្លឹទី៧, ២០១០, ៣៨។

ទៀតដែលមិនមែនជាម្ចាស់ទ្រព្យ ក្នុងការ ស្នាក់នៅលើទ្រព្យរបស់សហព័ទ្ធរបស់ខ្លួន ដែលសម្រាប់គ្រួសារទាំងមូល ពីព្រោះ ច្បាប់មានគោលបំណងការពារដល់សហព័ទ្ធនោះ រហូតដល់ខ្លួនរកទីសំណាក់សម្រាប់គ្រួសារបាន ឬខ្លួនលែងមានសិទ្ធិនេះ ពោលគឺសហព័ទ្ធបានលែងលះ។ នៅក្នុងក្រមរដ្ឋប្បវេណីដដែលនេះ ក៏មានមាត្រា២៧៤ ដែលចែងអំពីសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅផងដែរ ក៏ប៉ុន្តែ សម្រាប់បញ្ញត្តិមាត្រា៩៧៧ មានលក្ខណៈពិសេសជាងត្រង់ថា សិទ្ធិក្នុងមាត្រា៩៧៧ គឺសំដៅទៅលើសិទ្ធិរបស់សហព័ទ្ធតែម្តង ប៉ុន្តែសម្រាប់មាត្រា២៧៤នេះវិញ គឺសំដៅទៅលើគ្រួសារទាំងមូល។

មួយវិញទៀត កម្រិតនៃការប្រើប្រាស់សិទ្ធិនៅក្នុងមាត្រា២៧៤ គឺបានត្រឹមតែអាស្រ័យផល និងកាន់កាប់ចំណែកមួយនៃអគារទៅតាមសេចក្តីត្រូវការសម្រាប់ការរស់នៅរបស់ក្រុមគ្រួសារគេតែប៉ុណ្ណោះ ប៉ុន្តែងាកមកមើលមាត្រា៩៧៧វិញ វិសាលភាពរបស់វាគឺមានការការពារសហព័ទ្ធខ្លាំងមែនទែន ដែលសិទ្ធិនេះអាចនឹងអះអាងចំពោះតតិយជន មិនឲ្យមានការរឹបអូសយកអចលនវត្ថុដែលខ្លួនកំពុងអាស្រ័យនៅនោះបានទេ រហូតដល់ខ្លួនអាចរកទីសំណាក់ផ្សេងបាន ឬលែងលះជាមួយសហព័ទ្ធដែលជាម្ចាស់ទ្រព្យនោះ។ នៅពេលដែលយកមាត្រា២ខុសគ្នា មកប្រៀបធៀបគ្នាដូចនេះ ថ្វីត្បិតតែវាមានលក្ខណៈស្រដៀង ឬប្រហាក់ប្រហែលគ្នាក៏ពិតមែន ប៉ុន្តែគោលគំនិតក្នុងការបង្កើតឡើងរបស់ច្បាប់ គឺដើម្បីការពារនូវផលប្រយោជន៍របស់បុគ្គលផ្សេងៗគ្នា ដែលយើងជាអ្នកច្បាប់គប្បីចេះបែងចែក ថាក្នុងស្ថានភាពណា គួរប្រើបញ្ញត្តិមាត្រាមួយណា ដើម្បីការពារបុគ្គលដែលមានតួនាទីផ្សេងៗគ្នានោះ។

### ១.៣. ការចាត់ចែងទ្រព្យសម្បត្តិរួម

នៅក្នុងវិសាលភាពនៃការចាត់ចែងទ្រព្យសម្បត្តិរួម ចាំបាច់ត្រូវតែមានការយល់ព្រមពីសហព័ទ្ធទាំងសងខាង។ ដោយហេតុថា ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធមានសិទ្ធិកម្មសិទ្ធិទៅលើគ្នាទៅវិញទៅមក ពោលគឺមានសិទ្ធិស្មើៗគ្នា ទើបច្បាប់កំណត់ថា ការចាត់ចែងទ្រព្យសម្បត្តិនេះ គប្បីមានការព្រមព្រៀងយល់ស្របមតិគ្នា មុននឹងលក់ ឬចាត់ចែងទៅឲ្យតតិយជនផ្សេងទៀត។ មានមតិមួយចំនួន យល់ថា ទ្រព្យសម្បត្តិរួមនេះ មានស្ថានភាពប្រហាក់ប្រហែលទៅនឹងកម្មសិទ្ធអវិភាគ ដែលមានចែងក្នុងមាត្រា២០២ ដល់មាត្រា២១៤ ដែលបានកំណត់រាល់សកម្មភាពដែលទាក់ទងទៅនឹងសិទ្ធិរបស់ម្ចាស់កម្មសិទ្ធិអវិភាគ ដោយសារតែសហព័ទ្ធបានប្រើប្រាស់ទ្រព្យរួមក្នុងគោលបំណងសហការគ្នា លើសិទ្ធិដែលខ្លួនមាន។ ប៉ុន្តែជាក់ស្តែង ទ្រព្យសម្បត្តិរួម ស្ថិតនៅក្នុងបញ្ញត្តិអាពាហ៍ពិពាហ៍ ដែលមានន័យក្តោបទៅលើសកម្មភាពរបស់សហព័ទ្ធ និងមានចំណុចខុសគ្នាយ៉ាងដាច់ដោយឡែក ត្រង់ថាទ្រព្យសម្បត្តិរួម គឺចាំបាច់ត្រូវតែមានការយល់ព្រមពីសហព័ទ្ធទាំង

សងខាង ក្នុងការចាត់ចែងទ្រព្យនេះ ដែលខុសពីកម្មសិទ្ធិអវិភាគ ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ មានសិទ្ធិក្នុងការធ្វើអនុប្បទាន ឬដាក់ជាប្រាតិភោគ នូវចំណែករបស់ខ្លួនបាន ដោយពុំចាំបាច់មានការយល់ព្រមពីម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀតទេ ហើយម្ចាស់បំណុលរបស់ម្ចាស់កម្មសិទ្ធិអវិភាគនេះក៏អាចរឹបអូសត្រឹមកម្រិតនៃចំណែកនោះផងដែរ។[៥៧]

ដោយត្រង់ន័យនេះ យើងឃើញថា ទ្រព្យសម្បត្តិរួម មានលក្ខណៈដាច់ខាតជាងកម្មសិទ្ធិអវិភាគជាខ្លាំង បើទោះបីជាស្ថានភាពវាមានភាពស្រដៀងគ្នាក៏ដោយ។ ប៉ុន្តែ នៅពេលអនុវត្តពិតប្រាកដ សម្រាប់ទ្រព្យសម្បត្តិរួម រមែងជួបនូវស្ថានភាពដែលសហព័ទ្ធណាម្ខាងពុំផ្តល់ការយល់ព្រម ឬពុំមានវត្តមានសម្រាប់ការផ្តល់ការយល់ព្រមទៅលើការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ខ្លួនឡើយ ដែលវាធ្វើឲ្យមានការរាំងស្ទះដល់ការចាត់ចែងទ្រព្យសម្បត្តិរួមនោះ សម្រាប់ការប្រើប្រាស់ផ្សេងៗ។

ដោយហេតុនេះហើយ ទើបកថាខណ្ឌ២ នៃមាត្រា៩៧៦ នៃក្រមរដ្ឋប្បវេណី ចូលខ្លួនមកជួយសម្រួលដល់ការចាត់ចែងលើទ្រព្យសម្បត្តិរួមនេះ។ បើទោះជាយ៉ាងនេះក្តី ក៏តុលាការដែលជាអ្នកអនុញ្ញាតឲ្យសហព័ទ្ធនោះ អាចចាត់ចែងទ្រព្យសម្បត្តិរួមនេះដោយពុំចាំបាច់មានការយល់ព្រមពីសហព័ទ្ធរបស់គេ (ក្នុងករណីដែលសហព័ទ្ធម្ខាងទៀតធ្វើការបដិសេធ មិនសមស្រប ឬពុំមានវត្តមានក្នុងការផ្តល់ការយល់ព្រម) ត្រូវមើលដែរថាមូលហេតុអ្វីបានជាសហព័ទ្ធនេះ មានបំណងចង់លក់ ឬចាត់ចែងទ្រព្យសម្បត្តិនេះ ដែលគោលដៅនៃការចាត់ចែងទ្រព្យនេះទៀតសោត ត្រូវតែក្នុងទំហំសម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីរក្សាជីវភាពរស់នៅ ទើបច្បាប់យល់ព្រមសម្រេចឲ្យមានសកម្មភាពចាត់ចែងលើទ្រព្យសម្បត្តិរួមនេះបាន ឧទាហរណ៍ លក់ផ្ទះដែលជាទ្រព្យរួមដើម្បីយកលុយទៅព្យាបាលជម្ងឺកូន។

យ៉ាងណាមិញ បើទោះបីជាច្បាប់បានបញ្ញត្តិឡើងនូវកថាខណ្ឌទី២ ដើម្បីអោយសហព័ទ្ធដែលត្រូវការ ការអនុញ្ញាតពីតុលាការសម្រាប់ការចាត់ចែងទ្រព្យសម្បត្តិរួមនេះក៏ដោយ (នៅពេលដែលសហព័ទ្ធម្ខាងទៀតពុំបានបង្ហាញឆន្ទៈយល់ព្រម) ក៏ស្ថានភាពកម្ពុជាបច្ចុប្បន្ន នៅតែបន្តមាននូវបញ្ហាដែលសហព័ទ្ធដែលចង់ចាត់ចែងទ្រព្យនោះ បានសម្រេចជាឯកតោភាគីទៅលើការលក់ទ្រព្យសម្បត្តិនេះទៅឲ្យតតិយជនណាមួយ ទាំងដែលមិនមានការយល់ព្រមពីសហព័ទ្ធ និងការអនុញ្ញាតពីតុលាការ។ ហេតុនេះហើយ ទើបកថាខណ្ឌទី៣ នៃមាត្រាដដែលបានឲ្យសិទ្ធិទៅសហព័ទ្ធដែលពុំបានបង្ហាញឆន្ទៈយល់ព្រម អាចធ្វើការទាមទារឲ្យលុបចោលនូវការចាត់ចែងនោះ ដោយដាក់ពាក្យបណ្តឹងទៅតុលាការផងដែរ ដែលអំឡុងពេលនៃការដាក់ពាក្យបណ្តឹងនេះ អាចឈានទៅដល់ពីរឆ្នាំ

[៥៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២០៤។

សម្រាប់អចលនវត្ថុដែលជាការអាស្រ័យនៅរបស់គ្រួសារ និងរយៈពេលមួយឆ្នាំក្នុងករណីទ្រព្យសម្បត្តិនោះ ជាទ្រព្យសម្បត្តិផ្សេងទៀត។

**កថាខណ្ឌទី២ ការទទួលខុសត្រូវចំពោះកាតព្វកិច្ច**

ក្រៅពីមានសកម្មភាព ដែលសហព័ទ្ធអាចទទួលបានសិទ្ធិចំពោះទ្រព្យសម្បត្តិរបស់ពួកគេហើយនោះ (ទាំងទ្រព្យរួម និងទ្រព្យដោយឡែក) ច្បាប់ក៏ពុំអាចអាក់ខាននូវការចែងបញ្ញត្តិដែលទាក់ទងទៅនឹងកាតព្វកិច្ចដែលពួកគេមាន ចំពោះម្ចាស់បំណុលផងដែរ។ ដែលនៅក្នុងបទបញ្ញត្តិនៃទ្រព្យសម្បត្តិនេះ យើងនឹងសិក្សាទៅលើប្រតិបត្តិការនៃការចាត់ចែងទ្រព្យសម្បត្តិ ទំហំ និងវិសាលភាពដែលសហព័ទ្ធអាចប្រើប្រាស់ទ្រព្យនោះ ទៅតាមកម្រិតនៃករណីរបស់គេនីមួយ រួមមានទាំងការទទួលខុសត្រូវលើបំណុលរួម (២.១) និងការទទួលខុសត្រូវលើបំណុលដោយឡែក (២.២)។

**២.១. ការទទួលខុសត្រូវលើបំណុលរួម**

ដោយសារការរស់នៅជីវភាពជាប្ដីប្រពន្ធ ចៀសមិនផុតពីបញ្ហាដែលពួកគេទាំងពីរអ្នកអាចនឹងមានជីវភាពខ្វះខាត ដែលអាចឈានទៅដល់ការខ្ចីប្រាក់ពីម្ចាស់បំណុលណាម្នាក់ដើម្បីមកផ្គត់ផ្គង់សម្រាប់ជីវភាពរស់នៅឡើយ ដែលក្នុងករណីនេះ សកម្មភាពនេះគឺត្រូវបានធ្វើឡើងដោយសហព័ទ្ធទាំងពីរ គប្បីយើងទទួលស្គាល់ថា វាជាបំណុលរួម។ ការបែងចែកឲ្យដាច់រវាង បំណុលរួម និងបំណុលដោយឡែកនេះ គឺមានសារៈសំខាន់ណាស់ សម្រាប់កាតព្វកិច្ចរបស់កូនបំណុល នៅពេលដែលគេធ្វើការសងទៅម្ចាស់បំណុលវិញ។

ជាក់ស្ដែង ច្បាប់ក៏បានកំណត់អំពីកាតព្វកិច្ចសាមគ្គីរបស់សហព័ទ្ធផងដែរ ដែលមាននៅក្នុងមាត្រា៩៧៥ នៃក្រមរដ្ឋប្បវេណី។ ក្នុងនោះដែរ ច្បាប់បាននិយាយអំពីការទទួលខុសត្រូវរបស់ប្ដីប្រពន្ធ ចំពោះសោហ៊ុយដើម្បីរក្សាជីវភាពរួមប្ដីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាលថែទាំកូនជាអាទិ៍។ មិនតែប៉ុណ្ណោះ ក៏មានកាតព្វកិច្ចផ្សេងទៀតផងដែរ ដូចជាការទទួលខុសត្រូវជាមួយម្ចាស់បំណុល រាល់សកម្មភាពទាំងឡាយណា ដែលសហព័ទ្ធទាំងពីរ បានធ្វើប្រតិបត្តិការខ្ចីប្រាក់ ពីម្ចាស់បំណុល ក្នុងគោលបំណងដើម្បីផលប្រយោជន៍របស់ក្រុមគ្រួសារ ឬសហព័ទ្ធម្ខាងណាបានទៅខ្ចីពីម្ចាស់បំណុលតែឯង តែក៏បានទទួលការយល់ព្រមពីសហព័ទ្ធម្ខាងទៀតនៅពេលក្រោយ (ក្នុងករណីដែលសហព័ទ្ធម្ខាងនោះបានធ្វើជាលាយលក្ខណ៍អក្សរយល់ព្រម)[៥៨] ក៏ត្រូវបានច្បាប់ចាត់ចូលថាវាជាបំណុលរួមផងដែរ។

សម្រាប់ការចំណាយ លើការគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម សហព័ទ្ធទាំងសងខាងមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក ពោលគឺពួកគេម្នាក់ៗត្រូវចេញចំណែកនៃការចំណាយនោះស្មើៗ

[៥៨] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៥។

គ្នា ដែលក្នុងន័យនេះច្បាប់ចង់សំដៅទៅលើកាតព្វកិច្ចសាមគ្គីភាពរបស់សហព័ទ្ធ។ ដូច្នេះបញ្ហាប្រឈមដែលសហព័ទ្ធ នឹងត្រូវដោះស្រាយរួមគ្នា គឺនៅពេលបំពេញកាតព្វកិច្ចចំពោះម្ចាស់បំណុលវិញ ពោលគឺនៅពេលដែលសហព័ទ្ធត្រូវសងប្រាក់ទៅឲ្យម្ចាស់បំណុលវិញ ប្រសិនបើប្រតិបត្តិការនោះ ប្រព្រឹត្តទៅដោយរលូន មានន័យថាពុំមានភាពរកាំរកូសជាមួយម្ចាស់បំណុលនោះទេ ដោយកូនបំណុលមានលទ្ធភាពសងប្រាក់តាមការកំណត់សង នោះវាពុំបង្កជាបញ្ហាអ្វីគួរឲ្យកង្វល់ទេ ប៉ុន្តែក្នុងករណីដែលសហព័ទ្ធពុំមានប្រាក់សងនោះទេ គប្បីសហព័ទ្ធចេះជួយសង្គ្រោះគ្នាដោយធ្វើការចាត់ចែងទ្រព្យសម្បត្តិរួម ដើម្បីយកប្រាក់សងទៅម្ចាស់បំណុល ព្រោះប្រតិបត្តិការនេះគឺបានធ្វើឡើយដោយសហព័ទ្ធទាំងសងខាង ដូច្នេះការចេះជួយសង្គ្រោះគ្នា គឺជាមូលហេតុដ៏សមស្របបំផុតសម្រាប់ជីវិតអាពាហ៍ពិពាហ៍។

ម្យ៉ាងវិញទៀត ការដោះស្រាយបំណុលរួមនេះ គឺពុំមែនបានតែក្នុងអំឡុងពេលអាពាហ៍ពិពាហ៍នោះទេ គឺបន្តរហូតទោះបីជាក្រោយពេលលែងលះគ្នាក៏ដោយ ក៏ម្ចាស់បំណុលមានសិទ្ធិក្នុងការទាមទារបំណុលនេះ ពីសហព័ទ្ធទាំងពីរ ឬតែម្ខាងក៏បាន ពីព្រោះថាវាជាសិទ្ធិរបស់ម្ចាស់បំណុល ដូច្នេះច្បាប់ការពារដល់គេ ក្នុងការទាមទារទៅសហព័ទ្ធទាំងសងខាង ហើយសហព័ទ្ធទាំងពីរត្រូវតែទទួលខុសត្រូវ បើទោះបីជាគេបានលែងលះគ្នាក៏ដោយ។

### ២.២. ការទទួលខុសត្រូវលើបំណុលដោយឡែក

ក្រៅពីកាតព្វកិច្ចរបស់សហព័ទ្ធ ដែលមានចំពោះគ្នាទៅវិញទៅមកដូចបានរៀបរាប់ខាងលើនោះហើយ ក៏មានករណីមួយចំនួន ដែលសហព័ទ្ធតែម្ខាងបានបង្កើតកាតព្វកិច្ចជាមួយម្ចាស់បំណុលតែម្នាក់ឯង ដើម្បីផលប្រយោជន៍របស់ខ្លួនឯងជាអាទិ៍។ ដោយឡែក ដោយសារបំណុលរួម ច្បាប់ចង់សំដៅតែទៅលើកាតព្វកិច្ចសាមគ្គី ដែលមានចែងក្នុងមាត្រា៩៧៥ ដែលជារួមគឺរាល់ការប្រើប្រាស់សម្រាប់ផលប្រយោជន៍ក្នុងក្រុមគ្រួសារ ប្រពន្ធកូន ដូច្នេះយើងអាចសន្និដ្ឋានបានថា សកម្មភាពក្រៅពីមាត្រានេះ ការធ្វើប្រតិបត្តិការរបស់សហព័ទ្ធណាម្ខាងជាមួយម្ចាស់បំណុល គឺពុំមែនជាបំណុលរួមឡើយ (បើពុំមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត)។

ចំពោះបំណុលដោយឡែកនេះផងដែរ អាចកើតឡើងមុន ឬកំឡុងពេលអាពាហ៍ពិពាហ៍ ដែលដូចបកស្រាយខាងដើមថា ភាពចាំបាច់នៃការកំណត់ឲ្យមានភាពជាក់លាក់ក្នុងការបែងចែកបំណុលរួម និងបំណុលដោយឡែកដូចនេះ គឺទុកសម្រាប់នៅពេលកូនបំណុលត្រូវអនុវត្តកាតព្វកិច្ច។ នៅពេលដែលបំណុលមួយជាបំណុលដោយឡែក អ្នកដែលជាប់កាតព្វកិច្ចគឺមានតែសហព័ទ្ធដែលជាអ្នកធ្វើប្រតិបត្តិការខ្ចីប្រាក់ពីម្ចាស់បំណុលនោះតែប៉ុណ្ណោះ ហើយសហព័ទ្ធម្ខាងទៀតនឹងត្រូវ

បានគេការពារ ដោយម្ចាស់បំណុលមានសិទ្ធិទាមទារ ចំពោះតែសហព័ទ្ធម្ខាងដែលធ្វើប្រតិបត្តិការជាមួយគេទេ។

ដោយឡែក សម្រាប់បញ្ហានៅកម្ពុជាបច្ចុប្បន្ន ការដោះស្រាយបំណុលដោយឡែកនេះ ពុំមានបញ្ញត្តិពិសេសណាមួយចែងឲ្យឃើញនូវសិទ្ធិរបស់ម្ចាស់បំណុល ក្នុងការទាមទារឲ្យអនុវត្តលើទ្រព្យសម្បត្តិរួមទាំងអស់របស់សហព័ទ្ធ ឬសិទ្ធិរបស់សហព័ទ្ធក្នុងការការពារទ្រព្យសម្បត្តិរួមរបស់ខ្លួន នៅពេលដែលសហព័ទ្ធម្ខាងទៀតបានជាប់កាតព្វកិច្ចនេះទេ។ ប៉ុន្តែក៏មានមតិមួយចំនួនលើកឡើងអំពីសិទ្ធិរបស់ម្ចាស់បំណុលលើការអនុវត្តលើទ្រព្យសម្បត្តិរួម តែលើចំណែកពាក់កណ្តាលដែលសហព័ទ្ធជាប់កាតព្វកិច្ចនោះមាន សម្រាប់បំណុលដោយឡែករបស់គេ។[៥៩] ដោយសារតែទ្រព្យសម្បត្តិរួម មានលក្ខណៈស្រដៀងគ្នាទៅនឹងកម្មសិទ្ធិអវិភាគ ព្រោះសហព័ទ្ធទាំងសងខាងមានសិទ្ធិក្នុងការទទួលបានចំណែកម្នាក់ពាក់កណ្តាល ទើបយើងអាចសន្មតបានថាម្ចាស់បំណុលអាចអនុវត្តយកនូវទ្រព្យសម្បត្តិដោយឡែក ត្រឹមចំណែកដែលសហព័ទ្ធម្ខាងដែលជាប់កាតព្វកិច្ចនោះមាន។ បើទោះបីជាមាត្រា៩៧៦ នៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី១ បានកំណត់អំពីការយល់ព្រមរបស់សហព័ទ្ធទាំងសងខាង ទើបអាចចាត់ចែងទ្រព្យសម្បត្តិរួម ក្នុងគោលបំណងណាមួយ ប៉ុន្តែពុំបានបញ្ជាក់អំពីការចាត់ចែងទ្រព្យសម្បត្តិរួមនោះ ដោយម្ចាស់បំណុល ឬតតិយជនណាមួយឡើយ ទើបយើងអាចទាញយកនូវចំណុចសន្និដ្ឋានបានថា ប្រសិនបើសហព័ទ្ធណាម្ខាងជាប់កាតព្វកិច្ចជាមួយម្ចាស់បំណុលណាម្នាក់ ជាបំណុលដោយឡែក នោះម្ចាស់បំណុលនោះ មានសិទ្ធិក្នុងការអនុវត្តលើទ្រព្យសម្បត្តិរួម ត្រឹមកម្រិតដែលសហព័ទ្ធដែលជាប់កាតព្វកិច្ចនោះមាន។

## ផ្នែកទី៣ ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ

នៅពេលដែលប្តីប្រពន្ធ សម្រេចចិត្តលែងលះគ្នាមានកត្តាជាច្រើនដែលពួកគេទាំងពីរនាក់ (បើលែងលះតាមការព្រមព្រៀង) ឬតុលាការ (បើជាការលែងលះមិនព្រមព្រៀង) ត្រូវគិតគូរនូវចំណុចផ្សេងៗដែលត្រូវបែងចែក។ ក្រៅពីការទាមទារឲ្យមានការលែងលះ របស់សហព័ទ្ធក្នុងនោះផងដែរ សហព័ទ្ធក៏ពិចារណាលើការទាមទារឲ្យមានការកំណត់អ្នកមានអំណាចមេបាលើកូន ព្រមទាំងបែងចែកទ្រព្យរួមរៀងៗខ្លួនដែរ។ តាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ស្តីអំពីការបែងចែកទ្រព្យសម្បត្តិ កថាខណ្ឌទី១ បានកំណត់អំពីការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះគ្នា ដោយផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ដោយយុត្តិធម៌ (៣.១ ការបែងចែកទ្រព្យសម្បត្តិតាមការពិភាក្សាគ្នា) និងកថាខណ្ឌទី២ បានកំណត់ក្នុងករណីដែលការបែងចែកពុំអាចពិភាក្សាគ្នាបានទេ

---

[៥៩] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, *សៀវភៅជំនួយស្មារតី, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, (ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១៧), ៣៧១។

សហាព័ទ្ធអាចដាក់ពាក្យបណ្ដឹងទៅតុលាការក្នុងការសម្រេចសេចក្ដី (៣.២ ការបែងចែកទ្រព្យសម្បត្តិតាមសេចក្ដីរបស់តុលាការ)។

### កថាខណ្ឌទី១ ការបែងចែកទ្រព្យសម្បត្តិរួមតាមការពិភាក្សាគ្នា

អនុលោមតាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី សហាព័ទ្ធអាចដាក់ពាក្យសុំលែងលះទៅតុលាការបាន[៦០] ក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាអំពីការលែងលះគ្នា ហើយតុលាការនឹងសម្រេចឲ្យលែងលះគ្នា នៅពេលដែលគាត់យល់ថាភាគីទាំងសងខាងពិតជាមានបំណង ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ពិតប្រាកដមែន។ នៅមុនពេលដែលតុលាការសម្រេចលើពាក្យសុំលែងលះរបស់សហាព័ទ្ធ តុលាការក៏គប្បីត្រូវពិចារណាទៅលើឆន្ទៈរបស់ភាគី ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍នេះ ដោយត្រូវប្រាកដថាពួកគេពិតជាមិនអាចរួមរស់នៅជាមួយគ្នាបន្តទៅទៀតបានឡើយ ដោយធ្វើការកោះហៅ ភាគីសម្រាប់ធ្វើការសាកសួរពីចេតនា និងបញ្ហាផ្សេងៗដែលជាដើមចម ដែលពួកគេពុំអាចបន្តអាពាហ៍ពិពាហ៍នេះតទៅទៀតបាន។ ក្នុងពាក្យសុំលែងលះនេះផងដែរ សហាព័ទ្ធគប្បីកំណត់អំពីការព្រមព្រៀងលើការលែងលះគ្នា ការកំណត់អំពីអ្នកមានអំណាចមេបាលើកូន ព្រមទាំងការបែងចែកទ្រព្យសម្បត្តិរួមផងដែរ។ នៅពេលនោះ តុលាការនឹងពិនិត្យមើលទៅលើមូលហេតុ និងភាពយុត្តិធម៌នៃការបែងចែកចំណែកទ្រព្យសម្បត្តិ ដើម្បីធានាថាការបែងចែកទាំងនេះប្រព្រឹត្តទៅដោយពុំមានការបង្ខិតបង្ខំពីភាគីណាម្ខាងឡើយ។ នីតិវិធីបន្តតុលាការនឹងចេញ សេចក្ដីសម្រេច លើពាក្យសុំលែងលះរបស់សហាព័ទ្ធ រួចពួកគេអាចយកសេចក្ដីសម្រេចនេះ ទៅ អនុវត្ត តាមផលប្រយោជន៍របស់ខ្លួនរៀងៗខ្លួនបាន។

ដោយឡែក ប្រសិនបើការពិភាក្សាពុំអាចឈានដល់ការព្រមព្រៀងគ្នា (អាចចូលក្នុងចំណុចផ្សេងៗទៀតដែលមានចែងក្នុងមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី) ទៅលើចំណុចទាំងពីរខាងលើទេ (ការកំណត់យកអ្នកមានអំណាចមេបា និងការបែងចែកទ្រព្យសម្បត្តិរួម) នោះសហាព័ទ្ធអាចដាក់ពាក្យបណ្ដឹងលែងលះមកតុលាការ ដើម្បីឲ្យចេញសាលក្រមសម្រេចអំពីអ្នកមានអំណាចមេបា និងការបែងចែកទ្រព្យសម្បត្តិរួមផងដែរ។

### កថាខណ្ឌទី២ ការបែងចែកទ្រព្យសម្បត្តិរួមតាមសេចក្ដីសម្រេចរបស់តុលាការ

ដោយផ្អែកតាមមាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី២ បានចែងថា ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្ដីប្រពន្ធបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិតាមការកំណត់របស់ច្បាប់ ដោយ

[៦០] ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង , លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, តារាងឧបសម្ព័ន្ធ ផ្នែកទី៤ ចំណុច៥។

ដំបូងគេសិក្សាលើទ្រព្យសម្បត្តិដោយឡែកដែលសហព័ទ្ធមាន ស្របតាមបញ្ញត្តិមាត្រា៩៧២ នៃក្រមដដែលនេះ ព្រមទាំងទ្រព្យសម្បត្តិរួម តាមសមាមាត្រនៃចំណែករបស់ភាគីទាំងសងខាង។

ជាមួយគ្នានេះដែរ ការបែងចែកទ្រព្យសម្បត្តិរួម មិនតម្រូវជាដាច់ខាតនូវការបែងចែកជាពីរចំណែកស្មើគ្នានោះទេ ក្នុងនោះដែរតុលាការនឹងពិចារណាទៅលើករណីពិសេស ដែលមានការទាមទារពីសហព័ទ្ធណាម្ខាងនូវចំណែកផ្សេងៗ ដោយមើលទៅលើស្ថានភាពដូចជាទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទៅលើលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ ព្រមទាំងកម្រិតនៃជីវភាពរស់នៅក្នុងពេលអាពាហ៍ពិពាហ៍ ដោយបូករួមទាំងអាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។ មិនតែប៉ុណ្ណោះ ច្បាប់ការពារផងដែរចំពោះសហព័ទ្ធដែលបានបំពេញការងារគេហកិច្ច ដោយតម្រូវឲ្យចាត់ទុកការងារនេះ មានតម្លៃស្មើនឹងការងារក្រៅរបស់សហព័ទ្ធម្ខាងទៀតផងដែរ ដោយស្របតាមរដ្ឋធម្មនុញ្ញ មាត្រា៣៦ និងមាត្រា៩៨០ កថាខណ្ឌ៣។ ជាក់ស្តែង នៅក្នុងបណ្តឹងលែងលះ ការទាមទារឲ្យមានការលែងលះគ្នា គឺជាលក្ខខណ្ឌចម្បងនៃនីតិវិធីលែងលះ ចំណែកឯលក្ខខណ្ឌបន្ទាប់បន្សំ គឺមានការកំណត់អំណាចមេបាដែលអាចស្នើសុំបានតាមនីតិវិធីបណ្តឹងស្តីពីឋានៈបុគ្គល និងការបែងចែកទ្រព្យ ដែលអាចស្នើសុំតាមក្រោយបាន តាមនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង។ ងាកមកការបែងចែកទ្រព្យសម្បត្តិតាមតុលាការវិញ ចៅក្រមដែលជាអ្នកសម្រេចសេចក្តី ត្រូវពិចារណា ពិនិត្យឲ្យគ្រប់ជ្រុងជ្រោយថាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធមានទំហំប៉ុណ្ណា ហើយថាតើការបែងចែកនោះទៀតសោតអាចនឹងប៉ះពាល់ដល់ផលប្រយោជន៍កូនដែរឬអត់ ពីព្រោះថាច្បាប់មានគោលគំនិតការពារដល់ផលប្រយោជន៍កុមារជាធំ។ បន្ទាប់ពីមានការសិក្សាលើចំណុចទាំងអស់នេះហើយ តុលាការនឹងអាចចេញនូវសេចក្តីសម្រេចដ៏សមស្របអាចទទួលយកបានមួយ ដើម្បីឲ្យភាគីដែលជាសហព័ទ្ធទាំងសងខាងយកទៅអនុវត្ត។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការស្រាវជ្រាវប្រធានបទខាងលើ យើងខ្ញុំអាចធ្វើការសន្និដ្ឋានបានថាប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ពិតជាមានភាពចាំបាច់ណាស់ក្នុងការលើកយកមកសិក្សាបកស្រាយ ដើម្បីឲ្យប្រជាពលរដ្ឋទូទៅ ឲ្យមានការយល់ដឹងឲ្យកាន់តែច្បាស់អំពីសារៈសំខាន់ គោលបំណង និងផលប្រយោជន៍របស់ប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ទាំងកិច្ចសន្យា និងទាំងច្បាប់កំណត់ ពីព្រោះវាគឺជាកិច្ចចម្បងមួយដែលពួកគេគប្បីដឹង និងយល់នៅពេលដែលពួកគេរៀបអាពាហ៍ពិពាហ៍។ ក្នុងនោះផងដែរ សហព័ទ្ធមានសិទ្ធិសេរីភាពក្នុងការកំណត់យកនូវទ្រព្យសម្បត្តិរបស់ពួកគេតាមការព្រមព្រៀងលើកិច្ចសន្យាទ្រព្យសម្បត្តិ ឬតាមការកំណត់របស់ច្បាប់។ ខុសប្លែកគ្នាត្រង់ថាបើពួកគេយល់ព្រមគោរពតាមកិច្ចសន្យាទ្រព្យសម្បត្តិ នោះពួកគេតម្រូវឲ្យមានការព្រមព្រៀងបង្កើតឡើងនូវកិច្ចសន្យានោះ និងចុះបញ្ជីយ៉ាងត្រឹមត្រូវស្របតាមនីតិវិធីនៅក្រសួងយុត្តិធម៌ ប៉ុន្តែបើពួកគេយល់ថាមិនចាំបាច់បង្កើតនូវកិច្ចសន្យាទ្រព្យសម្បត្តិទេនោះ គេក៏មិនចាំបាច់បង្កើតវាទេ ហើយប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់កំណត់នឹងចូលខ្លួនមកអនុវត្តដោយស្វ័យប្រវត្តិ។

សម្រាប់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា វាមានគោលបំណងក្នុងការកំណត់យកអំពីសេរីភាព និងឆន្ទៈរបស់បុគ្គលឯកជនក្នុងការបែងចែកទ្រព្យសម្បត្តិរបស់ពួកគេ នៅមុនពេល និងកំឡុងពេលដែលពួកគេរស់ជាមួយគ្នាជាប្តីប្រពន្ធ។ ជាមួយគ្នាផងដែរ កិច្ចសន្យាទ្រព្យសម្បត្តិនេះអាចធ្វើការកែប្រែ ផ្លាស់ប្តូរ និងលុបចោលបានទៅតាមការព្រមព្រៀងរបស់សហព័ទ្ធទាំងពីរ ដោយអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងសេចក្តីប្រកាសនៅក្រសួងយុត្តិធម៌។ ម៉្យាងវិញទៀត វាមានអត្ថប្រយោជន៍សម្រាប់សហព័ទ្ធទាំងសងខាង ដើម្បីធ្វើការអះអាងជាមួយតតិយជន អំពីកម្រិតនៃទំហំទ្រព្យសម្បត្តិដែលពួកគេមាន និងជាការសម្រួលដល់តតិយជនផ្សេងទៀតផងដែរ ក្នុងការដឹងអំពីទំហំទ្រព្យសម្បត្តិរបស់សហព័ទ្ធទាំងសងម្ខាង ឬតែម្ខាង នៅមុនពេលដែលគេធ្វើជំនួញ ឬពាណិជ្ជកម្មជាមួយប្តី ឬប្រពន្ធនោះ។ មិនតែប៉ុណ្ណោះ វាពិតជាមានសារៈសំខាន់ផងដែរ នៅពេលដែលសហព័ទ្ធទាំងសងខាងឈានទៅរកការលែងលះ។ នៅពេលដែលប្តីប្រពន្ធមួយគូរនេះសម្រេចប្រកាន់យកនូវប្រពន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ពួកគេបានព្រមព្រៀងគ្នាលើការបែងចែកទ្រព្យសម្បត្តិទាំងរួម និងដោយឡែក រួមទាំងបានឯកភាពគ្នាទៅលើកាតព្វកិច្ចណាមួយជាកាតព្វកិច្ចរួម និងកាតព្វកិច្ចណាមួយជាកាតព្វកិច្ចដោយឡែក។ ក្នុងន័យនេះ វាក៏បានជួយសម្រួលដល់នីតិវិធីតុលាការ ក្នុងការសម្រេចលើរឿងក្តីលែងលះគ្នានេះផងដែរ ព្រោះថា តុលាការនឹងសម្រេចទៅតាមអ្វីដែលមានកំណត់នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិនោះតែប៉ុណ្ណោះ ប៉ុន្តែតុលាការនឹងពិចារណាមើល

តទៅទៀតថាតើ ទ្រព្យសម្បត្តិដែលមានកំណត់នៅក្នុងខ្លឹមសារកិច្ចសន្យាទាំងនោះ មានផ្ទុយទៅនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុងដែរឬទេ។

សម្រាប់ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមច្បាប់កំណត់វិញ **គឺ**ច្បាប់មានគោលបំណងចង់រក្សានូវចំណងអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋ**ឲ្យ**រឹតតែមានភាពរឹងមាំ តាមរយៈការចេះជួយសង្គ្រោះគ្នា សហការគ្នាក្នុងការរស់នៅ និងមានភាពសាមគ្គីភាពរវាងប្ដី និងប្រពន្ធ នៅក្នុងការដោះស្រាយបំណុលរួមផងដែរ។ ចំពោះប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមច្បាប់កំណត់ មានអត្ថប្រយោជន៍ នៅពេលដែលប្ដីប្រពន្ធណាម្ខាង ធ្វេសប្រហែសក្នុងការដើរតួជាប្ដី ឬប្រពន្ធ **និងជា**ម្ដាយ ឬឪពុកសម្រាប់កូន នោះច្បាប់តម្រូវឲ្យពួកគេ មានការជួយសហការគ្នាទៅវិញទៅមក ដែលមានកំណត់នៅក្នុងបញ្ញត្តិច្បាប់ជាសំអាង។ ដោយឡែកនៅពេលលែងលះ សម្រាប់ប្ដីប្រពន្ធដែលកំណត់យកនូវប្រព័ន្ធទ្រព្យសម្បត្តិនេះ តុលាការនឹងសម្រេចសេចក្ដីទៅតាមការព្រមព្រៀង និងភស្តុតាងនានា ដែលបញ្ជាក់នូវទ្រព្យសម្បត្តិរបស់ពួកគេ ដែលខុសពីសហព័ទ្ធដែលមានកិច្ចសន្យាទ្រព្យសម្បត្តិ តុលាការសម្រេចតែទៅតាមអ្វីដែលមាននៅក្នុងខ្លឹមសារកិច្ចសន្យានោះតែប៉ុណ្ណោះ។

សរុបមក នៅក្នុងពេលរៀបអាពាហ៍ពិពាហ៍ ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធត្រូវបានយកមកចាត់ចែង ប្រើប្រាស់ និងគ្រប់គ្រងក្នុងកម្រិតនៃការសាមគ្គី និងជួយសង្គ្រោះគ្នាទៅវិញទៅមក និងក្រោយពេលលែងលះ ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធត្រូវបានយកមកបែងចែកទៅឲ្យសហព័ទ្ធទាំងសងខាងទៅតាមសមាមាត្រនៃចំណែករបស់ខ្លួនរៀងៗខ្លួន។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងលម្អិត អំពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធរួចមក យើងខ្ញុំយល់ឃើញថា ច្បាប់បានតាក់តែងនូវកម្រងបញ្ញត្តិពីខាងលើ មានការគិតគូរច្បាស់លាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធ ដើម្បីបំពេញក្នុងនាមជាប្តី ឬប្រពន្ធ និងបង្ការនូវហានិភ័យដែលអាចកើតមានឡើងនៅពេលមានបញ្ហាណាមួយ។ ប៉ុន្តែបើទោះបីច្បាប់ មានការកំណត់នូវចំណុចរបស់ប្តីប្រពន្ធយ៉ាងលម្អិតបែបនេះក៏ដោយ ក៏មានប្រជាជនមួយចំនួនធំ នៅតែមិនទាន់មានការយល់ដឹងអំពីច្បាប់នៅឡើយ។ នៅពេលដែលពួកគេមិនបានស្វែងយល់អំពីច្បាប់ដូចនេះ វានឹងមិនមានជាបញ្ហាចោទទេនៅពេលដែលពួកគេរួមរស់នៅជាមួយយ៉ាងសុខុដុមរមនា ប៉ុន្តែវានឹងមានវិវាទកើតឡើងនៅពេលដែលមានសហព័ទ្ធណាម្ខាងបានបំពានលើសហព័ទ្ធម្ខាងទៀត នៅក្នុងករណីដែលផ្ទុយពីច្បាប់។ នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ប្រជាជនមួយភាគធំ បានធ្វេសប្រហែសក្នុងការពិនិត្យ និងសិក្សាលើច្បាប់ដែលពាក់ព័ន្ធ នៅពេលដែលគេរៀបអាពាហ៍ពិពាហ៍ ឧទាហរណ៍ ការមិនចេញថ្លៃសោហ៊ុយសម្រាប់អាពាហ៍ពិពាហ៍ ការមិនមើលថែក្រុមគ្រួសារដូចជាការផ្គត់ផ្គង់នូវសំភារៈ ក៏ដូចជាផ្តល់ការស្រលាញ់ដល់សហព័ទ្ធរបស់ខ្លួន និងមានបញ្ហាមួយចំនួនទៀត តួយ៉ាងដូចការបែងចែកមិនស្មើភាពគ្នា ឬមិនអាចពិភាក្សាគ្នាបាន លើទ្រព្យសម្បត្តិរួម នៅពេលលែងលះ។ ហេតុដូចនេះហើយ ទើបច្បាប់ខិតខំតាក់តែងនូវចំណុចទាំងឡាយ ដើម្បីជៀសវាងនូវបញ្ហានានា ដែលបានរៀបរាប់ខាងលើ ប៉ុន្តែក្នុងនោះដែរក៏មានចន្លោះខ្វះខាតពីអ្នកអនុវត្តច្បាប់ ក្នុងការផ្សព្វផ្សាយឲ្យមានភាពទូលំទូលាយជាងនេះ ដល់ប្រជាពលរដ្ឋដែលបានដឹងអំពីបញ្ញត្តិទាំងនេះ ក៏ដូចជាពុំមានលទ្ធភាពក្នុងការដឹងនូវច្បាប់ដែលពាក់ព័ន្ធទាំងនេះផងដែរ។ ដូច្នេះហើយ យើងខ្ញុំសុំលើកយកនូវការសំណូមពរដល់រាជរដ្ឋាភិបាលនូវចំណុចដូចខាងក្រោមនេះ៖

-បង្កើតឱកាសដល់ប្រជាជន ក្នុងការយល់ដឹងបន្ថែមអំពីច្បាប់ ដែលទាក់ទងនឹងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធទាំង២ប្រភេទខាងលើនេះ ទាំងក្នុងលក្ខណៈអនឡាញ (គោលបំណងផ្សព្វផ្សាយដល់ប្រជាជនដែលមានលទ្ធភាព និងចេះពីរបៀបប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេត) ទាំងក្នុងលក្ខណៈផ្សព្វផ្សាយច្បាប់តាមសមាគម មូលដ្ឋាន (គោលបំណងផ្សព្វផ្សាយដល់ប្រជាជនដែលមិនមានលទ្ធភាពក្នុងការដឹង ជាពិសេសប្រជាជននៅតាមបណ្តាខេត្តនានា)

-លើកទឹកចិត្តឲ្យប្រជាជនមានសាមគ្គីភាព ជួយសង្គ្រោះគ្នា ចេះយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក ដែលស្របទៅនឹងគោលបំណងអាពាហ៍ពិពាហ៍ ដែលពួកគេគប្បីចេះពិភាក្សាគ្នាជាមុន មុនពេលសម្រេចលើកិច្ចការអ្វីមួយ។

-ជំរុញឲ្យមន្ត្រីអគ្រានុកូលដ្ឋាន និងមន្ត្រីដែលពាក់ព័ន្ធ ព្យាយាមឲ្យយោបល់ និងណែនាំអំពីច្បាប់ដល់សហព័ទ្ធដែលទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ពីព្រោះពួកគេអាចនឹងមិនដឹង ឬកម្រិតនៃការយល់ដឹងនៅមានកំណត់ ដែលអាចបង្កឲ្យមានវិវាទនានានៅពេលក្រោយ។

-បង្ការការផ្តល់ព័ត៌មានខុស ឬការឲ្យប្រឹក្សា ពិគ្រោះយោបល់ខុស ពីសំណាក់មន្ត្រីមានសមត្ថកិច្ចទៅកាន់ប្រជាពលរដ្ឋ គប្បីរដ្ឋាភិបាលមានវិធានការនានាដើម្បីទប់ស្កាត់នូវបញ្ហានេះ ដែលអាចកើតមានឡើងជាយថាហេតុ។

ជាចុងក្រោយ យើងខ្ញុំដែលជានិស្សិតផ្នែកខាងច្បាប់ នឹងព្យាយាមចែករំលែកនូវចំណេះដឹងក៏ដូចជាអាចផ្តល់ប្រឹក្សា ឬការពិភាក្សាណាមួយ ដល់ប្រជាជនដែលមានភាពខ្វះខាតក្នុងការយល់ដឹងនូវបញ្ហាទាំងនេះ ដើម្បីឲ្យពួកគេមានលទ្ធភាពក្នុងការប្រើប្រាស់ និងដោះស្រាយជាមួយដៃគូសហព័ទ្ធរបស់ពួកគេដែលប្រកបទៅដោយភាពត្រឹមត្រូវតាមផ្លូវច្បាប់។

# ឯកសារយោង

## ឯកសារយោង

### ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

–រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

–ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

–ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩។

–ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

–ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

–ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ, លេខ ៨១ កយ.ប្រក/១៣, ០៩ សីហា ២០១៣។

–សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ៥, គន្ថីទី៧, ក្រសួងយុត្តិធម៌, ភ្នំពេញ, ២០១០។

### សៀវភៅ និងឯកសារផ្សេងទៀត

–រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, *សៀវភៅជំនួយស្មារតី, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, (ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១៥)។

–ណូមឺរ៉ា តូយ៉ូហ៊ីរ៉ូ, *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី*, (ភ្នំពេញ៖ ២០១៤), ១៣៩ និង ១៤០។

–វិភាគទានច្បាប់, *កម្រងមេរៀនឆ្នាំ ២០១៧,* (ភ្នំពេញ៖ ២០១៧)។

–ចំណាប់អារម្មណ៍របស់ ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ០៩ សីហា ២០១៣។

## គេហទំព័រ

-លោកជំទាវ ចាន់ សុទ្ធាវី (រដ្ឋលេខធិការក្រសួងយុត្តិធម៌),

http://www.youtube.com/watch?v=9AXRVUBS2SA (ចូលទស្សនាថ្ងៃទី ៥ មិថុនា ២០១៨)។

-ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា,

https://thimhorn.wordpress.com/2017/11/09/ប្រព័ន្ធទ្រព្យសម្បត្តិ/, ( ចូលទស្សនានៅថ្ងៃ ២៥ មិថុនា ២០១៨)។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

**១. ឧបសម្ព័ន្ធលេខ០១៖** ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
**២. ឧបសម្ព័ន្ធលេខ០២៖** ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង
**៣.ឧបសម្ព័ន្ធលេខ០៣៖** ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

# ឧបសម្ព័ន្ធលេខ០១
# ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

**មាត្រា ២៥.- ការប្រគល់សិទ្ធិឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រកាស**

ទម្រង់នៃពាក្យសុំ និង បញ្ហាផ្សេងទៀតដែលចាំបាច់សម្រាប់ការចុះបញ្ជីនីតិបុគ្គល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ចំនួនសោហ៊ុយត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤
## ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**មាត្រា ២៦.- សមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១-កិច្ចការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ច របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។ បញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវរក្សាទុកនៅក្រសួងយុត្តិធម៌ ។

**មាត្រា ២៧.- បែបបទ និង ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

បែបបទ និង ទម្រង់នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២៨.- ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១-ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើរួមគ្នា និងជាលាយល័ក្ខណ៍អក្សរដោយប្តីប្រពន្ធ ឬដោយបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ ។

២-ពាក្យសុំត្រូវសរសេរចូលនូវឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ កាលបរិច្ឆេទចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ខ្លឹមសារនៃកិច្ចសន្យានោះ និង ចំណុចផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

៣-ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាលាយល័ក្ខណ៍អក្សរ និងឯកសារផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ២៩.- ការប្រតិបត្តិការចុះបញ្ជី**

មន្ត្រីដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ២៦ (សមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) នៃច្បាប់នេះ មិនអាចប្រតិបត្តិការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធបានទេ ហេតុទាល់តែអាចបញ្ជាក់បានថា ពាក្យសុំនោះត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និង បទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា ៣០.- ការចុះបញ្ជីចំពោះការផ្លាស់ប្តូរ ជាអាទិ៍**

១-ប្រសិនបើមានការផ្លាស់ប្តូរនូវចំណុចដែលបានចុះក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីចំពោះការផ្លាស់ប្តូរនោះ ។

២-ប្រសិនបើប្តីប្រពន្ធបានលែងលះអាពាហ៍ពិពាហ៍ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍-ពិពាហ៍ជាមួយគ្នាបានលែងលះកំជាប់ពាក្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវដាក់ពាក្យលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាមួយគ្នា ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ជនដែលបានកំណត់ខាងក្រោមនេះ អាចដាក់ពាក្យសុំលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតែឯកឯងបាន ប្រសិនបើមានហេតុដូចតទៅនេះ :

ក-ប្រសិនបើសហព័ទ្ធណាម្នាក់បានស្លាប់ គឺ សហព័ទ្ធដែលនៅរស់ ។

ខ-ប្រសិនបើមានសេចក្តីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិ ក្នុងសាលក្រម ឬ សាលដីការលែងលះអាពាហ៍ពិពាហ៍ដែលបានចូលជាស្ថាពរ គឺ អតីតសហព័ទ្ធណាម្នាក់ ។

គ-ប្រសិនបើតុលាការបានសម្រេចសេចក្តីអំពីការបែងចែកទ្រព្យសម្បត្តិ ដោយការលែងលះអាពាហ៍ពិពាហ៍ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយសេចក្តីសម្រេចនោះចូលជាស្ថាពរ គឺ អតីតសហព័ទ្ធណាម្នាក់ ។

ឃ-ប្រសិនបើហេតុការណ៍ដែលលែងលះកំជាប់ពាក្យ ត្រូវបានបញ្ជាក់ដោយជាក់លាក់ នៅក្នុងសាលក្រម ឬ សាលដីកាស្ថាពរ ដែលសម្រេចអំពីការទាមទារដោយផ្អែកលើហេតុការណ៍លែងលះកំ-ជាប់ពាក្យ គឺ ភាគីណាម្នាក់ ។

៤-ចំណុចដែលត្រូវសរសេរចូលក្នុងពាក្យសុំ និង ឯកសារដែលត្រូវភ្ជាប់ជាមួយនឹងពាក្យសុំ សម្រាប់ការដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៣១.- ការបញ្ជាក់**

បុគ្គលណាក៏ដោយ ក៏អាចសុំឱ្យធ្វើការបញ្ជាក់ចំពោះចំណុចដែលបានចុះ ឬ មិនបានចុះនៅក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានដែរ ដោយត្រូវបង់សោហ៊ុយ ។

**មាត្រា ៣២.- ការប្រគល់សិទ្ធិឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើប្រកាស**

ទម្រង់នៃពាក្យសុំ ការបញ្ជាក់ និង បញ្ហាផ្សេងទៀតដែលចាំបាច់សម្រាប់ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិ ប្តីប្រពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ចំនួនសោហ៊ុយត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៣.- ការអនុញ្ញាតឱ្យអនីតិជនប្រកបអាជីវកម្ម**

ការអនុញ្ញាតឱ្យអនីតិជនប្រកបអាជីវកម្ម ដោយអ្នកមានអំណាចមេបា ដែលបានធ្វើឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ត្រូវចាត់ទុកជាការអនុញ្ញាតឱ្យប្រកបអាជីវកម្មដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ២០ (អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម) នៃក្រមរដ្ឋប្បវេណី ។

**មាត្រា ៣៤.- ការចាត់ចែងអំពីសាជីវកម្ម ឬមូលនិធិដែលមានអត្ថិភាពតាំងពីមុនកាលបរិច្ឆេទនៃការអនុវត្ត**

១-សាជីវកម្មដែលមានទ្រព្យសម្បត្តិឯកកម្មសិទ្ធិមានតម្លៃមិនតិចជាង ២០.០០០.០០០(ម្ភៃលាន) រៀល ហើយដែលជាសាជីវកម្មមានគោលបំណងមិនទាញយកចំណេញ ឬ មូលនិធិដែលមានទ្រព្យសម្បត្តិឯកកម្មសិទ្ធិមានតម្លៃ មិនតិចជាង ២០០.០០០.០០០ (ពីររយលាន) រៀល ហើយដែលជាមូលនិធិ

# ឧបសម្ព័ន្ធលេខ០២

## ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្ដី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ២ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៣ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការជ្រើសតាំងអ្នកវាយតម្លៃ ដោយយោងតាមបញ្ញត្តិនៃមាត្រា១៨៥ (កម្មសិទ្ធិនៃបាតទន្លេ ឬស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី) | តុលាការដែលបានកំណត់នៅក្នុងមាត្រា ១៨៥ (កម្មសិទ្ធិនៃបាតទន្លេ ឬស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី) |
| ៣ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៤ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការអនុញ្ញាតឱ្យអនុវត្តសិទ្ធិឧបាទេសកម្ម ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៤២៣ (ល័ក្ខខ័ណ្ឌដើម្បីអនុវត្តសិទ្ធិឧបាទេសកម្ម) | តុលាការនៃលំនៅឋានរបស់កូនបំណុល |
| | ២ ការអនុញ្ញាតឱ្យលក់ដេញថ្លៃនូវវត្ថុដែលជាកម្មវត្ថុនៃការសង ដោយយោងតាមបញ្ញត្តិនៃមាត្រា៤៥៨ (សិទ្ធិលក់ដោយខ្លួនឯង) | តុលាការនៃកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច |
| ៤ | ចំណុចលើកឡើងខាងក្រោមនេះ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងគន្ថីទី៧ នៃក្រមរដ្ឋប្បវេណី | |
| | ១ ការសម្រេចសេចក្ដីជំនួសការយល់ព្រមចំពោះអាពាហ៍ពិពាហ៍របស់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា៩៤៣ (ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន) | តុលាការនៃលំនៅឋានរបស់អនីតិជន |
| | ២ ការចាត់ចែងទាក់ទងនឹងចំណែកបន្ទុកនៃសោហ៊ុយដែលកើតឡើងពីអាពាហ៍ពិពាហ៍ ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៧១ (ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍) | តុលាការនៃលំនៅឋានរបស់ភាគីម្ខាងទៀត |
| | ៣ ការសម្រេចសេចក្ដីអំពីការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៤ មាត្រា៩៧៤ (ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់ប្ដី ឬប្រពន្ធ |
| | ៤ ការអនុញ្ញាតឱ្យចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា៩៧៦ (ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ) | តុលាការនៃលំនៅឋានរបស់ប្ដី ឬប្រពន្ធ |
| | ៥ ពាក្យសុំលែងលះដោយការព្រមព្រៀង ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៧៩ (ការលែងលះដោយការព្រមព្រៀង) | តុលាការនៃលំនៅឋានរបស់ប្ដី ឬប្រពន្ធ |
| | ៦ ការបែងចែកទ្រព្យសម្បត្តិ ដោយយោងតាមបញ្ញត្តិនៃមាត្រា៩៨០ (ការបែងចែកទ្រព្យសម្បត្តិ) | តុលាការនៃលំនៅឋានរបស់ប្ដី ឬប្រពន្ធ |
| | ៧ ពាក្យសុំឱ្យបង្កើតសុំកូនពេញលេញ ដោយយោងតាមបញ្ញត្តិនៃមាត្រា១០០៧ (ទម្រង់នៃការបង្កើតសុំកូនពេញលេញ) | តុលាការនៃលំនៅឋានរបស់អ្នកដែលនឹងក្លាយទៅជាឪពុកម្ដាយចិញ្ចឹម |

# ឧបសម្ព័ន្ធលេខ០៣
# ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជី
# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការចុះបញ្ជី

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ


រៀបចំដោយ
ក្រុមការងារក្រសួងយុត្តិធម៌
និង
ទីប្រឹក្សាផ្នែកច្បាប់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
ប្រចាំក្រសួងយុត្តិធម៌


p


ក្រសួងយុត្តិធម៌
បោះពុម្ពលើកទីមួយ ចំនួន ៥០០ ក្បាល
នៅរាជធានីភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០១៤

ប្រកាស ស្តីពី
នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ
ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ (ដំណាក់កាលទី ៤)
នៅក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ២០១៤

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ
គឺជាគម្រោងសហប្រតិបត្តិការបច្ចេកទេស
រវាង
ក្រសួងយុត្តិធម៌
និង
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ចំណាប់អារម្មណ៍របស់
## ឯកឧត្តម អង្គ វង្សវឌ្ឍនា
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង និងមោទនភាពខ្ពស់ដោយក្រសួងយុត្តិធម៌ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវសមិទ្ធផលជាច្រើនជាបន្តបន្ទាប់រួមមានៈ បញ្ញត្តិមូលដ្ឋាន បញ្ញត្តិបន្ទាប់បន្សំ និងបញ្ញត្តិពិសេស ដែលបទប្បញ្ញត្តិទាំងនោះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ទៅនឹងការរស់នៅក្នុងសង្គម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។

ជាមួយគ្នានេះដែរ នៅក្នុងទំនាក់ទំនងរវាង បុគ្គល និងបុគ្គល ដែលបានរៀបអាពាហ៍ពិពាហ៍ និងបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមាននូវធនធានទ្រព្យសម្បត្តិជាចលនវត្ថុក្តី ជាអចលនវត្ថុក្តី គប្បីបញ្ជាក់ឲ្យបានច្បាស់អំពីសិទ្ធិទៅលើទ្រព្យសម្បត្តិនោះ ថាតើធនធានទ្រព្យសម្បត្តិណាខ្លះជាសិទ្ធិរួម ? ហើយធនធានទ្រព្យសម្បត្តិណាខ្លះ ជាសិទ្ធិផ្តាច់មុខរបស់ភាគីណាមួយ ?

ករណីនេះ នៅប្រទេសជឿនលឿនមួយចំនួន ដើម្បីបើកឱកាសឲ្យភាគីអាចកំណត់ឲ្យបានច្បាស់លាស់នូវទំនាក់ទំនងទ្រព្យសម្បត្តិទាំងនោះ និងងាយស្រួលដល់ការដោះស្រាយវិវាទទៅលើទំនាក់ទំនងទ្រព្យសម្បត្តិ គេបានរៀបចំឲ្យមានបទប្បញ្ញត្តិ ដែលទាក់ទងទៅនឹង ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ។

ទស្សនៈនៃគោលគំនិត ក្នុងការកំណត់នូវទំនាក់ទំនងនៃទ្រព្យសម្បត្តិនេះ ក៏ត្រូវបានយកមកបញ្ចូលនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយបានអនុវត្តកាលពីថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ កន្លងមកនេះ ។

នៅក្នុងមាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណីបានចែងថា ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយរៀបអាពាហ៍ពិពាហ៍បាន ឲ្យតែមិនផ្ទុយនឹងសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុង ។ បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេស ចំពោះទ្រព្យសម្បត្តិនោះទេ នោះត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ។ p

រីឯមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានប្រគល់សមត្ថកិច្ចឲ្យក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយក្រសួងត្រូវរៀបចំកំណត់អំពី បែបបទ និងទម្រង់ នៃការចុះបញ្ជីតាមរយៈប្រកាសរបស់ក្រសួង ។

ផ្អែកតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌បានបង្កើតក្រុមការងារមួយ ដោយសហការ ជាមួយជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ដើម្បីរៀបចំ បែបបទ និងទម្រង់ នៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយប្រើប្រព័ន្ធចុះបញ្ជីដែលរៀបចំឡើងដោយប្រើក្រដាសដាក់ក្នុងក្រណ្ឌ ។

ជាមួយនឹងការអបអរសាទរនៃភាពជោគជ័យ របស់ក្រុមការងារក្នុងការរៀបចំប្រកាសនេះ ខ្ញុំក៏សូមធ្វើការវាយតម្លៃខ្ពស់ កោតសរសើរ និងសូមថ្លែងអំណរគុណ ដោយស្មោះអស់ពីចិត្ត ចំពោះស្មារតីទទួលខុសត្រូវខ្ពស់បំផុត និងការខិតខំប្រឹងប្រែង ការព្យាយាម យកអស់ពីកំលាំងកាយ និងបញ្ញាស្មារតី របស់ក្រុមការងារ និងជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ។ ជាពិសេស ក្រុមការងារសាស្ត្រាចារ្យជប៉ុន ដែលបានចូលរួម ប្រឹក្សាយោបល់ នៅក្នុងការរៀបចំ បទប្បញ្ញត្តិគតិយុត្តដ៏មានសារៈសំខាន់នេះ ហើយក៏ជាផ្នែកមួយនៃការអភិវឌ្ឍវិស័យច្បាប់ ស្របតាមគោលនយោបាយ ស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

ជំហានបន្ទាប់ ក្រសួងយុត្តិធម៌ក៏បានកំណត់ទិសដៅឲ្យ ក្រុមការងារដែលបានរៀបចំប្រកាសនេះ ត្រូវធ្វើការបណ្តុះបណ្តាល និង ផ្សព្វផ្សាយប្រកាសនេះ ឲ្យបានទូលំទូលាយទៅដល់មន្ត្រីអនុវត្តច្បាប់និងប្រជាពលរដ្ឋទូទៅ ។

ក្រសួងយុត្តិធម៌មានជំនឿយ៉ាងមុតមាំថា ប្រកាសនេះនឹងក្លាយជាឧបករណ៍គតិយុត្តដ៏សំខាន់ ដែលផ្តល់សិទ្ធិ និងបើកឱកាស ឲ្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមានបំណងចង់ធ្វើការចុះបញ្ជី អាចធ្វើការចុះបញ្ជី អំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន ហើយឈានទៅដល់ការបង្កើតទំនាក់ទំនងរវាង បុរស និងស្ត្រី ឲ្យមានភាពច្បាស់លាស់ និងតម្លាភាព ពាក់ព័ន្ធនឹងបញ្ហាទ្រព្យសម្បត្តិ និងចូលរួមចំណែកក្នុងការពង្រឹងគោលការណ៍សមភាពយេនឌ័រនៅក្នុងសង្គម ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

p

**អង្គ វង្សវឌ្ឍនា**

## ប្រធានក្រុមការងារតាក់តែងច្បាប់

| | | |
|---|---|---|
| ឯកឧត្តម | **អង្គ វង្សវឌ្ឍនា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |

## សមាសភាពក្រុមការងារក្រសួងយុត្តិធម៌ដែលទទួលបន្ទុកតាក់តែងប្រកាសស្តីពី "ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ"

| | | |
|---|---|---|
| លោកជំទាវ | **ចាន់ សុធាវី** | រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ (ប្រធាន) |
| ឯកឧត្តម | **យាន ស៊ីណា** | អតីតអនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ |
| លោក | **និត្យ ឫទ្ធី** | ចៅក្រមនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ម៉ៅ តិរុណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| លោកស្រី | **សូរ ដានី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងយុត្តិធម៌ |
| លោក | **ទូច ថារិទ្ធ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **កែវ សេដ្ឋា** | អតីតអនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **ហុក ច័ន្ទសុវណ្ណារ៉ា** | អនុប្រធានការិយាល័យកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **អុល ធីរៈ** | អនុប្រធានការិយាល័យកិច្ចការអយ្យការនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ឡាយ លីនណា** | អនុប្រធានការិយាល័យបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **សួន ណារី** | មន្ត្រីគ្រប់គ្រងរដ្ឋបាលនៃក្រសួងយុត្តិធម៌ |

## ជំនាញការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ប្រចាំក្រសួងយុត្តិធម៌

| | | |
|---|---|---|
| លោក | Issei SAKANO | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Hiroshi KIYOHARA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Masayoshi HARADA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Emiko KANETAKE | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Ayako TAMIYA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Miha ISOI | ទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

## សមាសភាពសាស្ត្រាចារ្យជប៉ុនដែលបានប្រឹក្សាយោបល់ក្នុងការរៀបចំប្រកាស

| | | |
|---|---|---|
| លោក | Akio MORISHIMA | សាស្ត្រាចារ្យកិត្តិយសនៃសាកលវិទ្យាល័យ Nagoya (ប្រធាន) |
| លោក | Ikufumi NIIMI | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Meiji |
| លោក | Michitaro URAKAWA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Kaoru KAMATA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Yutaka YAMAMOTO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Kyoto |
| លោក | Tsuneo MATSUMOTO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Hitotsubashi |
| លោក | Yoshihisa NOMI | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Gakushuin |

| | | |
|---|---|---|
| លោក | Toshifumi MINAMI | អតីតចៅក្រមសាលាឧទ្ធរណ៍នៃទីក្រុងតូក្យូ |
| លោក | Toyohiro NOMURA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Gakushu-in |
| លោក | Masayuki TANAMURA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Keita SATO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Chuo |
| លោក | Atsushi MOTOYAMA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Ritsumeikan |
| លោក | Hiroshi MATSUO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Keio |
| លោក | Hisaya HATANAKA | ជំនួយការសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Fukuoka |
| លោក | Keisuke ENDO | មន្ត្រីនៃការិយាល័យកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | Kazuo UESAKA | សាស្ត្រាចារ្យនៃនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌ |

**សមាសភាពលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាយោបល់**

| | | |
|---|---|---|
| លោក | Atsuhito YOSHIMOTO | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |
| លោក | Hisashi NAGAYA | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |

**អ្នកបកប្រែ :**

| | | |
|---|---|---|
| លោក | **គីម ពេជ្រដា** | អតីតជំនួយការ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **កែវ ពិសី** | អតីតជំនួយការ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **កែវ ម៉ានី** | អតីតមន្ត្រីច្បាប់ជាន់ខ្ពស់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **ឡៀម សុខសិរីយស** | អតីតជំនួយការផ្នែកច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **ខ៉ែត ណារ័ត្ន** | មន្ត្រីច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **សោម តេនា** | ជំនួយការផ្នែកច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| កញ្ញា | **ស៊ី ច័ន្ទឌីម៉ា** | ជំនួយការរដ្ឋបាល នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## ជំពូកទី ១- បទប្បញ្ញត្តិទូទៅ


ប្រការ ១ - គោលដៅ ........................................ ២

ប្រការ ២ - គោលបំណង ........................................ ២

ប្រការ ៣ - វិសាលភាព ........................................ ២


## ជំពូកទី ២- សមត្ថកិច្ចចុះបញ្ជី


ប្រការ ៤ - ស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជី ........................................ ២


## ជំពូកទី ៣- ការបង្កើត ការគ្រប់គ្រងក្រូណូ និងអំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូ

### ផ្នែកទី ១- ការបង្កើតក្រូណូ


ប្រការ ៥ - ការបង្កើតក្រូណូ ........................................ ៣

ប្រការ ៦ - ក្រូណូទទួលពាក្យសុំ ........................................ ៣

ប្រការ ៧ - ក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........................................ ៤

ប្រការ ៨ - ក្រូណូសម្រាក់ដាក់ឯកសារពាក្យសុំ ........................................ ៤

ប្រការ ៩ - ក្រូណូលើកចោល ........................................ ៤

ប្រការ ១០ - ក្រូណូសម្រាក់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ........................................ ៤

ប្រការ ១១ - ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ........................................ ៤


### ផ្នែកទី ២- ការគ្រប់គ្រងក្រូណូ


ប្រការ ១២ - ការគ្រប់គ្រងក្រូណូ ........................................ ៥


### ផ្នែកទី ៣- អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូ


ប្រការ ១៣ - ការរក្សាទុកឯកសារក្នុងក្រូណូទទួលពាក្យសុំ និងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........................................ ៥

ប្រការ ១៤ - អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំ ក្រូណូលើកចោល ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ........................................ ៥


## ជំពូកទី ៤- បទប្បញ្ញត្តិទូទៅ នៃពាក្យសុំចុះបញ្ជី


ប្រការ ១៥ - ពាក្យសុំចុះបញ្ជី ........................................ ៥

ប្រការ ១៦ - ទម្រង់នៃពាក្យសុំចុះបញ្ជី ........................................ ៦

ប្រការ ១៧ - ឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី ........................................ ៦

ប្រការ ១៨ - ការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់........................................៧


## ជំពូកទី ៥- ពាក្យសុំចុះបញ្ជី

ប្រការ ១៩ - ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ........................................៧
ប្រការ ២០ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ........................................៨
ប្រការ ២១ - ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ........................................៨
ប្រការ ២២ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ
រំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ........................................៩
ប្រការ ២៣ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ
មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ........................................១០
ប្រការ ២៤ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ
សហព័ទ្ធណាម្នាក់បានស្លាប់........................................១០
ប្រការ ២៥ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើ
សាលក្រម ឬ សាលដីកាស្ថាពរ រំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ..១១
ប្រការ ២៦ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តី
សម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែល
មិនមែនជាបណ្តឹង........................................១១
ប្រការ ២៧ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកតាម
សាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្ត
ក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ........................................១២
ប្រការ ២៨ - ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍........................................១២


## ជំពូកទី ៦- ការទទួល ការពិនិត្យពាក្យសុំចុះបញ្ជី និងពាក្យសុំឲ្យពិនិត្យឡើងវិញ

ប្រការ ២៩ - ការទទួលពាក្យសុំចុះបញ្ជី........................................១៣
ប្រការ ៣០ - ការដកពាក្យសុំចុះបញ្ជី........................................១៣
ប្រការ ៣១ - ការពិនិត្យពាក្យសុំចុះបញ្ជី........................................១៣
ប្រការ ៣២ - ការកែតម្រូវ និងការលើកចោលពាក្យសុំចុះបញ្ជី........................................១៣
ប្រការ ៣៣ - ការប្រគល់ឯកសារភ្ជាប់ឲ្យវិញ........................................១៤
ប្រការ ៣៤ - ពាក្យសុំឲ្យពិនិត្យឡើងវិញចំពោះការលើកចោលរបស់មន្ត្រីចុះបញ្ជី........................................១៤
ប្រការ ៣៥ - ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ........................................១៤
ប្រការ ៣៦ - អានុភាពនៃការចុះបញ្ជី........................................១៤


## ជំពូកទី ៧- របៀបចុះបញ្ជី និងចងក្រងទុកក្នុងក្រឡា

ប្រការ ៣៧ - របៀបចុះបញ្ជីក្នុងក្រឡាទទួលពាក្យសុំ........................................១៥

ប្រការ ៣៨ - របៀបចុះបញ្ជីក្នុងក្រ្គណាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.................................១៥
ប្រការ ៣៩ - របៀបចុះបញ្ជីក្នុងក្រ្គណាចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ............១៥
ប្រការ ៤០ - របៀបចុះបញ្ជីក្នុងក្រ្គណាចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ............១៦
ប្រការ ៤១ - របៀបចុះបញ្ជីក្នុងក្រ្គណាចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.១៦
ប្រការ ៤២ - របៀបចុះបញ្ជីក្នុងក្រ្គណាចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍.................១៦
ប្រការ ៤៣ - វិធីកត់ត្រាការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ .........................១៧
ប្រការ ៤៤ - របៀបចងក្រងរក្សាទុកក្នុងក្រ្គណាសម្រាប់ដាក់ឯកសារពាក្យសុំ.........................................១៧
ប្រការ ៤៥ - របៀបចងក្រងរក្សាទុកក្នុងក្រ្គណាលើកចោល........................................................................១៧
ប្រការ ៤៦ - របៀបចងក្រងរក្សាទុកក្នុងក្រ្គណាសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ.......................១៧
ប្រការ ៤៧ - របៀបចងក្រងរក្សាទុកក្នុងក្រ្គណាសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី....១៨

## ជំពូកទី ៨- នីតិវិធីនៃការចេញលិខិតបញ្ជាក់

ប្រការ ៤៨ - របៀបដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ..................................................................១៨
ប្រការ ៤៩ - ការចេញលិខិតបញ្ជាក់..........................................................................................................១៨

## ជំពូកទី ៩- អវសានប្បញ្ញត្តិ

ប្រការ ៥០ - កាលបរិច្ឆេទ នៃការអនុវត្ត......................................................................................................១៩

ឧបសម្ព័ន្ធទី ១ - ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.........................................................២០
ឧបសម្ព័ន្ធទី ២ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ...............................២១
ឧបសម្ព័ន្ធទី ៣ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន ...............................................២២
ឧបសម្ព័ន្ធទី ៤ - ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ..............២៣
ឧបសម្ព័ន្ធទី ៥ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ......................២៤
ឧបសម្ព័ន្ធទី ៦ - ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ .........................................២៥
ឧបសម្ព័ន្ធទី ៧ - ពាក្យសុំឲ្យចេញលិខិតបញ្ជាក់......................................................................................២៦
ឧបសម្ព័ន្ធទី ៨ - សន្លឹកក្រដាសទទួលពាក្យសុំ .......................................................................................២៧
ឧបសម្ព័ន្ធទី ៩ - សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ............................................................២៨
ឧបសម្ព័ន្ធទី ១០ - សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ...........................................២៩
គំរូចុះបញ្ជី ១ - សន្លឹកក្រដាសទទួលពាក្យសុំ ..........................................................................................៣០
គំរូចុះបញ្ជី ២ - ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) ..........................................៣១
គំរូចុះបញ្ជី ៣ - ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា)........................៣២
គំរូចុះបញ្ជី ៤ - ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) ............................................៣៤
គំរូចុះបញ្ជី ៥ - ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា) ........................៣៥
គំរូចុះបញ្ជី ៦ - ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) ...............................៣៧

គំរូចុះបញ្ជី ៧ - ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា) ........៣៨
គំរូចុះបញ្ជី ៨ - ការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋានជាអាទិ៍ (សន្លឹកចុះបញ្ជី).......................................៣៩

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ៤២.ករយ.ប្រក/១៣

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322 023 2 7 841

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ : គោលដៅ**

ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលបង្កើតអានុភាពរវាងបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឲ្យបានត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

**ប្រការ ២ : គោលបំណង**

គោលបំណងនៃប្រកាសនេះ គឺអនុញ្ញាតឲ្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចធ្វើការចុះបញ្ជីកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយការរៀបអាពាហ៍ពិពាហ៍បាន ដើម្បីកំណត់ឲ្យបានច្បាស់លាស់ អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ។

**ប្រការ ៣ : វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តទៅលើចំណុច ដូចខាងក្រោម ៖

- ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- នីតិវិធីនៃការចេញលិខិតបញ្ជាក់។

## ជំពូកទី ២
## សមត្ថកិច្ចចុះបញ្ជី

**ប្រការ ៤ : ស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជី**

១- នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

២- មន្ត្រីដែលទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (មន្ត្រីចុះបញ្ជី) ត្រូវនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ។

៣- ក្រូណូទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវរក្សាទុកនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ។

## ជំពូកទី ៣
## ការបង្កើត ការគ្រប់គ្រងក្រូណូ និងរយៈពេលរក្សាទុកឯកសារក្នុងក្រូណូ
### ផ្នែកទី ១
### ការបង្កើតក្រូណូ

**ប្រការ ៥ : ការបង្កើតក្រូណូ**

នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ត្រូវបង្កើតក្រូណូ ដូចខាងក្រោម ៖

១. ក្រូណូទទួលពាក្យសុំ

២. ក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

៣. ក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ

៤. ក្រូណូលើកចោល

៥. ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ

៦. ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី

**ប្រការ ៦ : ក្រូណូទទួលពាក្យសុំ**

១- ក្រូណូទទួលពាក្យសុំ គឺជាក្រូណូសម្រាប់ចុះព័ត៌មាន ដូចជា ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និងចុះលេខទទួលពាក្យសុំនៅលើពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ និងពាក្យសុំលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

២- សន្លឹកក្រដាសទទួលពាក្យសុំ ដែលដាក់ក្នុងក្រូណូ ត្រូវមានតារាងបែងចែកខ្ទង់ ដូចខាងក្រោមនេះ ៖

- លេខរៀងទទួលពាក្យ
- កាលបរិច្ឆេទ នៃការទទួលពាក្យ
- ប្រភេទ នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ
- ជាប្ដីប្រពន្ធ
- បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន)
- ផ្សេងៗ

**ប្រការ ៧ : ក្រុណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

១- ក្រុណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺជាក្រុណ្ឌសម្រាប់ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

២- សន្លឹកចុះបញ្ជី ដែលដាក់ក្នុងក្រុណ្ឌ ត្រូវមានតារាងបែងចែកខ្ទង់ ដូចខាងក្រោមនេះ ៖

- លេខចុះបញ្ជី និង លេខទទួលពាក្យសុំ
- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់កាគីនៃកិច្ចសន្យា
- ការផ្លាស់ប្ដូរឈ្មោះ និងអាសយដ្ឋាន
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណង និងមូលហេតុនៃការចុះបញ្ជី
- ខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ការលុបការចុះបញ្ជី អំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

**ប្រការ ៨ : ក្រុណ្ឌសម្រាប់ដាក់ឯកសារពាក្យសុំ**

ក្រុណ្ឌសម្រាប់ដាក់ឯកសារពាក្យសុំ គឺជាក្រុណ្ឌសម្រាប់ដាក់ពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់ ដែលមន្ត្រីចុះបញ្ជីបានទទួលពីអ្នកដាក់ពាក្យសុំ ។

**ប្រការ ៩ : ក្រុណ្ឌលើកចោល**

ក្រុណ្ឌលើកចោល គឺជាក្រុណ្ឌសម្រាប់ដាក់លិខិតលើកចោលពាក្យសុំចុះបញ្ជីរបស់មន្ត្រីចុះបញ្ជី។

**ប្រការ ១០ : ក្រុណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ**

ក្រុណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ គឺជាក្រុណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ព្រមទាំងដាក់សេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងឯកសារដែលភ្ជាប់មកជាមួយ ។

**ប្រការ ១១ : ក្រុណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

ក្រុណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី គឺជាក្រុណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យធ្វើការបញ្ជាក់ ចំពោះចំណុចដែលបានចុះ ឬ មិនបានចុះនៅក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

p

## ផ្នែកទី ២
## ការគ្រប់គ្រងក្រុមណ្ឌ

ប្រការ ១២ : ការគ្រប់គ្រងក្រុមណ្ឌ

ក្រុមណ្ឌ គឺត្រូវគ្រប់គ្រង និងរក្សាទុកនៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ ។

## ផ្នែកទី ៣
## អំឡុងពេលរក្សាទុកឯកសារក្នុងក្រុមណ្ឌ

ប្រការ ១៣ : ការរក្សាទុកឯកសារក្នុងក្រុមណ្ឌទទួលពាក្យសុំ និងក្រុមណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឯកសារក្នុងក្រុមណ្ឌទទួលពាក្យសុំ និងក្រុមណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវរក្សាទុកជានិរន្តរ៍ ។

ប្រការ ១៤ : អំឡុងពេលរក្សាទុកឯកសារក្នុងក្រុមណ្ឌសម្រាប់ដាក់ឯកសារពាក្យសុំ ក្រុមណ្ឌលើកចោល ក្រុមណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ក្រុមណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី

១- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុមណ្ឌសម្រាប់ដាក់ឯកសារពាក្យសុំ មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំ ។

២- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុមណ្ឌលើកចោល មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតលើកចោល ។

៣- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុមណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ។

៤- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុមណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ។

## ជំពូកទី ៤
## បទប្បញ្ញត្តិទូទៅ នៃពាក្យសុំចុះបញ្ជី

ប្រការ ១៥ : ពាក្យសុំចុះបញ្ជី

p

១- រាល់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ពាក្យសុំច្បាប់ដើម ត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងនៃច្បាប់ដើមនោះ ។

២- ជាគោលការណ៍ ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវធ្វើឡើងរួមគ្នា។ លើកលែងតែករណីដូចខាងក្រោម អាចដាក់ពាក្យសុំតែម្នាក់ឯងបាន ៖

ក. ការផ្លាស់ប្តូរ ឬ ការកែតម្រូវតែ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។

ខ. ការចុះបញ្ជី ដោយផ្អែកលើសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចស្ថាពរ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដូចមានចែងនៅក្នុងមាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ខ, គ, ឃ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

៣- រាល់ពាក្យសុំចុះបញ្ជីខាងលើ អ្នកតំណាងក៏អាចកាន់យកមកដាក់នៅ ចំពោះមុខមន្ត្រីចុះបញ្ជីជំនួសប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ ។

៤- បុគ្គល ឬ អ្នកតំណាង ដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវយកពាក្យសុំនោះ មកដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ដោយផ្ទាល់ ។

**ប្រការ ១៦ : ទម្រង់នៃពាក្យសុំចុះបញ្ជី**

១- ទម្រង់នៃពាក្យសុំចុះបញ្ជី ត្រូវសរសេរជាភាសាខ្មែរ ពាក្យសុំចុះបញ្ជី ដែលត្រូវសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ពាក្យសុំចុះបញ្ជី ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន) ហើយត្រូវគោរពចូលមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ។

២- ក្រៅពីនេះ ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ។

**ប្រការ ១៧ : ឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី**

១- នៅពេលដាក់ពាក្យសុំចុះបញ្ជី អ្នកដាក់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនទៅឲ្យនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនោះ ។

២- ចំពោះពាក្យសុំចុះបញ្ជី ដែលអ្នកតំណាងយកមកដាក់ ដូចមានចែងក្នុងប្រការ ១៥ កថាខណ្ឌទី៣ ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិតំណាងផងដែរ ។

ប្រការ ១៨ : ការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់

១- ចំពោះឯកសារដែលភ្ជាប់ជាមួយនឹងពាក្យសុំ អ្នកដាក់ពាក្យសុំអាចទាមទារឲ្យប្រគល់វិញនៅពេលដាក់ពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះលិខិតប្រគល់សិទ្ធិតំណាង ។

២- ដើម្បីទាមទារឲ្យប្រគល់ឯកសារភ្ជាប់ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងពាក្យសុំនោះ នូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះគ្មានភាពខុសពីច្បាប់ដើម ។

៣- ក្នុងករណីដែលប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីត្រូវឲ្យអ្នកទទួលការប្រគល់សរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នូវការណ៍ ដែលខ្លួនបានទទួលការប្រគល់ឯកសារនោះ និងចុះហត្ថលេខា ។

## ជំពូកទី ៥
## ពាក្យសុំចុះបញ្ជី

ប្រការ ១៩ : ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១- ប្រសិនបើមានការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចដាក់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

ឃ- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ង- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍។

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនឹងបញ្ហាដីធ្លី
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

## ប្រការ ២០ ៖ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

១- ប្រសិនបើមានការផ្លាស់ប្ដូរនូវចំណុចដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរនោះ ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃការផ្លាស់ប្ដូរ)

ឃ– ចំណុចដែលត្រូវផ្លាស់ប្ដូរ

- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធថ្មី
- ឈ្មោះ ឬ អាសយដ្ឋានថ្មី

ឯកសារភ្ជាប់៖

- កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធថ្មី
- សាលក្រម ឬ ដីកាសម្រេចផ្លាស់ប្ដូរ
- លិខិតបញ្ជាក់អំពីការផ្លាស់ប្ដូរអាសយដ្ឋាន
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិផលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្រោយពេលមានការផ្លាស់ប្ដូរ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

## ប្រការ ២១ ៖ ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

១- នៅពេលកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថាមានកំហុស ឬ ខកខានមិនបានចុះបញ្ជី ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីកែតម្រូវ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– គោលបំណង

p

ខ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទដែលបានកែតម្រូវ)

គ– ចំណុចដែលត្រូវកែតម្រូវ

- ឈ្មោះ
- អាសយដ្ឋាន

- ថ្ងៃ ខែ ឆ្នាំកំណើត
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឯកសារភ្ជាប់៖

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិផ្លុលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនឹងបញ្ហាដីធ្លី ក្រោយពេលមានការកែតម្រូវ
- លិខិតបញ្ជាក់អាសយដ្ឋាន
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២២ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុលែងលះអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ**

១- ប្រសិនបើប្តីប្រពន្ធបានលែងលះអាពាហ៍ពិពាហ៍ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានលែងលះកំជាប់ពាក្យ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទលែងលះអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ)

ឯកសារភ្ជាប់៖

- ដីកាសម្រេច ដែលលែងលះអាពាហ៍ពិពាហ៍តាមការព្រមព្រៀង
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេច
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹងពីការលែងលះកំជាប់ពាក្យ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

### ប្រការ ២៣ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដោយមូលហេតុមោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

១- ប្រសិនបើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដែលបានចុះបញ្ជីរួច ត្រូវបានមោឃៈ រំលាយ ឬ លុបចោល ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមោឃភាព, ការលុបចោល, ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់ថាកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវបានមោឃៈ លុបចោល ឬ រំលាយ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹង ដែលបញ្ជាក់ពីការលុបចោល ឬ រំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

### ប្រការ ២៤ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដោយមូលហេតុសហព័ទ្ធណាម្នាក់បានស្លាប់

១- ប្រសិនបើសហព័ទ្ធណាម្នាក់បានស្លាប់ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានស្លាប់ សហព័ទ្ធដែលនៅរស់ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដែលនៅរស់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី p

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមរណភាព)

ឯកសារភ្ជាប់:

- សំបុត្រមរណភាព
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)

- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៥ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ លែងលះអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ**

១- ប្រសិនបើមានសេចក្តីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិក្នុងសាលក្រម ឬ សាលដីកាលែងលះអាពាហ៍ពិពាហ៍ដែលបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាលែងលះអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិដែលបានចូលជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៦ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**

១- ប្រសិនបើតុលាការសម្រេចសេចក្តី អំពីការបែងចែកទ្រព្យសម្បត្តិ ដោយការលែងលះអាពាហ៍ពិពាហ៍ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយសេចក្តីសម្រេចនោះបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់តុលាការ)

ឯកសារភ្ជាប់:

- ដីកាសម្រេចការបែងចែកទ្រព្យសម្បត្តិដោយការលែងលះអាពាហ៍ពិពាហ៍ ដែលបានចូលជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេច
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៧ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកតាមសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ**

១- នៅពេលមានសាលក្រម ឬ សាលដីកាស្ថាពរដែលកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ ភាគីណាម្នាក់ ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជី។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៨: ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍**

១- នៅពេលដែលបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា បានរៀបអាពាហ៍ពិពាហ៍ក្រោយពីបានធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បុគ្គលនោះត្រូវដាក់ពាក្យសុំចុះបញ្ជីបន្ថែមអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

ឯកសារភ្ជាប់:

- សំបុត្រអាពាហ៍ពិពាហ៍
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

## ជំពូកទី ៦
## ការទទួល ការពិនិត្យពាក្យសុំចុះបញ្ជី និងពាក្យសុំឲ្យពិនិត្យឡើងវិញ

**ប្រការ ២៩ : ការទទួលពាក្យសុំចុះបញ្ជី**

នៅពេលមន្ត្រីចុះបញ្ជី បានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចុះនិទ្ទេសនៅលើពាក្យសុំនោះ នូវលេខរៀងទទួលពាក្យសុំ កាលបរិច្ឆេទ និងឈ្មោះនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ព្រមទាំងហត្ថលេខាបំព្រួញ និងឈ្មោះមន្ត្រីចុះបញ្ជីនោះ ។

**ប្រការ ៣០ : ការដកពាក្យសុំចុះបញ្ជី**

ពាក្យសុំចុះបញ្ជីអាចដកបានមុនពេលការចុះបញ្ជីត្រូវបានបញ្ចប់ ដោយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

**ប្រការ ៣១ : ការពិនិត្យពាក្យសុំចុះបញ្ជី**

១- មន្ត្រីចុះបញ្ជី ត្រូវពិនិត្យពាក្យសុំ និងឯកសារភ្ជាប់ ។

២- នៅពេលពិនិត្យពាក្យសុំ ដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើមន្ត្រីចុះបញ្ជីមានវិមតិសង្ស័យនោះ មន្ត្រីចុះបញ្ជីអាចធ្វើការសាកសួរបន្ថែមទៅអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាងនោះបាន ។

**ប្រការ ៣២ : ការកែតម្រូវ និងការលើកចោលពាក្យសុំចុះបញ្ជី**

១- មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតបង្គាប់ឲ្យកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ និងជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ក្នុងករណីដែលមន្ត្រីចុះបញ្ជីពិនិត្យឃើញថា ពាក្យសុំចុះបញ្ជីធ្វើឡើងពុំត្រឹមត្រូវ ដោយមានមូលហេតុ ដូចខាងក្រោម ៖

- ព័ត៌មាន និងបែបបទក្នុងពាក្យសុំចុះបញ្ជីមិនស្របតាមប្រកាសនេះ
- ពុំបានផ្តល់ឯកសារដែលចាំបាច់
- ខ្លឹមសារនៅក្នុងពាក្យសុំ និងឯកសារភ្ជាប់មិនស្របគ្នា
- ពាក្យសុំចុះបញ្ជីនោះធ្លាប់បានដាក់ និងចុះបញ្ជីម្តងរួចមកហើយ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំនៅក្នុងពាក្យសុំ មិនស្របគ្នាជាមួយនឹងការចុះបញ្ជី

- ពុំបានបង់សោហ៊ុយ ឬ
- ពាក្យសុំនោះ មិនអនុលោមតាមលក្ខខណ្ឌនៃប្រកាសនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ផ្សេងទៀត ដែលពាក់ព័ន្ធ។

៣-ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជី ពុំបានកែតម្រូវនៅក្នុងអំឡុងពេលសមរម្យនោះទេ មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតលើកចោលពាក្យសុំចុះបញ្ជីនោះ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ។

**ប្រការ ៣៣ : ការប្រគល់ឯកសារភ្ជាប់ឲ្យវិញ**

ក្នុងករណីពាក្យសុំចុះបញ្ជីត្រូវបានដក ឬ លើកចោល មន្ត្រីចុះបញ្ជីត្រូវប្រគល់ឯកសារភ្ជាប់ឲ្យទៅអ្នកដាក់ពាក្យសុំវិញ បើមានការស្នើសុំ ។

**ប្រការ ៣៤ : ពាក្យសុំឲ្យពិនិត្យឡើងវិញចំពោះការលើកចោលរបស់មន្ត្រីចុះបញ្ជី**

១- ការលើកចោលពាក្យសុំរបស់មន្ត្រីចុះបញ្ជី ដូចមានចែងក្នុងប្រការ ៣២ នៃប្រកាសនេះ អ្នកដាក់ពាក្យសុំចុះបញ្ជីមានសិទ្ធិដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

២- ពាក្យសុំឲ្យពិនិត្យឡើងវិញក្នុងកថាខណ្ឌទី១ ខាងលើនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង សម្រេច ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំនោះ ។

**ប្រការ ៣៥ : ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានដូចខាងក្រោម ៖

- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋានរបស់ភាគី
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុនៃការចុះបញ្ជី និងកាលបរិច្ឆេទ
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**ប្រការ ៣៦ : អានុភាពនៃការចុះបញ្ជី**

ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានអានុភាពនៅពេលដែលចុះហត្ថលេខា និង ប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

p

# ជំពូកទី ៧
# របៀបចុះបញ្ជី និងចងក្រងទុកក្នុងក្រណ្ឌ

**ប្រការ ៣៧ : របៀបចុះបញ្ជីក្នុងក្រណ្ឌទទួលពាក្យសុំ**

នៅពេលដែលមន្ត្រីចុះបញ្ជី បានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកក្រដាសទទួលពាក្យសុំនូវព័ត៌មាន ដូចមានចែងក្នុងកថាខណ្ឌទី២ ប្រការ ៦ នៃប្រកាសនេះ ។

**ប្រការ ៣៨ : របៀបចុះបញ្ជីក្នុងក្រណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- បន្ទាប់ពីមន្ត្រីចុះបញ្ជីបានពិនិត្យពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ១៩ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) រួច មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកចុះបញ្ជីនូវចំណុចដូចខាងក្រោមនេះ ៖

- ឈ្មោះ អាសយដ្ឋាន និងថ្ងៃ ខែ ឆ្នាំកំណើតរបស់ភាគីនៃកិច្ចសន្យា
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

២- ចំពោះសន្លឹកចុះបញ្ជីនៅក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះលេខចុះបញ្ជីផ្អែកលើលេខរៀងទទួលពាក្យសុំ ហើយចុះហត្ថលេខាបំពេញដើម្បីបញ្ជាក់ថា **"បានពិនិត្យរួច"** រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រណ្ឌ ទៅតាមលំដាប់លេខចុះបញ្ជី។

**ប្រការ ៣៩ : របៀបចុះបញ្ជីក្នុងក្រណ្ឌចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ ដែលបានកំណត់ក្នុងប្រការ ២០ (ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរ គោលបំណងនៃការចុះបញ្ជី មូលហេតុ និងកាលបរិច្ឆេទ ព្រមទាំងខ្លឹមសារនៃកិច្ចសន្យាទាំងអស់ឡើងវិញ នៅក្នុងសន្លឹក **"ផ្លាស់ប្តូរ"** ។

២- ចំពោះការផ្លាស់ប្តូរខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំពេញដើម្បីបញ្ជាក់ថា **"បានពិនិត្យរួច"** រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រណ្ឌ ទៅតាមលំដាប់លេខចុះបញ្ជី។

៤- ចំពោះការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន មន្ត្រីចុះបញ្ជីត្រូវសរសេរឈ្មោះ ឬ អាសយដ្ឋានថ្មី មូលហេតុនៃការផ្លាស់ប្តូរ និងកាលបរិច្ឆេទនៃការផ្លាស់ប្តូរ ចូលក្នុងសន្លឹកដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរួចហើយ នៅក្នុងខ្ទង់ពាក់ព័ន្ធនឹង "ការផ្លាស់ប្តូរឈ្មោះ និង អាសយដ្ឋាន" រួចមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងឈ្មោះរបស់មន្ត្រីចុះបញ្ជីនោះ។

## ប្រការ ៤០ ៖ របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

បញ្ញត្តិនៃប្រការ ៣៩ (របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) នៃប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

## ប្រការ ៤១ ៖ របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១- បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ២២ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ រំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ) ប្រការ ២៣ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តប្តីប្រពន្ធ ដោយមូលហេតុ មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) ប្រការ ២៤ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុសហព័ទ្ធណាម្នាក់បានស្លាប់) ប្រការ ២៥ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ រំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ) ប្រការ ២៦ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង) និងប្រការ ២៧ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកតាមសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ឃ) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរអំពីគោលបំណង មូលហេតុ និងកាលបរិច្ឆេទ នៅក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រង់ខ្ទង់ "ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ។

២- ចំពោះសន្លឹកចុះបញ្ជីក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា "**បានពិនិត្យរួច**" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រុណ្ឌ ទៅតាមលំដាប់លេខចុះបញ្ជី។

## ប្រការ ៤២ ៖ របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ២៨ (ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរអំពី

កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍នៅខ្ទង់ "កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍" នៅក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងឈ្មោះរបស់មន្ត្រីចុះបញ្ជី។

**ប្រការ ៤៣ : វិធីកត់ត្រាការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ពាក់ព័ន្ធនឹងការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នៅត្រង់ខ្ទង់ "ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឬ ខ្ទង់ "ការផ្លាស់ប្តូរទ្រព្យសម្បត្តិប្តីប្រពន្ធ" មន្ត្រីចុះបញ្ជីក៏អាចចុះថា "**ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានភ្ជាប់មកជាមួយ**" រួចភ្ជាប់នូវលិខិតថតចម្លងនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះជាមួយគ្នាក្នុងសន្លឹកចុះបញ្ជីនៃក្រុណ្ឌបាន។ ក្នុងករណីនេះ មន្ត្រីចុះបញ្ជីត្រូវកត់ត្រានូវលេខចុះបញ្ជី និង លេខទទួល នៅក្នុងលិខិតថតចម្លងនៃកិច្ចសន្យា ដែលបានភ្ជាប់មកជាមួយនោះ ហើយមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា "បានពិនិត្យរួច" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង សម្រេច។

២- ក្រោយពេលពិនិត្យ និងសម្រេចរួច រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងចុះហត្ថលេខា និងប្រថាប់ត្រានៅគ្រប់សន្លឹកនៃលិខិតថតចម្លងដែលបានភ្ជាប់មកជាមួយ។

**ប្រការ ៤៤ : របៀបចងក្រងរក្សាទុកក្នុងក្រុណ្ឌសម្រាប់ដាក់ឯកសារពាក្យសុំ**

ក្រោយពេលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានចុះហត្ថលេខា និងប្រថាប់ត្រារួច មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកពាក្យសុំចុះបញ្ជី និង ឯកសារភ្ជាប់ក្នុងក្រុណ្ឌសម្រាប់ដាក់ឯកសារពាក្យសុំ ទៅតាមលំដាប់លេខរៀង និងកាលបរិច្ឆេទទទួលពាក្យសុំ ។

**ប្រការ ៤៥ : របៀបចងក្រងរក្សាទុកក្នុងក្រុណ្ឌលើកចោល**

នៅពេលដែលមន្ត្រីចុះបញ្ជី បានលើកចោលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកលិខិតលើកចោលក្នុងក្រុណ្ឌលើកចោល ទៅតាមលំដាប់លេខលិខិតលើកចោល និងកាលបរិច្ឆេទ ។

**ប្រការ ៤៦ : របៀបចងក្រងរក្សាទុកក្នុងក្រុណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ**

ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពាក្យសុំឲ្យពិនិត្យឡើងវិញ និងឯកសារភ្ជាប់ ក្នុងក្រុណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ទៅតាមលំដាប់លេខពាក្យសុំឲ្យពិនិត្យឡើងវិញ និងកាលបរិច្ឆេទ ។

p

**ប្រការ ៤៧ : របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

រាល់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកពាក្យសុំនោះនៅក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ទៅតាមលំដាប់លេខនៃការទទួលពាក្យសុំឱ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី និងកាលបរិច្ឆេទ ។

## ជំពូកទី ៤
## នីតិវិធីនៃការចេញលិខិតបញ្ជាក់

**ប្រការ ៤៨ : របៀបដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់**

១- ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

២- ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ត្រូវដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ ។

៣- ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

- គោលបំណងនៃពាក្យសុំ ៖ ការសុំឱ្យចេញលិខិតបញ្ជាក់
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់
- ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គល ក្នុងករណីដែលអ្នកដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ជានីតិបុគ្គល
- ចំណុចដែលត្រូវធ្វើការបញ្ជាក់
- ចំនួនលិខិតបញ្ជាក់
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬ ស្នាមម្រាមដៃ ។

៤- អ្នកដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ត្រូវបង់សោហ៊ុយសេវា ដូចបានកំណត់តាមបទប្បញ្ញត្តិ ឬ ប្រកាសរួម របស់ក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤៩ : ការចេញលិខិតបញ្ជាក់**

១- នៅពេលបានទទួលពាក្យសុំឱ្យចេញលិខិតបញ្ជាក់ មន្ត្រីចុះបញ្ជីត្រូវថតចម្លងចេញពីសន្លឹកចុះបញ្ជីក្នុងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទៅឱ្យអ្នកដាក់ពាក្យសុំ ដោយត្រូវសរសេរនៅលើឯកសារថតចម្លងថា ៖

- បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- កាលបរិច្ឆេទ (ថ្ងៃទី..........ខែ.........ឆ្នាំ.........)
- ហត្ថលេខាបំព្រួញរបស់មន្ត្រីចុះបញ្ជី និង ហត្ថលេខា និង ប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏អាចឱ្យរដ្ឋលេខាធិការទទួលបន្ទុកកិច្ចការរដ្ឋប្បវេណី ចុះហត្ថលេខាជំនួសបានដែរ។

២- ក្រោយពីបានទទួលពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ក្រសួងយុត្តិធម៌ត្រូវចេញលិខិតបញ្ជាក់ឱ្យអ្នកដាក់ពាក្យសុំនោះ ដោយពុំមានការយឺតយ៉ាវ យ៉ាងយូរបំផុតមិនឱ្យលើសពីរយៈពេល ៣ ថ្ងៃ ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**ប្រការ ៥០ : កាលបរិច្ឆេទ នៃការអនុវត្ត**

ប្រកាសនេះ ត្រូវអនុវត្តក្រោយពេលប្រាំមួយខែបានកន្លងហួស គិតចាប់ពីថ្ងៃចុះហត្ថលេខា ។

ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

អង្គ វង្សវឌ្ឍនា

p

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ១
ប្រការ ១៩

## ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ.......................ភេទ ប្រុស អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្តី ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះ.......................ភេទ ស្រី អាយុ............ថ្ងៃ ខែ ឆ្នាំកំណើត......... ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង..........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត...................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជីៈ...................(ចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)...... ។
- មូលហេតុៈ.....................(កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រមទាំងកាលបរិច្ឆេទ)......... ។
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធៈ.......(សរសេរខ្លឹមសារកិច្ចសន្យាទាំងអស់)......... ....................................................................................................... ....................................................................................................... .......................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

p **ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធទី ២
ប្រការ ២០

## ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ........................ភេទ ប្រុស អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្តី ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ...............រាជធានី ខេត្ត........... ។

ឈ្មោះ........................ភេទ ស្រី អាយុ..............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង.........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត...................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី:.........(ចុះបញ្ជីផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)...... ។
- មូលហេតុ:...........(ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រមទាំងកាលបរិច្ឆេទ)... ។
- ចំណុចដែលត្រូវផ្លាស់ប្តូរ:.......(សរសេរទាំងអស់នូវខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្រោយពីការផ្លាស់ប្តូររួច)...........................................................................
..........................................................................................................
..........................................................................................................
..........................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

**ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៣
ប្រការ ២០

## ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន

ឈ្មោះ......................ភេទ ....... អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្តី ឬ ប្រពន្ធ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់.............ក្រុង ស្រុក ខណ្ឌ...............រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង.........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត..................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន។

- គោលបំណងនៃការចុះបញ្ជីៈ...................(ចុះបញ្ជីផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន)...... ។
- មូលហេតុៈ......................(ការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន ព្រមទាំងកាលបរិច្ឆេទ)... ។
- ចំណុចដែលត្រូវផ្លាស់ប្តូរៈ.......(ឈ្មោះថ្មី ឬ អាសយដ្ឋានថ្មី)..........................................
..........................................................................................................................
..........................................................................................................................
.........................................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........
ស្នាមម្រាមដៃ

ឈ្មោះ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៤
ប្រការ ២១

## ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ.......................ភេទ ប្រុស អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្តី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ........ ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះ.......................ភេទ ស្រី អាយុ..............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ......... ឃុំ សង្កាត់............ ក្រុង ស្រុក ខណ្ឌ..................... រាជធានី ខេត្ត..................... ។

### សូមគោរពជូន
### ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការការកែតម្រូវការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជីៈ...........(កែតម្រូវកំហុស ឬ ការខកខានមិនបានចុះបញ្ជី).... ។
- មូលហេតុៈ.....................(មានកំហុស ឬ ការខកខានមិនបានចុះបញ្ជី)..................... ។
- ចំណុចដែលត្រូវកែតម្រូវៈ
  - ឈ្មោះ.........................................................................................................
  - អាសយដ្ឋាន...................................................................................................
  - ថ្ងៃខែឆ្នាំកំណើត..............................................................................................
  - ខ្លឹមសារនៃទ្រព្យសម្បត្តិប្តីប្រពន្ធ..........................................................................

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

ស្នាមម្រាមដៃ

ប្តីឈ្មោះ ប្រពន្ធឈ្មោះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៥
ប្រការ ២២ - ២៧

## ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ [1]

ឈ្មោះ........................ភេទ ប្រុស អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្តី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះ........................ភេទ ស្រី អាយុ..............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង..........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............ ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត...................... ។

### សូមគោរពជូន
### ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី:...........(លុបការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ)................ ។
- មូលហេតុ:......................(ការលែងលះអាពាហ៍ពិពាហ៍ ព្រមទាំងកាលបរិច្ឆេទ ឬ លែងលះកំជាប់ពាក្យ ព្រមទាំងកាលបរិច្ឆេទ)..............................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

ស្នាមម្រាមដៃ

p

ប្តីឈ្មោះ ប្រពន្ធឈ្មោះ

[1] ក្នុងករណីមោឃភាព ការលុបចោល ឬការលែងលះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ លែងលះអាពាហ៍ពិពាហ៍ ឬកំជាប់ពាក្យ ដោយផ្អែកលើសេចក្តីសម្រេចរបស់តុលាការ អ្នកដាក់ពាក្យសុំអាចដាក់ពាក្យសុំតែម្នាក់ឯងបាន។

ឧបសម្ព័ន្ធទី ៦
ប្រការ ២៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

ឈ្មោះ........................ភេទ ប្រុស អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្ដី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះ........................ភេទ ស្រី អាយុ............ថ្ងៃ ខែ ឆ្នាំកំណើត......... ជាប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង........................ភេទ.......អាយុ.......ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ......... ឃុំ សង្កាត់............ ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត.................... ។

**សូមគោរពជូន**
**ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។

- គោលបំណងនៃការចុះបញ្ជី ៖ ការចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ។
- មូលហេតុ: ការរៀបអាពាហ៍ពិពាហ៍ ។
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ៖.................................................... ។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ធ្វើនៅ................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

**ស្នាមម្រាមដៃ**

**ប្ដីឈ្មោះ** **ប្រពន្ធឈ្មោះ**

p

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធទី ៧
ប្រការ ៤៨

## ពាក្យសុំឲ្យចេញលិខិតបញ្ជាក់

ឈ្មោះ.......................ភេទ ....... អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្ដី [ ] ឬ ប្រពន្ធ [ ] ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា [ ] ឬ ជាបុគ្គលផ្សេងទៀត អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ.............ភូមិ.............. ឃុំ សង្កាត់.................. ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង.........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត................ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត..................... ។

**សូមគោរពជូន**
**ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំឲ្យចេញលិខិតបញ្ជាក់។

- គោលបំណងនៃពាក្យសុំ ៖ ការសុំឲ្យចេញលិខិតបញ្ជាក់
- ចំណុចដែលត្រូវធ្វើការបញ្ជាក់ ៖ ............................
- ចំនួនលិខិតបញ្ជាក់ ៖......................ច្បាប់

អាស្រ័យហេតុនេះ សូមឯកឧត្ដមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតតាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ធ្វើនៅ................ថ្ងៃទី.......ខែ.........ឆ្នាំ ២០........

**ស្នាមម្រាមដៃ**

**ឈ្មោះ**

p

ឧបសម្ព័ន្ធទី ៨

# សន្លឹកក្រដាសទទួលពាក្យសុំ

| លេខរៀងទទួលពាក្យ | កាលបរិច្ឆេទនៃការទទួលពាក្យសុំ | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកដាក់ពាក្យសុំ | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកតំណាង (ប្រសិនបើមាន) | ប្រភេទនៃការចុះបញ្ជីកិច្ចសន្យា ប្តីប្រពន្ធ | ជាប្តីប្រពន្ធ | ជាបុគ្គលដែលត្រូវរៀបការជាមួយគ្នា | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | | | | |

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៩

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ ថ្ងៃទី......ខែ...........ឆ្នាំ..........

| លេខចុះបញ្ជី[2] : | ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្តូរ | កាលបរិច្ឆេទនៃការផ្លាស់ប្តូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : <br> ថ្ងៃខែឆ្នាំកំណើត : <br> អាសយដ្ឋាន : | | | | |
| ឈ្មោះ : <br> ថ្ងៃខែឆ្នាំកំណើត : <br> អាសយដ្ឋាន : | | | | |

កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

គោលបំណងនៃការចុះបញ្ជី :
មូលហេតុ និងកាលបរិច្ឆេទ :

ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ :

[2] លេខចុះបញ្ជី ៖ សំដៅទៅលើលេខដែលបានចុះនៅក្នុងសន្លឹកក្រដាសទទួលពាក្យសុំ (ឧបសម្ព័ន្ធទី ៨) ត្រង់ខ្ទង់ "ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ" ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ១០

នីស្ថីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

# សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ. ថ្ងៃទី.........ខែ.... .. ...ឆ្នាំ..........

| លេខចុះបញ្ជី [3] | ឈ្មោះប្តី ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា ៖ | ឈ្មោះប្រពន្ធ ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា៖ |
| --- | --- | --- |
| | | |

គោលបំណងនៃការចុះបញ្ជី :

មូលហេតុ និងកាលបរិច្ឆេទ :

ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

p

[3] លេខចុះបញ្ជី ៖ សំដៅទៅលើលេខដែលបានចុះនៅក្នុងសន្លឹកក្រដាសទទួលពាក្យសុំ (ឧបសម្ព័ន្ធទី ៨) ត្រង់ខ្ទង់ "ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ" ។

គំរូចុះបញ្ជី ១
ការទទួលពាក្យសុំ

# សន្លឹកក្រដាសទទួលពាក្យសុំ

| លេខរៀងទទួលពាក្យ | កាលបរិច្ឆេទនៃការទទួលពាក្យសុំ | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកដាក់ពាក្យសុំ | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកតំណាង (ប្រសិនបើមាន) | ប្រភេទនៃការចុះបញ្ជីកិច្ចសន្យា ប្តីប្រពន្ធ | ជាប្តីប្រពន្ធ | ជាបុគ្គលដែលត្រូវរៀបការជាមួយគ្នា | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ០១ | ២០.០៣.២០១៣ | - ហុក ច័ន្ទសុវណ្ណារ៉ា #១៨២B, St. ៩ ...... - លី សាមឌី #១៨៣A, St. ៩ ...... ① | | កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ | -ប្តី -ប្រពន្ធ | | |
| ០២ | | - ហុក ច័ន្ទសុវណ្ណារ៉ា #១៨២B, St. ៩ ...... - លី សាមឌី #១៨៣A, St. ៩ ... .. ① | | ផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ | | | |
| ០៣ | | ធីរៈ ② | | | | | |
| ០៤ | | យស ③ | | | | | |
| ០៥ | | រតនា ④ | | | | | |
| ០៦ | | ឫទ្ធី ⑤ | | | | | |
| ០៧ | | Emiko ⑥ | | | | | |
| ០៨ | | ធីរៈ ② | | លុបកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ | | | |

ក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| គំរូចុះបញ្ជី ២<br>ការបង្កើត |
|---|

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្ដូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្ដូរ | កាលបរិច្ឆេទនៃការផ្លាស់ប្ដូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៨.០៩.១៩៨១<br>អាសយដ្ឋាន : #១៨២B, St. ៩ . .. | | | | |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : #១៨៣A, St. ៩ .... | | | | |

| | | |
|---|---|---|
| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ | |

| | |
|---|---|
| គោលបំណងនៃការចុះបញ្ជី : បង្កើត<br>មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣ | ហត្ថលេខាបំព្រួញ |

## ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្ដី។

ដី

ទីតាំង៖ ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខក្បាលដី ៖ លេខ ០០១

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣

(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

វីឡា

ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្ដី។

Lexus 570

ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងភាគព្វកិច្ចដែលប្ដីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។

៥. ទ្រព្យសម្បត្តិដែលប្ដី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ។

p

ហត្ថលេខា
រដ្ឋមន្ត្រី

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ :

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| គំរូចុះបញ្ជី ៣ ការបង្កើត |
|---|

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៣

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្តូរ | កាលបរិច្ឆេទនៃការផ្លាស់ប្តូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៥.១៩៨១<br>អាសយដ្ឋាន : #១៨២B, St. ៥ ..... | | | | |
| ឈ្មោះ : លី សាមនី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : #១៨៣A, St. ៥ ..... | | | | |

| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ | |
|---|---|---|

គោលបំណងនៃការចុះបញ្ជី : បង្កើត

មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣

(ហត្ថលេខាបំព្រួញ)

## ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានភ្ជាប់មកជាមួយ-

(ហត្ថលេខា រដ្ឋមន្ត្រី)

p

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ :



p

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខរៀងទទួលពាក្យសុំ ៖ ០១
លេខរៀងចុះបញ្ជី ៖ ០១

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ប្តីឈ្មោះ ហុក ច័ន្ទសុវណ្ណារ៉ា ភេទ ប្រុស សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ
ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៨១
អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ប្រពន្ធឈ្មោះ លី សាមឌី ភេទ ស្រី សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ
ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៨១
អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ក្នុងនាមជាប្តីប្រពន្ធ យើងបានព្រមព្រៀងគ្នាទៅលើទ្រព្យសម្បត្តិរបស់ភាគីទាំងសងខាង ដូចខាងក្រោម ៖

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។

ដី

ទីតាំង៖ ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខក្បាលដី ៖ លេខ ០០១

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣

(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

វីឡា

ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្តី។

Lexus 570

ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងការតព្វកិច្ចដែលប្តីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។

៥. ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៣

p ស្នាមម្រាមដៃ ស្នាមម្រាមដៃ

ឈ្មោះប្តី ឈ្មោះប្រពន្ធ
ហុក ច័ន្ទសុវណ្ណារ៉ា លី សាមឌី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូចុះបញ្ជី ៤
ការផ្លាស់ប្តូរកិច្ចសន្យា

ពិស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

## សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ. ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣

| លេខចុះបញ្ជី : ០១ | ឈ្មោះប្តី ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា ៖ ហុក ច័ន្ទសុវណ្ណារ៉ា | ឈ្មោះប្រពន្ធ ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា៖ លី សាមឌី |
|---|---|---|

គោលបំណងនៃការចុះបញ្ជី : ការផ្លាស់ប្តូរ

ហត្ថលេខាបំព្រួញ

មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១ ០៤ ២០១៣

### ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

ដី

ទីតាំង៖ ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខក្បាលដី ៖ លេខ ០០១

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣

(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។

វីឡា

ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្តី។

Lexus 570

ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងកាតព្វកិច្ចដែលប្តីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។

៥. ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

ហត្ថលេខា
រដ្ឋមន្ត្រី

p

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូចុះបញ្ជី ៥
ការផ្លាស់ប្តូរកិច្ចសន្យា

# សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ. ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៣

| លេខចុះបញ្ជី : ០១ | ឈ្មោះប្តី ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា ៖<br>ហុក ចិន្តសុវណ្ណារ៉ា | ឈ្មោះប្រពន្ធ ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា៖<br>លី សាមឌី |
|---|---|---|

| | |
|---|---|
| គោលបំណងនៃការចុះបញ្ជី : ការផ្លាស់ប្តូរ<br>មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០៤.២០១៣ | ហត្ថលេខាចំហ្រួញ |

ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានភ្ជាប់មកជាមួយ-

ហត្ថលេខា
រដ្ឋមន្ត្រី

ក្រោមយកឃ្លះ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខរៀងទទួលពាក្យសុំ ៖ ០២
លេខរៀងចុះបញ្ជី ៖ ០១

# កិច្ចសន្យាផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ប្ដីឈ្មោះ ហុក ច័ន្ទសុវណ្ណារ៉ា ភេទ ប្រុស សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ
ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៨១
អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ប្រពន្ធឈ្មោះ លី សាមឌី ភេទ ស្រី សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ
ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៨១
អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ក្នុងនាមជាប្ដីប្រពន្ធ យើងបានព្រមព្រៀងគ្នាធ្វើការផ្លាស់ប្ដូរទៅលើទ្រព្យសម្បត្តិចំនួន ២ ក្នុង ចំនោមទ្រព្យសម្បត្តិដែលបានព្រមព្រៀងពីមុន ដូចខាងក្រោម ៖

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

ដី

ទីតាំង៖ ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខក្បាលដី ៖ លេខ ០០១

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣

(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្ដី។

វីឡា

ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៣

| | |
|---|---|
| ស្នាមម្រាមដៃ | ស្នាមម្រាមដៃ |
| p | |
| ឈ្មោះប្ដី | ឈ្មោះប្រពន្ធ |
| ហុក ច័ន្ទសុវណ្ណារ៉ា | លី សាមឌី |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

| គំរូចុះបញ្ជី ៦ |
|---|
| ការលុបការចុះបញ្ជី |

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២១

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្តូរ | កាលបរិច្ឆេទនៃការផ្លាស់ប្តូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៩.១៩៨១<br>អាសយដ្ឋាន : #១៨២B, St. ៥ ...... | | | | |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : #១៨៣A, St. ៥ ... | | | | |

| | | |
|---|---|---|
| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ | |

| | |
|---|---|
| គោលបំណងនៃការចុះបញ្ជី : បង្កើត<br>មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣ | ហត្ថលេខាបំព្រួញ |

## ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។

ដី

ទីតាំង៖ ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ

លេខក្បាលដី ៖ លេខ ០០១

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣

(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកានកាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

វីឡា

ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្តី។

Lexus 570

ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងកាតព្វកិច្ចដែលប្តីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។

៥ ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

ហត្ថលេខា
រដ្ឋមន្ត្រី

p

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ :

លុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើដីកាសម្រេចលែងលះអាពាហ៍ពិពាហ៍តាមការព្រមព្រៀង លេខ ០១
ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២០

ហត្ថលេខាបំព្រួញ

ហត្ថលេខា
រដ្ឋមន្ត្រី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| គំរូចុះបញ្ជី ៧ |
| --- |
| ការលុបការចុះបញ្ជី |

ឱស្ថការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២១

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្តូរ | កាលបរិច្ឆេទនៃការផ្លាស់ប្តូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
| --- | --- | --- | --- | --- |
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៩.១៩៨១<br>អាសយដ្ឋាន : #១៨២B, St. ៩ ..... | | | | |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥ ១០.១៩៨១<br>អាសយដ្ឋាន : #១៨៣A, St. ៩ ..... | | | | |

| | | |
| --- | --- | --- |
| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ | |

គោលបំណងនៃការចុះបញ្ជី : បង្កើត
មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣

(ហត្ថលេខាចាប់ហ្វ្រញ)

ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

"ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានភ្ជាប់មកជាមួយ"

(ហត្ថលេខា រដ្ឋមន្ត្រី)

p

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ :
លុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើដីកាសម្រេចលែងលះអាពាហ៍ពិពាហ៍តាមការព្រមព្រៀង លេខ ០១
ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២០ (ហត្ថលេខាចាប់ហ្វ្រញ)

(ហត្ថលេខា រដ្ឋមន្ត្រី)

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូចុះបញ្ជី ៨
ការផ្លាស់ប្តូរអាសយដ្ឋាន

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៥

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្តូរ | កាលបរិច្ឆេទនៃការផ្លាស់ប្តូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
| --- | --- | --- | --- | --- |
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៩.១៩៨១<br>អាសយដ្ឋាន : ផ្ទះលេខ ១៨២B, ផ្លូវលេខ ៩ សង្កាត់មានជ័យខណ្ឌមានជ័យ រាជធានីភ្នំពេញ. | ផ្ទះលេខ ៣០E០ ផ្លូវ ១៦៣ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ | ផ្លាស់ប្តូរអាសយដ្ឋាន | ថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៥ | ហត្ថលេខា |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : ផ្ទះលេខ ១៨៣A, ផ្លូវលេខ ៩ សង្កាត់មានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | | | | |

| | |
| --- | --- |
| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ |

គោលបំណងនៃការចុះបញ្ជី : បង្កើត
មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១ ០១.២០១៣

ហត្ថលេខាបំពេញ

## ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។
ដី
ទីតាំង៖ ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ
លេខក្បាលដី ៖ លេខ ០០១
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣
(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។
វីឡា
ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣ រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្តី។
Lexus 570
ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងកាតព្វកិច្ចដែលប្តីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។
៥. ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

p

ហត្ថលេខា
រដ្ឋមន្ត្រី

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ :